**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់
# និងសោភ័ណភាពខេត្តរតនគិរី

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ខាត់ ស្រីវី**

**ក.មាំង សារ៉ាន់**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ខាត់ ស្រីវី**

**ក.ម៉ាំង សារ៉ាន់**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ខាត់ ស្រីទី** និងនាងខ្ញុំឈ្មោះ **ម៉ាំង សារ៉ាន់** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ជំនាន់ទី២៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២២-២០២៣។

ជាបឋមនាងខ្ញុំទាំងពីរនាក់ មានកិត្តិយសសូមសេចក្តីអនុញ្ញាត ដើម្បីបានសម្តែងនូវគារវកិច្ចគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ អ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ**ដែលបានប្រឹងប្រែងប្រកបដោយព្រហ្មវិហាធម៌ចិញ្ចឹមបីបាច់ ថែរក្សា លះបង់ទាំងកម្លាំងកាយទាំងកម្លាំងចិត្ត ធនធានក្តីស្រឡាញ់ ភាពកក់ក្តៅគ្រប់បែបយ៉ាង បណ្តុះទឹកចិត្តកតញ្ញូតាធម៌ ចំពោះគ្រប់អ្នកមានគុណ និងបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ដើម្បីឱ្យកូនក្លាយខ្លួនជាពលរដ្ឋល្អ ជាទំពាំងស្នងឬស្សីយ៉ាងរឹងមាំសម្រាប់ប្រទេសជាតិ។

សូមគោរពអរគុណដល់ **ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រងព្រមទាំងសាស្ត្រាចារ្យ ទាំងអស់** ដែលបានខិតខំប្រឹងប្រែង និងលទ្ធភាពគ្រប់បែបយ៉ាងក្នុងការដឹកនាំក្នុងគោលបំណងបណ្តុះបណ្តាលមូលធនផ្នែកបញ្ញាធនធានមនុស្សកម្ពុជា ឱ្យមានចំណេះដឹងបទពិសោធន៍និងមានសមត្ថភាពខ្ពស់ដើម្បីក្លាយជាសសរទ្រូងស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

សូមគោរពអគុណដល់ **លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំកែលម្អ និងចង្អុលបង្ហាញតម្រង់ទិសព្រមទាំងពន្យល់ពីវិធីសាស្ត្រ និងផ្តល់យោបល់ល្អៗទាក់ទងនឹងប្រធានបទសារណារបស់នាងខ្ញុំទាំងពីរនាក់ រួមទាំងការចំណាយពេលវេលា ដ៏មានតម្លៃតាំងពីដើមដល់បញ្ចប់ការសិក្សាស្រាវជ្រាវនេះ។

ជាចុងក្រោយ នាងខ្ញុំទាំងពីរនាក់មាន កិត្តិយស សូមសេចក្តីអនុញ្ញាតគោរពជូនពរដល់ អ្នកមានគុណទាំងអស់ សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុតនូវភក្តីភាព ការគោរពស្រលាញ់ ក្នុងភាពសុចរិតដែលជាតម្លៃដ៏ឧត្តុងឧត្តមនៃសេចក្តីថ្លៃថ្នូរ ព្រមទាំងកតញ្ញូតាធម៌បំផុត។ នាងខ្ញុំទាំងពីរនាក់ សូមឱ្យអ្នកមានគុណទាំងអស់ទទួលបាននូវ ភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃរកទទួលទានមានបាន គ្រប់ៗគ្នាព្រមទាំងជួបនូវ ពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំទាំងពីរនាក់ បានសិក្សាថ្នាក់បរិញ្ញាបត្រនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះបានទទួលនូវចំណេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តី និងការអនុវត្តផងដែរ។ ដោយយោងតាមចំណេះដឹងទាំងអស់នេះបានជាមានឱកាស និងមានលទ្ធភាពបានសរសេរសារណាបញ្ចប់ការសិក្សាមួយសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ។ នេះគឺជាឱកាសយ៉ាងវិសេសវិសាលបំផុតសម្រាប់វាស់ស្ទង់នូវចំណេះដឹងដែលមានពីមុនមក និងសិក្សាស្រាវជ្រាវបន្ថែមទៀត។ ហេតុនេះហើយទើបនាងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តក្នុងការជ្រើសរើសយកប្រធានបទមួយដែលទាក់ទងនឹង **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី** មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយសារតែមានចំណុចជាច្រើនដែលជាបញ្ហាចោទត្រូវសិក្សា និងរកពីហេតុបង្ក និងដំណោះស្រាយជាដើម។

កម្មវត្ថុសំខាន់មួយទៀតនោះចង់ឱ្យនិស្សិតជំនាន់ក្រោយ និងសាធារណជនបានយល់ដឹងអំពីបញ្ហានៃការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពយ៉ាងស្រស់ស្អាត មានបរិស្ថានរស់នៅល្អមិនមានការរំខាន និងការបំពុលផ្សេងៗ ព្រមទាំងវិធានការដោះស្រាយមួយចំនួនដែលអាចកើតមានឡើងនៅក្នុងការរៀបចំ។ លើសពីនេះទៅទៀត នាងខ្ញុំទាំងពីរនាក់មានគោលបំណងចង់បង្ហាញអំពី ការរីកចម្រើនដែលមាននៅក្នុងខេត្តរតនគិរី។ ម្យ៉ាងទៀត ឃើញថាទោះបីជាមានការរីកចម្រើនយ៉ាងណាក៏ដោយ ក៏បញ្ហាអសន្តិសុខ សណ្តាប់ធ្នាប់ ក្មេងញៀនថ្នាំ បញ្ហាបរិស្ថានក៏នៅកើតមានដែរ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរនាក់ សូមគោរពទទួលយកនូវរាល់កំហុសឆ្គាំឆ្គងណាមួយដោយចេតនា ឬអចេតនា ឬមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយ សូមមេត្តាខន្តី អភ័យទោសដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំទាំងពីរនាក់ និងរង់ចាំទទួលនូវមតិរិះគន់កែលម្អរាល់ចំណុចខ្វះខាតទាំងឡាយក្នុងន័យស្ថាបនា ដើម្បីឱ្យការស្រាវជ្រាវមួយនេះមានអត្ថន័យ គ្រប់គ្រាន់បន្ថែម។ សូមគោរពជូនពរដល់មិត្តនិស្សិត មិត្តអ្នកអានទាំងអស់សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា ប្រាជ្ញាវាងវៃ រកទទួលទានមានបានគ្រប់ៗគ្នាព្រមទាំងជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......................................................................................................១

## ជំពូកទី១

## សញ្ញាណទូទៅនៃការរៀបចំខេត្តរតនគិរី

**១.១. ទិដ្ឋភាពទូទៅ** .................................................................................................៤
១.១.១. ទីតាំងភូមិសាស្ត្រ .................................................................................................. ៥
១.១.១.១. តំបន់ទេសចរណ៍ ...............................................................................................៦
១.១.១.២. តំបន់បង្កបង្កើនផល.............................................................................................៩
១.១.២. ដង់ស៊ីតេប្រជាជន ................................................................................................ ១០
**១.២. សមត្ថកិច្ចដែលពាក់ព័ន្ធនឹងការរៀបចំខេត្ត** ............................................................ ១១
១.២.១. សមាសភាព.......................................................................................................... ១២
១.១.១.២. ក្រុមប្រឹក្សាខេត្ត.............................................................................................. ១៨
១.២.១.២. គណៈអភិបាលខេត្ត............................................................................................ ១៨
១.២.២. តួនាទី និងភារកិច្ច................................................................................................. ២០
១.២.២.១. ក្រុមប្រឹក្សាខេត្ត................................................................................................២០
១.២.២.២. គណៈអភិបាលខេត្ត............................................................................................២៤
**១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំខេត្ត**..........................................................................២៩
១.៣.១. កំណើនប្រជាជន ................................................................................................. ២៩
១.៣.២. ភាពក្រីក្រ............................................................................................................ ៣១
១.៣.៣. កម្រិតជីវភាពនៃការរស់នៅ......................................................................................៣២
១.៣.៤. ការដាក់សម្ពាធបរិស្ថាន .........................................................................................៣៣
១.៣.៥. គមនាគមន៍ .........................................................................................................៣៣

# ជំពូកទី២

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី

**២.១. ការរៀបចំខេត្តរតនគិរី** ........ ៣៥

២.១.១. ការរៀបចំសោភ័ណភាពខេត្តរតនគិរី ........ ៣៥

២.១.១.១. សោភ័ណភាពពេលថ្ងៃ ........ ៣៦

២.១.១.២. សោភ័ណភាពពេលយប់ ........ ៣៨

២.១.២. ការរៀបចំសណ្ដាប់ធ្នាប់ ........ ៣៩

២.១.២.១. សន្ដិសុខ ........ ៤០

២.១.២.២. ផាសុកភាព ........ ៤៣

**២.២. បញ្ហាប្រឈមនៃការរៀបចំខេត្ត** ........ ៥៧

២.២.១. ធនធានមនុស្ស ........ ៥៧

២.២.២. គម្រោងថវិកា ........ ៥៨

២.២.៣. កង្វះបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ ........ ៥៨

**២.៣. ដំណោះស្រាយ** ........ ៥៩

២.៣.១. ការសហការពីប្រជាពលរដ្ឋ ........ ៦០

២.៣.២. ប្លង់គោល ........ ៦០

**សេចក្ដីសន្និដ្ឋាន** ........ ៦៣

**អនុសាសន៍** ........ ៦៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

តាំងពីសម័យបុរាណមកម្លេះ នៅគ្រប់បណ្ដាប្រទេសទាំងអស់សង្កេតឃើញថាសុទ្ធតែមានការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំខេត្ត និងប្រទេសរបស់ខ្លួនឱ្យមានសណ្ដាប់ធ្នាប់ របៀបរៀបរយមានភាពស្រស់ស្អាតមានសុខសន្តិភាពពេញលេញ និងមានបរិស្ថានល្អ គ្រាន់តែរបៀបនៃការរៀបចំ និងការអភិវឌ្ឍនោះមានភាពខុសគ្នាទៅតាមស្ថានភាពគ្រប់គ្រង និងយុទ្ធសាស្ត្ររបស់អ្នកដឹកនាំនៃប្រទេសនីមួយៗហើយសម្រាប់ប្រទេសកម្ពុជាការរៀបចំខេត្ត និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធកើតមានតាំងពីសម័យបុរាណមកម្លេះ ហើយក៏នៅតែបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះផងដែរ។

ប្រទេសកម្ពុជាត្រូវបានបែងចែកជា២៥ខេត្តក្រុង ហើយក្រុង និងខេត្តនីមួយៗគឺសុទ្ធសឹងតែមានការរៀបចំសណ្ដាប់ធ្នាប់ សោភ័ណភាព និងបរិស្ថានក្នុងខេត្ត និងក្រុងឱ្យបានល្អប្រសើរទៅតាមលទ្ធភាព និងស្ថានភាពរបស់ខេត្ត ក្រុងរបស់ខ្លួន។ ក្នុងនោះផងដែរខេត្តរតនគិរីដែលជាខេត្តតែមួយគត់ដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ ហើយជាខេត្តមួយដែលមានការទាក់ទាញភ្ញៀវទេសចរមកទស្សនាពីថ្នាក់ជាតិ និងថ្នាក់អន្តរជាតិជាច្រើនឱ្យមកកម្សាន្ត ម៉្យាងវិញទៀតរដ្ឋបាលខេត្តរតនគិរីបានយកចិត្តទុកដាក់ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងធ្វើការរៀបចំ កែលម្អសណ្ដាប់ធ្នាប់ សោភ័ណភាព សន្តិសុខ សុវត្ថិភាព និងបរិស្ថានខេត្តរបស់ខ្លួនក៏ដូចជាខិតខំរិះរកវិធីសាស្ត្រធ្វើយ៉ាងណាឱ្យការរៀបចំខេត្ត កាន់តែល្អប្រសើរ និងដំណោះស្រាយទាក់ទងទៅនឹងបញ្ហាប្រឈមផ្សេងៗដែលកើតមានឡើងដើម្បីឱ្យស្របទៅតាមស្តង់ដារ និងដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិមកពីគ្រប់ទិសទីឱ្យមកទស្សនាកាត់តែច្រើនបន្ថែមទៀត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាឱ្យមានលក្ខណៈស៊ីជម្រៅ និងមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទសារណាខាងលើ នាងខ្ញុំទាំងពីរនាក់ បានលើកឡើងនូវចំណោទបញ្ហាមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងនោះរួមមាន "តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំខេត្តរតនគិរីនេះឡើង? តើធ្វើដូចម្ដេច ដើម្បីរៀបចំខេត្តរតនគិរីនេះឱ្យមានសណ្ដាប់ធ្នាប់ និងសោភ័ណភាព? និងបច្ចុប្បន្នភាពការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ សោភ័ណភាពបរិស្ថានរស់នៅល្អមិនមានការបំពុលផ្សេងៗ និងវិធានការដោះស្រាយនៃការបំពុលទាំងនោះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទមកធ្វើការស្រាវជ្រាវដែលទាក់ទងទៅនឹង នីតិនគរូបនីយកម្មស្ដីពី "**ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី**" យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ គឺដើម្បីឱ្យមានការរីកចម្រើនដល់ជ្រុងណាមួយនៅក្នុងសង្គម ព្រមទាំងបង្ហាញពីការ

ជំរុញឱ្យមានការអភិវឌ្ឍ ការរៀបចំឱ្យមានសន្តិសុខសណ្តាប់ធ្នាប់ល្អក្នុងការរស់នៅ។ ជាពិសេស គឺចង់ឱ្យសិស្ស និស្សិតជំនាន់ក្រោយៗបានយល់ដឹង និងជ្រួតជ្រាបច្បាស់ពីការអភិវឌ្ឍ ព្រមទាំងអាចយកឯកសារនេះសម្រាប់ជាជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួនផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវប្រធានបទនីមួយៗ គឺតែងតែមានគោលបំណងក្នុងការស្រាវជ្រាវ។ ហេតុនេះអ្វីដែលទាក់ទងនឹងប្រធានបទ"**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី** "គឺធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលទាក់ទងនឹងការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពក្នុងខេត្តរតនគិរីតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ដល់សិស្សនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ ព្រមទាំងសាធារណជនទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងខេត្តរតនគិរី ដើម្បីធ្វើយ៉ាងណាឱ្យខេត្តមានការអភិវឌ្ឍ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចំពោះប្រធាបទ"**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី**"គឺធ្វើការបកស្រាយ និងបំភ្លឺទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សណ្តាប់ធ្នាប់ សោភ័ណភាព ហើយរបៀបរៀបរយ សុខសុវត្ថិភាពនានាដែលមានបញ្ហាប្រឈម និងដំណោះស្រាយរបស់ខេត្តរតនគិរីផ្ទាល់។ រាល់ឯកសារដែលពាក់ព័ន្ធនឹងប្រធានបទនេះនាងខ្ញុំទាំងពីរបានស្វែងរកឯកសារពាក់ព័ន្ធមួយចំនួន គឺបានមកពីការដកស្រង់ចេញពីបណ្ណាល័យនីតិសាស្ត្រ នៃសាកលលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចតាមរយៈប្រព័ន្ធអ៊ីនធឺណេត គេហទំព័រ និងសៀវភៅសិក្សាផ្សេងៗជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ឆ្នាំសិក្សានេះនាងខ្ញុំទាំងពីរនាក់ បានធ្វើការបែងចែកជា២ជំពូកក្នុងនោះរួមមាន៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការរៀបចំខេត្តរតនគិរី"** នៅក្នុងជំពូកទី១ នេះក្រុមនាងខ្ញុំបានបែងចែកជាបីចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពី ទិដ្ឋភាពទូទៅនៃការរៀបចំខេត្តរតនគិរី ចំណុចទី២ និយាយអំពី សមត្ថកិច្ចដែលពាក់ព័ន្ធនឹងការរៀបចំខេត្តរតនគិរី និងចំណុចទី៣ និយាយអំពីកត្តាដែលជំរុញឱ្យមានការរៀបចំខេត្ត ។

- **ជំពូកទី២ "ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី"** នៅក្នុងជំពូកទី២នេះ នាងខ្ញុំទាំងពីរនាក់ បានបែងចែកជាបីចំណុចបន្ថែមទៀតដោយចំណុចទី១ និយាយអំពីការរៀបចំខេត្តរតនគិរីចំណុចទី២ និយាយអំពីផលវិបាកនៃការរៀបចំខេត្ត និងចំណុចទី៣ និយាយអំពីដំណោះស្រាយ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំ

# ខេត្តរតនគិរី

# ជំពូកទី១
# សញ្ញាណទូទៅនៃការរៀបចំខេត្តរតនគិរី

ខេត្តរតនគិរីត្រូវបានបង្កើតឡើងនៅក្នុងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៥៩ ហើយពេលនោះខេត្តនេះមានស្រុកចំនួនតែ៣ប៉ុណ្ណោះមានដូចជា ស្រុកវើនសៃ ស្រុកអណ្តូងពេជ្រ និងស្រុកលំផាត់។ ពេលនោះមានប្រជាជនតិចតួចនៅឡើយទេដែលភាគច្រើនមានតែបងប្អូនជនជាតិដើមភាគតិចដែលជាម្ចាស់ស្រុកប៉ុណ្ណោះហើយពួកគេរស់នៅដោយពឹងអាស្រ័យផលទៅលើការធ្វើបរកសិកម្មពនេចរ  និងការបរបាញ់សត្វសម្រាប់ចិញ្ចឹមជីវិត ហើយកាលនោះពុំទាន់មានការរៀបចំហេដ្ឋារចនាសម្ព័ន្ធដូចបច្ចុប្បន្នទេ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំស្តាឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលដែនដី និងការគ្រប់គ្រង។ ចំណែកក្នុងខេត្តរតនគិរីពេលនោះស្រុកវើនសៃបានប្តូរមកក្រុងបានលុងវិញ ព្រមទាំងបានសាងសង់វារីអគ្គិសនីអូរជុំដែលជាវារីអគ្គិសនីដំបូងគេបង្អស់នៅកម្ពុជា សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាជនដែលរស់នៅទីនោះក្រោមគំនិតផ្តួចផ្តើមរបស់ ឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ ប៊ូ ថង  ដែលបានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធខេត្តឡើងវិញ និងការដឹកនាំដោយផ្ទាល់ពីសំណាក់ ឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ ប៊ូ ថង រួមទាំងឥស្សរជនមួយចំនួនទៀតសម្រេចបានជាស្ថាពរនៅឆ្នាំ១៩៩៣។[១]

យ៉ាងណាមិញក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ  ខេត្តរតនគិរីមានការអភិវឌ្ឍ គួឱ្យកត់សម្គាល់ជាបន្តបន្ទាប់ដែលមាន ស្រុកចំនួន៨ និងមានក្រុង១ឈ្មោះ បានលុង ព្រមទាំងមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធមានប្រព័ន្ធរំដោះទឹកកខ្វក់ មានប្រព័ន្ធទឹកស្អាត មានការកសាង និងជួសជុលផ្លូវគមនាគមន៍ ការរៀបចំប្រមូលសំរាម មានសួនច្បារ មានគំនូសសញ្ញាចរាចរណ៍ មានបំពាក់ភ្លើងអគ្គិសនីតាមផ្លូវសាធារណៈ មានការកសាងអគារធំៗមានផ្សារទំនើប និងមានការរៀបចំរមណីយដ្ឋានធម្មជាតិជាច្រើនកន្លែងដែលទាក់ទាញភ្ញៀវទេសចរចូលមកទស្សនា។

## ១.១. ទិដ្ឋភាពទូទៅ

ដើម្បីអោយមានភាពងាយស្រួលដល់ការបកស្រាយ និងមានការងាយស្រួលយល់អំពីអត្ថន័យនៃប្រធានបទស្រាវជ្រាវខាងលើ នាងខ្ញុំទាំងពីរនាក់ សូមធ្វើការបង្ហាញនូវពាក្យគន្លឹះមួយចំនួនជាមុនសិន។ ពាក្យគន្លឹះទាំងនោះមានដូចជា ក្រុង សណ្តាប់ធ្នាប់ និងសោភ័ណភាព។

ក្រុង  សំដៅទៅលើទីកន្លែងមួយដែលមិនមានការធ្វើសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលអាចរួមបញ្ចូលគ្នាដែលមានដូចជាចំនួនប្រជាជន ទីផ្លាទំនេរ ដង់ស៊ីតេប្រជាជន និងចរន្តសេដ្ឋកិច្ច។ ដោយយោង

[១] គេហទំព័ររដ្ឋបាលខេត្តរតនគិរី https://www.ratanakiri.gov.kh/ ដកស្រង់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

តាមវចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យ ក្រុងនេះថាជា នគរ បុរី រាជធានី។

សណ្តាប់ធ្នាប់ សំដៅទៅលើធាតុទាំង៣ រួមមានសន្តិសុខ ភាពស្ងប់ស្ងៀម និងមិនមានការបំពុលទាំង៥។[២] ជារួមការរៀបចំក្រុងដើម្បីឱ្យមាន សណ្តាប់ធ្នាប់ និងសោភ័ណភាព គឺសំដៅដល់ការរៀបចំរាជធានី បុរី ដែលជាកន្លែងមួយមិនមានសកម្មភាពកសិកម្ម មានសន្តិសុខ មានភាពស្ងប់ស្ងៀម និងមិនមានបំពុលទឹក បំពុលដី បំពុលខ្យល់ បំពុលសំឡេង និងបំពុលដោយសំណល់រឹងរាវ។

សោភ័ណភាព សំដៅទៅលើភាពល្អហ្មត់ហ្មង។[៣] សោភ័ណភាពនេះមានពីរ គឺសោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់។ សោភ័ណភាពពេលថ្ងៃ គឺសំដៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមានដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ សំណង់អគារតូចធំ ទាំងរបស់រដ្ឋ និងរបស់ឯកជន ផ្លូវក្រោមដី ភ្លើងសញ្ញាចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ជាដើម។ ចំណែកឯសោភ័ណភាពពេលយប់ គឺសំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវក្នុងទីក្រុង តាមអគារនានា និងមានការរៀបចំដាក់ភ្លើងចម្រុះពណ៌នៅតាមដងផ្លូវក្នុងទីក្រុង ព្រមទាំងតាមសួនច្បារនានា តាមកន្លែងកម្សាន្តផ្សេងៗទៀត។

### **១.១.១. ទីតាំងភូមិសាស្ត្រ**

ខេត្តរតនគិរី គឺជាខេត្តស្ថិតនៅភាគឥសាននៃព្រះរាជាណាចក្រកម្ពុជាដែលមានចម្ងាយពីរាជធានីភ្នំពេញ ៥៨៨គីឡូម៉ែត្រ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ លេខ ៧ និង៧៨ ក្នុងការធ្វើដំណើរត្រូវចំណាយរយៈពេល៨ម៉ោង។ ខេត្តនេះមានព្រំប្រទល់ ខាងកើតជាប់នឹងខេត្តកន្ទូម និងខេត្តយ៉ាឡាយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងលិចជាប់ជាមួយនឹងខេត្តស្ទឹងត្រែង ហើយខាងជើងជាប់នឹងខេត្តអត្តពឺនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងចំណែកខាងត្បូងជាប់នឹងខេត្តមណ្ឌលគិរី។

នាពេលបច្ចុប្បន្ននេះខេត្តរតនគិរីមានផ្ទៃដីសរុបចំនួន ១០.៧៨២ គីឡូម៉ែត្រការ៉េ ហើយត្រូវបានបែងចែកដែនដីរដ្ឋបាលចំនួន ៨ស្រុក និងក្រុង១ សង្កាត់៤ ឃុំ៤៦ និងភូមិ២៤៣។ ខេត្តនេះមានទីតាំងស្ថិតនៅលើដីខ្ពង់រាបនៃភូមិភាគឥសានរបស់ប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតទឹកដីខ្ពង់រាបនេះជាគែមខាងលិចនៃប្រជុំភ្នំកន្ទូមនៃប្រទេសវៀតណាម។ យ៉ាងណាមិញខេត្តរតនគិរីមានក្រុងតែមួយដែលមានឈ្មោះថាក្រុងបានលុងដែលបានប្តូរពីស្រុកបានលុងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨។[៤] ដោយយោងតាមអនុក្រឹត្យស្តីពីការប្តូរស្រុកបានលុងទៅជាក្រុងបានលុងលេខ២២៧ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨។ ខេត្តរតនគិរី មានស្រុកចំនួន ៨ ក្រុង ១ សង្កាត់ ៤ ឃុំ ៤៦ និងភូមិ២៤៣ ដែលមានដូចខាងក្រោម៖

[២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១

[៣] វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត

[៤] អនុក្រឹត្យ ស្តីពីការផ្លាស់ប្តូរស្រុកបានលុង ទៅជាក្រុងបានលុង, លេខ២២៧ អនក្រ/បក, ៣០ ធ្នូ ២០០៩, មាត្រា១

តារាងចំនួនស្រុក ឃុំ ភូមិក្នុងខេត្តរតនគិរី

| ល.រ | ឈ្មោះស្រុក | ចំនួនឃុំ/សង្កាត់ | ចំនួនភូមិ |
|---|---|---|---|
| ១ | ក្រុងបានលុង | ៤ សង្កាត់ | ១៩ ភូមិ |
| ២ | ស្រុកអូរជុំ | ៧ ឃុំ | ៣៧ ភូមិ |
| ៣ | ស្រុកវើនសៃ | ៩ ឃុំ | ៣៤ ភូមិ |
| ៤ | ស្រុកបរកែវ | ៦ ឃុំ | ៣៤ ភូមិ |
| ៥ | ស្រុកលំផាត់ | ៦ ឃុំ | ២៦ ភូមិ |
| ៦ | ស្រុកកូនមុំ | ៦ ឃុំ | ២៣ ភូមិ |
| ៧ | ស្រុកអូរយ៉ាដាវ | ៧ ឃុំ | ២៩ ភូមិ |
| ៨ | ស្រុកអណ្តូងមាស | ៣ ឃុំ | ២១ ភូមិ |
| ៩ | ស្រុកតាវែង | ២ ឃុំ | ២០ ភូមិ |

#### ១.១.១.១. តំបន់ទេសចរណ៍

ធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលរួមមានដូចជា ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ជលផល ធនធានត្រូវបានអភិរក្ស អភិវឌ្ឍន៍ និង គ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។ តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជំរកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[៥] ទេសចរណ៍ ជាវិស័យមួយយ៉ាងសំខាន់ក្នុងការផ្តល់ចំណូលដល់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលនៅតាមរាជធានីខេត្តនានាដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារក៏ដូចគ្នា និងសង្គមជាតិដែលបានចាត់ទុកថាជាប្រភេទឧស្សាហកម្មគ្មានផ្សែង។ ខេត្តរតនគិរីជាតំបន់ដែលទាក់ទាញភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិឱ្យចូលមកទស្សនាខេត្តរតនគិរីដោយសារខេត្តនេះមានអាកាសធាតុល្អមិនត្រជាក់ពេកមិនក្តៅពេកម្យ៉ាងទៀតជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិបានបង្កឱ្យមានរមណីយដ្ឋានធម្មជាតិជាច្រើនបានដូចជា៖

- **ឧទ្យាជាតិវីរៈជ័យ** ជាតំបន់ទេសចរណ៍មួយដែលប្រកបទៅដោយទេសភាពស្រស់ស្អាតដោយមានព្រៃឈើធម្មជាតិជួរភ្នំខ្ពង់រាបជ្រលងភ្នំ និងដងអូរដែលអមដោយសហគមន៍ជនជាតិដើមភាគតិច និងសត្វព្រៃច្រើនប្រភេទកំពុងតែរង់ចាំការស្វាគមន៍អ្នកទេចរនៅឧទ្យានជាតិវីរៈជ័យ។ ម្យ៉ាងវិញទៀងឧទ្យានជាតិវីរៈជ័យគឺ

[៥] ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ១២៩៦.៣៦ នស.រកម, ២៤ ធ្នូ ១៩៩៦, មាត្រា៨

ត្រូវបានលាតសន្ធឹងលើផ្ទៃដី៣.៣២៥គីឡូម៉ែត្រការ៉េ ស្ថិតក្នុងស្រុកតាវែង និងស្រុកវើនសៃរបស់ខេត្តរតនគិរី ហើយបន្តភ្ជាប់នៅដល់ស្រុកសៀមប៉ាងខេត្តស្ទឹងត្រែង និងស្ថិតនៅចម្ងាយប្រហែល ៦០គីឡូម៉ែត្រពីខាងជើងក្រុងបានលុង ទីរួមខេត្តរតនគិរី។ នេះ គឺជាឧទ្យានដ៏ធំជាងគេដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក៏ធំជាងគេនៅក្នុងទូទាំងតំបន់រួមទាំងប្រទេសឡាវ និងវៀតណាម។ លើសពីនេះទៅទៀតឧទ្យានជាតិ មួយនេះត្រូវបានរាប់បញ្ចូលថាជាតំបន់អភិរក្សធំជាងគេនៅទ្វីបអាស៊ីផងដែរ។ នៅទីនេះមានជួរជ្រលងភ្នំតូច ធំហើយដើមឈើខ្លះដែលមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ វាលស្មៅ បក្សាបក្សីរាប់រយប្រភេទរាប់ទាំងសត្វអង្គត់ក.ស និងក.ខ្មៅ ត្រដក់ ត្រសេះ និងពពួកថនិកសត្វជាច្រើនប្រភេទទៀត។ ក្រុមអ្នកអភិរក្សឧទ្យាននេះ ក៏បានប្រទះឃើញនូវហ្វូងសត្វដំរី ខ្លាធំ និងអំបូរសត្វជាច្រើនប្រភេទទៀត រួមទាំងសត្វប្រភេទខ្លះកំពុងប្រកាសអាសន្នថាវានឹងឈានទៅដល់ការបាត់បង់នៅក្នុងលោកយើងនេះក៏មាន។

ភូមិភាគឥសានរបស់ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថាជាភូមិកំណើតនៃបងប្អូនជនជាតិដើមភាគតិចជាច្រើនអំបូរដែលបានរស់នៅទីនោះរាប់សតវត្សកន្លងមកហើយ ពួកគាត់បន្តការរស់នៅជាមួយនឹងការដាំដុះកសិផលជីវចម្រុះ។ មិនតែប៉ុណ្ណោះនៅក្នុងតំបន់នេះក៏មានបងប្អូនជនជាតិដើមភាគតិចព្រៅ និងកាវ៉ែត៤ទៅ៥សហគមន៍បានបន្តរស់នៅទៅតាមបែបប្រពៃណីទំនៀមទម្លាប់របស់ពួកគាត់ដោយពឹងផ្អែកលើអនុផលព្រៃឈើនៃឧទ្យានជាតិវីរៈជ័យ។ នាពេលបច្ចុប្បន្ននេះសហគមន៍ជនជាតិដើមភាគតិចទាំងនោះបានចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងកម្មវិធីអភិរក្សឧទ្យានជាតិដ៏ធំមួយនេះ។ ឧទ្យានជាតិនេះក៏ត្រូវបានគេទទួលស្គាល់ និងរាប់បញ្ចូលជាឧទ្យានជាតិនៃសម្បត្តិបេតិកភណ្ឌរបស់ប្រជាជាតិអាស៊ាន តាំងពីឆ្នាំ២០០៣។

- **បឹងយក្សឡោម** បឹងយក្សឡោមមានទីតាំងប្រមាណ៥គីឡូម៉ែត្រ ពីទីរួមខេត្តរតនគិរី។ បឹងដ៏ស្រស់ស្អាតនេះ មានទម្រង់ដោយសារភ្នំភ្លើង បន្ទាប់ពីបន្ទុះភ្នំភ្លើងមួយកាលពីប្រមាណ ៤.០០០ឆ្នាំកន្លងទៅ។ ការវាស់ជម្រៅបឹងនេះមានរហូតដល់ទៅ ៨០០ម៉ែត្រ និងបង្ហាញឱ្យឃើញទឹកថ្លាឈ្វេងជម្រៅប្រហែល ៥០ម៉ែត្រ។ នៅម្ខាងនៃបឹងមានកំពង់ផែដែលធ្វើពីឈើសម្រាប់ភ្ញៀវទេសចរទស្សនាបឹងឱ្យកាន់តែជិត។ ម្យ៉ាងទៀតផ្លូវជុំវិញបឹងផ្តល់នូវភាពរីករាយសម្រាប់ការដើរកម្សាន្តយឺតៗ ហើយនៅភាគខាងលិចបឹង ក៏មានមណ្ឌលមួយសម្រាប់ភ្ញៀវដែលមានតាំង និងលក់សិប្បកម្មក្នុងស្រុក ដូចជាឧបករណ៍តន្ត្រី ស្នា កន្ត្រក កន្ត្រៃងបង់ក និងកាបូបយួរដៃ ដែលធ្វើពីក្រណាត់ត្បាញដោយដៃរបស់ជនជាតិដើមភាគតិចតាមជាតិសាសន៍របស់ពួកគេ ។
- **ទឹកជ្រោះចាអ៊ុង** ជាទឹកជ្រោះចាអ៊ុងហូរធ្លាក់ពីលើភ្នំស្វាយដែលនៅជិតក្រុងបានលុង។ ទឹកជ្រោះនេះមានកម្ពស់២៥ម៉ែត្រ និងព័ទ្ធជុំវិញដោយវល្លិ និងរុក្ខជាតិដុះឡើងជាច្រើន។ ទេសភាពយ៉ាងស្រស់ស្អាតដែលធ្វើឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងនោះ គឺផ្សែងទឹកបង្កើតដោយទឹកធ្លាក់បុកជាមួយព្រៃឈើបង្កើតជាឥន្ទធនូ។ សព្វថ្ងៃនេះគេបានធ្វើជណ្តើរ ដើម្បីឱ្យភ្ញៀវទេសចរអាចងាយស្រួលចុះពីកំពូលភ្នំទៅដល់បាតជ្រោះតែម្តងនៅ

ទឹកជ្រោះក៏មានកន្លែងលក់ចំណីអាហារ ភេសជ្ជៈ អាហារញ៉ាំកម្សាន្ត និងវត្ថុអនុស្សាវរីយ៍ក្នុងស្រុកមួយចំនួនទៀត ហើយនៅក្រោយទឹកជ្រោះ គឺជារូងថ្មមួយយ៉ាងធំដែលភ្ញៀវទេសចរអាចទទួលបានការទស្សនាទេសភាពតាមរយៈផ្ទៃទឹក។

- **ទឹកជ្រោះកាចាញ** ស្ថិតនៅក្នុងភូមិ២ សង្កាត់កាចាញ ក្រុងបានលុង មានចម្ងាយប្រមាណ ៦គីឡូម៉ែត្រពីក្រុងបានលុង ហើយជារមណីយដ្ឋានធម្មជាតិដ៏ស្រស់ត្រកាលមួយទាក់ទាញភ្នែកភ្ញៀវទេសចរ ឱ្យទៅទស្សនានៅទីនោះ។ ទឹកធ្លាក់នេះស្ថិតនៅចំកណ្ដាលព្រៃភ្នំភ្ជាប់ដោយអូរ និងចំការកៅស៊ូនៅតាមដងផ្លូវធ្វើដំណើរទៅកាន់ទីនោះ។ ដើម្បីគយគន់សម្រស់ដ៏ស្រស់ត្រកាលនៃទឹកធ្លាក់នេះឱ្យកាន់ប្លែកអារម្មណ៍នោះ គឺភ្ញៀវទេសចរទាំងអស់ត្រូវចុះតាមជណ្ដើរឈើប្រមាណជាង ៧២កាំទៅក្រោម ឬដើរកម្សាន្តលេងតាមស្ពានយោលដែលលាតសន្ធឹងនៅពីមុខចរន្តទឹកធ្លាក់។ នៅខាងក្រោមនេះមានដើមឈើធំៗដែលអាចផ្ដល់ជាម្លប់ដល់ការសម្រាកលេង ឬហូបចុកចំណីអាហារព្រមទាំងមានលក់វត្ថុអនុស្សាវរីយ៍ផ្សេងៗ។
- **ទឹកជ្រោះកាទៀង** ទឹកជ្រោះកាទៀងមានទីតាំងស្ថិតនៅក្នុងភូមិកាទៀងឃុំល្បាំង២ ស្រុកលំផាត់ មានចម្ងាយប្រមាណ ៩គីឡូម៉ែត្រពីក្រុងបានលុង ខេត្តរតនគិរី ហើយទឹកជ្រោះកាទៀងនេះវាស្ថិតនៅកណ្ដាលព្រៃមានដើមឈើធំៗដែលអាចផ្ដល់ជាម្លប់យ៉ាងត្រជាក់ត្រឈឹងត្រឈៃដល់អ្នកទេសចរទាំងឡាយ។ម្យ៉ាងវិញទៀតដើម្បីគយគន់ទេសភាព ដ៏ស្រស់ត្រកាលនៃទឹកធ្លាក់នេះឱ្យកាន់តែប្លែក គឺយើងត្រូវចុះទៅតាមជណ្ដើរឈើជាច្រើនកាំទៅក្រោមហើយនៅខាងក្រោយខ្សែទឹកធ្លាក់នោះមានរូងថ្មយ៉ាងធំអាចឱ្យភ្ញៀវចូលទៅក្នុងបានហើយអាចមើលឃើញទេសភាពល្អៗប្លែកៗពីធម្មជាតិកាត់តាមខ្សែទឹក។ ចំណែកឯនៅខាងលើក្បែរទឹកធ្លាក់នោះមានកន្លែងជិះដំរីសម្រាប់ការដើរកម្សាន្តតាមព្រៃជុំវិញទីនោះ។ នៅទីនោះមានផលិតផល ផលិតចេញពីដៃរបស់ជនជាតិដើមគ្រឹងជាច្រើនមុខដាក់តាំងលក់ដូចជា ឃ្លោក ស្នា គង ក្រណាត់ ប៉ឹង សំពត់តាមបែបប្រពៃណីជនជាតិដើមភាគតិច។
- **ទឹកជ្រោះអូរស៊ិនលែរ៍** ទឹកជ្រោះអូរស៊ិនលែរ៍ ស្ថិតនៅក្នុងភូមិសាស្ត្រទឹកដី ស្រុកលំផាត់ មានចម្ងាយប្រមាណ ៣០គីឡូម៉ែត្រពីក្រុងបានលុង។ នៅទីនោះ គឺជារមណីយដ្ឋានទេសចរណ៍ធម្មជាតិដ៏ស្រស់បំព្រងមួយដែលតែងតែផ្ដល់នូវភាពសប្បាយរីករាយជក់ចិត្តជិតអារម្មណ៍ដល់អ្នកទេសចរគ្រប់ៗរូប។ រមណីយដ្ឋាននេះត្រូវគ្របដណ្ដប់ដោយព្រៃស្រោងពណ៌បៃតងដែលហ៊ុមព័ទ្ធជិតដោយ ជួរភ្នំនិងខ្ពង់រាបប្រកបដោយភាពសុខដុមរមនាពីធម្មជាតិសម្រាប់សត្វព្រៃ គ្រប់ប្រភេទ និងឮតែសំឡេងខ្សៀវខ្សារនៃសត្វបក្សាបក្សី ហើយទឹកធ្លាក់នោះមាន៧ជាន់ដែលទស្សនីយភាពដ៏ស្រស់ស្អាតនេះស្ថិតនៅកណ្ដាលព្រៃ និងមានការអភិរក្សថែរក្សាយ៉ាងល្អ ហើយកន្លែងខ្លះសូម្បីតែពន្លឺព្រះអាទិត្យក៏ពិបាកនឹងចាំងកាំរស្មីចូលដល់ផង។ ចំណែកនៅដេរប្រាំងចរន្តទឹកហូរមានសភាពយឺត

ល្អមដែលអាចឱ្យយើងហែលលេងបាន។ រីឯនៅរដូវភ្លៀងចរន្តទឹកហូរខ្លាំងលឿនកួចខ្វួលខ្វាញ់ និងធ្វើឱ្យពិបាកក្នុងការមុជកម្សាន្តណាស់។

- **បឹងលំកុដ** ជាបឹងធម្មជាតិដែលមាត់បឹងនេះមានសណ្ឋានដូចរូបបេះដូងមនុស្ស។ បឹងនេះមានទំហំ ២៥ហិកតា មានជម្រៅប្រមាណជា៦០ម៉ែត្រហើយមានលក្ខណៈអេកូឡូស៊ីដូច បឹងយក្សឡោម វាកើតឡើងពីបន្ទុះភ្នំភ្លើងកាលពីសម័យដើមដូចគ្នា។ បឹងនេះស្ថិតនៅលើតំបន់ខ្ពង់រាប និងជួរភ្នំដែលគ្របដណ្តប់ទៅដោយព្រៃត្រូពិចពណ៌បៃតងជានិច្ច បឹងលំកុដមានដើមឈើទ្រេតជាច្រើន ហាក់បីដូចជាចង់ដួលរលំទៅលើ ផ្ទៃទឹកបឹងដ៏ថ្លាពណ៌ខៀវស្រងាត់។ ហ៊ុមទ័ព្វជុំវិញ ដោយដុំថ្មក្រោមម្លប់នៃដើមឈើធំៗបឹងដែលកើតឡើងពីបន្ទុះភ្នំភ្លើងបុរាណនេះបានផ្តល់ជាសំបុកមច្ឆជាតិ តូច ធំជាច្រើនប្រភេទរស់នៅដែលឆ្ងាយបន្តិចពីមាត់បឹងលំកុដ គឺជាកន្លែងរស់នៅដ៏សុខសាន្តរបស់ជនជាតិដើមភាគតិចទំពួន និងជនជាតិឡាវ។ ប្រជាពលរដ្ឋដែលរស់នៅទីនោះ គឺជាកសិករដែលមានជីវភាពរស់នៅពឹងផ្អែកទៅលើ ដំណាំដាំដុះចម្ការស្រែ និងអនុផលព្រៃឈើ។ បឹងនេះស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំសេដា ស្រុកលំផាត់ដែលអ្នកទេសចរអាចទៅកាន់ទីនោះតាមផ្លូវជាតិលេខ៧៨A មានចម្ងាយប្រហែល ៥៤គីឡូម៉ែត្រ ពីក្រុងបានលុង។ មកទល់នឹងពេលនេះមិនទាន់មានអ្នកលក់ដូរអ្វីឡើយសូម្បីតែលក់ភេសជ្ជៈ ឬក៏អាហារនៅទីនោះក៏ពុំមានដែរ ។
- **ទឹកជ្រោះតាតៃ** គឺជាទីកន្លែងដែលមានល្បាក់ទឹកជ្រោះហូរជ្រែកតាមចន្លោះថ្មដា ស្រស់ត្រកាលស្ថិតនៅតាមបណ្តោយទន្លេស្រែពក ក្នុង ឃុំជ័យឧត្តម ស្រុកលំផាត់ដែលមានចម្ងាយប្រហែល ៣៤គីឡូម៉ែត្រពីខាងត្បូងនៃក្រុងបានលុង។ ទឹកជ្រោះតាតៃតែងតែ បង្ហាញភាពទាក់ទាញរបស់ខ្លួននៅ រដូវប្រាំងចាប់ពីខែកុម្ភៈដល់ខែមេសា។ ដោយមានបណ្តោយ ២ទៅ៣គីឡូម៉ែត្រ ល្បាក់ទឹកជ្រោះតាតៃ ក៏ផ្តល់ជាកន្លែងដ៏ប្រសើរមួយសម្រាប់ការស្ងួចត្រីលេងកម្សាន្តនៅត្រង់ចំណុចស្ងាត់ៗខ្លះ។ បើឆ្លងទៅត្រើយម្ខាងនៃទន្លេស្រែពក និងកន្លែងទឹកជ្រោះទីនោះគឺជាសហគមន៍ដ៏ធំរបស់បងប្អូនជនជាតិឡាវ និងខ្មែររស់នៅយ៉ាងសុខដុមរមនា។[៦] ជាក់ស្តែងទឹកជ្រោះតាតៃនេះនៅពេលរដូវប្រាំងទឹកមានសណ្ឋានរាក់ដែលបង្កឱ្យមានភាពងាយស្រួលក្នុងការលេងកម្សាន្ត ចំណែកឯនៅរដូវវស្សាវិញទឹកធំហើយល្បឿននៃការហូរក៏ខ្លាំងដែលពិបាកក្នុងការលេង និងអាចបង្កអោយមានគ្រោះថ្នាក់។ ពេលមានបុណ្យទានតែងតែមានអ្នកលក់ភេសជ្ជៈផ្សេងៗ ហើយផ្លូវសម្រាប់ការធ្វើដំណើរក៏មានភាពងាយស្រួលដែរ។

### ១.១.១.២. តំបន់បង្កបង្កើនផល

ខេត្តរតនគិរីមិនត្រឹមតែជាកន្លែងទេសចរណ៍យ៉ាងសំខាន់នោះទេតែក៏ជាទីកន្លែងប្រមូលផលិតផលកសិកម្ម សម្រាប់ផ្គត់ផ្គង់នៅក្នុងតំបន់ និងនាំចេញទៅខាងក្រៅផងដែរព្រោះតែខេត្តមានដីក្រួសក្រហមមានជីវជាតិដែលអំណោយផលសម្រាប់វិស័យកសិកម្ម។

[៦] គេហទំព័ររដ្ឋបាលខេត្តរតនគិរី https://www.ratanakiri.gov.kh/ ដកស្រង់នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

- **ដំណាំស្រូវ** ជាដំណាំដែលប្រើប្រាស់ពេលវេលា និងឆ្លងកាត់ជាច្រើនដំណាក់កាល ដើម្បីសម្រេចបានចេញជាគ្រាប់ស្រូវ ហើយយកមកកិនជាអង្ករ សម្រាប់ផ្គត់ផ្គង់នៅលើទីផ្សារ ហើយដំណាំស្រូវនេះគេដាំចែកចេញជា២រដូវ គឺរដូវប្រាំង និងរដូវវស្សា។ ខេត្តរតនគិរីជាខេត្តដែលពឹងផ្អែកលើវិស័យកសិកម្ម ៨២ភាគរយដែលមានសក្តានុពលខ្ពស់លើការដាំដំណាំកសិ-ឧស្សាហកម្ម និងការចិញ្ចឹមសត្វជាជាលក្ខណៈគ្រួសារ និងបែបប្រពៃណី។[៧] នោះឃើញថាគ្រប់ទាំង៨ស្រុកភាគច្រើន គឺធ្វើចំការដាំស្រូវតាមជ្រលងភ្នំជាលក្ខណៈជាចំការវិលជុំរបស់បងប្អូនជនជាតិដើមភាគតិច។
- **ដំណាំកៅស៊ូ** នៅក្នុងខេត្តរតនគិរីមានការដាំដំណាំក្រៅស៊ូ ជាលក្ខណៈគ្រួសារ និងមានការវិនិយោគពីក្រុមហ៊ុនឯកជនមានក្រុមហ៊ុនវិនិយោគចំនួន២៧ ដែលកំពុងប្រតិបត្តិការរបស់ខ្លួនស្របទៅតាមកិច្ចសន្យាដោយផ្តោតសំខាន់ទៅលើការដាំដុះដំណាំកសិ-ឧស្សហកម្មដែលក្រុមហ៊ុនទាំងនេះបានផ្តល់នូវការងារជាច្រើនសម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់។ សូមបញ្ជាក់ថាក្រុមហ៊ុនភាគហ៊ុនកៅស៊ូ ក្រុងប៊ុកមានក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺក្រុមហ៊ុនក្រុងប៊ុករតនគិរីអភិវឌ្ឍន៍កៅស៊ូដែលឈរជើងវិនិយោគនៅក្នុងខេត្តរតនគិរីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីកៅស៊ូសរុបចំនួន ៥.៦២១ គឺស្រុកតាវែង និងស្រុកអណ្តូងមាស។[៨]
- **ដំណាំស្វាយចន្ទី** គឺជាដំណាំយុទ្ធសាស្ត្រដែលរាជរដ្ឋាភិបាល បាននឹងកំពុងយកចិត្តទុកដាក់ និងជំរុញការនាំចេញឱ្យបានច្រើនជាងគេនៅលើពិភពលោកនាំចេញគ្រាប់ស្វាយចន្ទីនាពេលខាងមុខស្របពេលដែលរាជរដ្ឋាភិបាលទើបតែបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីស្វាយចន្ទីដែលជាផែនទី ចង្អុលផ្លូវផ្តោតទៅលើគោលដៅយុទ្ធសាស្ត្រធំៗដូចជា បង្កើនការដាំដុះផលិត កែច្នៃ និងនាំចេញនូវគ្រាប់ស្វាយចន្ទីទៅទីផ្សារអន្តរជាតិឱ្យបានកាន់តែច្រើន។ ជាក់ស្តែងខេត្តរតនគិរីជាខេត្តដែលមានដីក្រួសក្រហមមានជីវជាតិសម្រាប់ដាំដុះហេតុនេះប្រជាជនដែលរស់នៅខេត្តរតនគិរីភាគច្រើនបានដាំដើមស្វាយចន្ទីស្ទើរគ្រប់ទីកន្លែងហើយក៏ទទួលបានផលយ៉ាងប្រសើរផងដែរ។ ក្រៅពីដំណាំស្រូវ ដំណាំកៅស៊ូ ដំណាំស្វាយចន្ទី ខេត្តរតនគិរី សម្បូរទៅដោយដំណាំផ្សេងៗជាច្រើនដូចជា ម្រេច ធូរេន ចេកអំបូងលឿង ផ្លែប៉័រ ដំឡូងមី តាង៉ែន មៀន ក្រូច ម្នាស់...។

### ១.១.២. ដង់ស៊ីតេប្រជាជន

ខេត្តរតនគិរី គឺជាខេត្តមួយដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅតំបន់ខ្ពង់រាបដែលឆ្ងាយពីរាជធានីភ្នំពេញជាងគេបើប្រៀបជាមួយខេត្តផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជា។ រីឯប្រជាជនដែលរស់នៅក្នុងខេត្តរតនគិរីមានចំនួនសរុប ២១២.៤៥៣នាក់ស្រីចំនួន ១០៩.៤៧៥ នាក់ គ្រួសារសរុបចំនួន ៤៦.០៨៣ គ្រួសារ ពលរដ្ឋមានអាយុ១៨ឆ្នាំឡើងមានចំនួន ១០១.៣៩០នាក់មានដង់ស៊ីតេប្រជាជន ១៨ នាក់នៅក្នុងមួយគីឡូម៉ែត្រការ៉េ

---

[៧] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews.html ដកស្រង់នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

[៨] គេហទំព័រក្រសួងព័ត៌មាន https://www.information.gov.kh/ ដកស្រង់នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

(ស្ថិតិឆ្នាំ២០១៨) អត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន៣,៣%។[៩]ប្រជាជនដែលរស់នៅក្នុងខេត្តរតនគិរី គឺមានចម្រុះជាតិសាសន៍ដែលភាគច្រើនជាជនជាតិដើមភាគតិចមានប្រមាណជាង៦០% នៃប្រជាពលរដ្ឋសរុបចំនួន៨ជនជាតិរួមមាន ជនជាតិទំពួន កាចក់ កាវែត លន់ ព្រៅ ចារ៉ាយ ព្នង និងគ្រឹង។[១០] បងប្អូនជនជាតិដើមភាគតិចពួកគាត់ប្រកបរបរចិញ្ចឹមជីវិតដោយអនុផលព្រៃឈើ ការដាំដុះបន្លែផ្លែឈើ ការចិញ្ចឹមសត្វ ព្រមទាំងការធ្វើចម្ការវិលជុំ និងមានប្រជាពលពលរដ្ឋមួយចំនួនប្រកបមុខរបរលក់ដូរផងដែរ។

- **កសិកម្ម** បច្ចុប្បន្ននេះវិស័យកសិកម្ម ជាចំណែកមួយរួមផ្សំយ៉ាងសំខាន់ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋ។ ខេត្តរតនគិរីមានប្រជាជនមួយចំនួនធំជាកសិករដែលធ្វើកសិកម្ម ដើម្បីជួយផ្គត់ផ្គង់លើជីវភាពរបស់ពួកគេក៏ដូចជាការនាំចេញផងដែរតែក្នុងនោះមានការធ្វើចម្ការវិលជុំដោយពឹងផ្អែកទៅលើអាកាសធាតុតាមរដូវកាលដែលមានការខុសប្លែកពីខេត្តមួយចំនួន ដែលធ្វើកសិកម្ម ដោយការធ្វើស្រែ។ ក្រៅពីការដាំស្រូវ មានការដាំស្វាយចន្ទី ម្រេច កៅស៊ូព្រមទាំងផ្លែឈើហូបផ្លែជាច្រើន និងការចិញ្ចឹមសត្វដោយមានគ្រួសារខ្លះបានចាប់ផ្តើមប្រើប្រាស់បច្ចេកទេទំនើបៗក្នុងការធ្វើកសិកម្មដូចជា ការប្រើអាត្រាក់ទ័រក្នុងការភ្ជួរដីប្រើប្រាស់ថ្នាំបំប៉នដំណាំជាដើម។
- **អាជីវកម្ម** ប្រជាពលរដ្ឋក្នុងខេត្តរតនគិរីក៏មានការ ប្រកបអាជីវកម្មដែលមានដូចជា ការទិញ លក់ទំនិញកសិផល មានការទិញលក់គ្រឿងឧបភោគបរិភោគ លក់សម្លៀកបំពាក់ លក់គ្រឿងអេឡិចត្រូនិច ប្រេងឥន្ធនៈហាងលក់បរិក្ខាសំណង់ លក់មាស និងលក់ត្បូងធម្មជាតិ។ ចំណែកឯសិប្បកម្មសំខាន់ៗនៅក្នុងខេត្តមានដូចជាសិប្បកម្មផលិតទឹកសុទ្ធ សិប្បកម្មផលិតទឹកកក សិប្បកម្មផលិតនំប័ង សិប្បកម្មផលិតគ្រឿងសង្ហារឹម។ រីឯផ្នែកខាងជាងជួសជុលក្នុងខេត្តមានដូចជា ជាងជួសជុលរថយន្ត ជួសជុលម៉ូតូ ជួសជុលទូរស័ព្ទ ម៉ាញ៉េ ទូរទស្សន៍ជួសជុលនាឡិកាជាដើម។ យ៉ាងណាមិញចំពោះប្រជាជនដែលរស់នៅក្នុងខេត្តរតនគិរី ក្រៅពីការប្រកបរបរកសិកម្ម ធ្វើស្រូវក៏មានការចិញ្ចឹមសត្វ និងការដាំដំណាំរយៈពេលវែងដូចជា គោ ក្របី ជ្រូក មាន់ ទា និងត្រី តាមលក្ខណៈគ្រួសារ និងមានចម្ការបន្លែជាដើម។

## ១.២. សមត្ថកិច្ចដែលពាក់ព័ន្ធនឹងការរៀបចំខេត្ត

ការរៀបចំខេត្ត ក្រុងមួយដែលប្រកបទៅដោយសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងសោភ័ណភាពល្អចាំបាច់ណាស់ត្រូវតែមានការធ្វើគម្រោងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឱ្យបានត្រឹមត្រូវជាមុនសិនទើបការអនុវត្តនោះមានសុពលភាពល្អ។ ចំពោះផែនការអភិវឌ្ឍន៍ រយៈពេលប្រាំឆ្នាំដែលជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដែលប្រើប្រាស់សម្រាប់កំណត់បញ្ហាប្រឈមផ្សេងៗ និងកំណត់តម្រូវការដែល

[៩] ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

[១០] គេហទំព័ររដ្ឋបាលខេត្តរតនគិរី https://www.ratanakiri.gov.kh/ ដកស្រង់នៅថ្ងៃទី១៨ ឧសភា ឆ្នាំ២០២៣

ជាអាទិភាពរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាដែលកំពុងប្រឈម ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ស្រុក ខណ្ឌ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។[១១]

**១.២.១. សមាសភាព**

សមត្ថកិច្ចយ៉ាងសំខាន់ដែលពាក់ព័ន្ធនឹងការរៀបចំខេត្ត គឺរដ្ឋបាលខេត្តដែលក្នុងនោះមានក្រុមប្រឹក្សាខេត្ត និងគណៈអភិបាល ក្រុមប្រឹក្សាខេត្តរតនគិរី មានអង្គភាពក្រោមឱវាទជាច្រើនដែលធ្វើការរួមគ្នាក្នុងគោលបំណងតែមួយក្នុងការរៀបចំឱ្យខេត្តមានសោភ័ណភាព ស្រស់ស្អាត មានសុវត្ថិភាព មានបរិស្ថានស្អាត ព្រមទាំងមានផាសុកភាពក្នុងការរស់នៅ។ ខាងក្រោមនេះជារចនាសម្ព័ន្ធរដ្ឋបាលខេត្តរតនគិរីមានដូចខាងក្រោម៖

**ក. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានសមាសភាពដូចជា៖

- អភិបាលជាប្រធាន
- ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា
- ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- ប្រធានមន្ទីរ អង្គភាពនៃក្រសួងស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- តំណាងផ្សេងៗទៀតតាមការចាំបាច់។

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវខិតខំធានាឱ្យបានថាផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួងស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាលដែលបានផ្តល់សេវាសម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដែលត្រូវបានដាក់បញ្ចូលត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំកម្មវិធីវិនិយោគបីឆ្នាំរំកិល ប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅ គណៈកម្មាធិការសម្រាប់សម្របសម្រួលបច្ចេកទេសត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[១២]

- អនុគណៈកម្មាធិការសេដ្ឋកិច្ច និងអនុគណៈកម្មាធិការសង្គមកិច្ច។

---

[១១] ប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ស្រុក ខណ្ឌ, ប្រការ២

[១២] ច្បាប់វិសោធនកម្ម ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៤ មករា ២០១៩, មាត្រា១២៣-១២៤

### ខ. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវជ្រើសរើសចេញពីចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះ ឬស្ត្រី និងបុរសនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិដូចខាងក្រោម៖

- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល។
- មានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូន ក្រុមប្រឹក្សាគណៈអភិបាល អភិបាល គណៈកម្មាធិការដទៃទៀត របស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធ និងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារ ដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា។
- មានសិទ្ធិទទួលបាននូវរបៀបវារៈប្រជុំ និងឯកសារសម្រាប់កិច្ចប្រជុំដូចសមាជិកអង្គប្រជុំដទៃទៀត។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចចាត់តាំងសមាជិករបស់ខ្លួនបានយ៉ាងច្រើនពីររូបដើម្បីចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈអភិបាល និងកិច្ចប្រជុំនៃគណៈកម្មាធិការនានា របស់ក្រុមប្រឹក្សាហើយសមាជិកដែលត្រូវបានចាត់តាំងទាំងនេះមានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ របាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលនូវស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងស្ថានភាពរបស់កុមារដែលនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ សមិទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី កុមារ និងអនុសាសន៍ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី កុមារ ព្រមទាំងអនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។[១៣]

### គ. គណៈអភិបាលខេត្ត

នៅក្នុងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌត្រូវរៀបចំឱ្យមានគណៈអភិបាល រួមមានប្រធានមួយរូបហើយជាអភិបាល និងអភិបាលរងមួយចំនួនទៀត។ អភិបាលរាជធានីខេត្តត្រូវតែងតាំងដោយព្រះរាជក្រឹត្យទៅតាមសំណើរបស់នាយករដ្ឋមន្ត្រីតាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយគណៈអភិបាលខេត្តមានចំនួន ៣រូបទៅ៧រូប។

[១៣] ច្បាប់វិសោធនកម្ម ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៤ មករា ២០១៩, មាត្រា១២៧-១៣០-១៣៤

- **នាយករដ្ឋបាលខេត្ត**

ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តត្រូវមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើរពីអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។ នាយករដ្ឋបាលខេត្តត្រូវមាននាយករងរដ្ឋបាលពីររូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋបាលខេត្តបានតែងតាំងឡើងពីក្នុងចំណោម មន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តិចាប់ពី អនុមន្ត្រីនៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

- **ទីចាត់ការ**

ទីចាត់ការនីមួយៗត្រូវស្ថិតក្រោមការទទួលខុសត្រូវការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការ ហើយត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាខេត្ត។ ទីចាត់ការនីមួយៗត្រូវមាននាយកទីចាត់ការមួយរូប និងនាយករងទីចាត់ការ យ៉ាងច្រើនពីររូបជាជំនួយការ។ ទីចាត់ការនីមួយៗមានភារកិច្ចសំខាន់ៗដូចខាងក្រោមះ

- **ទីចាត់ការរដ្ឋបាល**

នៅក្នុងទីចាត់ការរដ្ឋបាលត្រូវទទួលខុសត្រូវរាល់ភារកិច្ចមួយចំនួនមានដូចជា លិខិតស្នាម តម្កល់ឯកសារ និងការធ្វើនីត្យានុកូលកម្មលើឯកសារផ្សេងៗ  ការគ្រប់គ្រង ថែរក្សាត្រារបស់រដ្ឋបាលខេត្ត និងទំនាក់ទំនងជាមួយសាធារណជនដែលទាក់ទងមកសាលាខេត្ត ការរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងការបិទផ្សាយព័ត៌មានលើកក្តារព័ត៌មានសាធារណៈ។ ការគ្រប់គ្រងស្ថិតិ ទិន្នន័យរបស់ប្រជាពលរដ្ឋ ការងារអត្រានុកូលដ្ឋាន ការងារពិធីការ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រការងារលេខាធិការដ្ឋានដល់ក្រុមប្រឹក្សាខេត្ត។

- **ទីចាត់ការផែនការ និងវិនិយោគ**

សម្រាប់ទីចាត់ការផែនការ និងវិនិយោគត្រូវរៀបចំផែនការមួយចំនួនមាន ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលប្រចាំឆ្នាំ ការគ្រប់គ្រងកិច្ចសន្យា ឬអនុវត្តគម្រោងដែលបានចុះកិច្ចសន្យាជាមួយរដ្ឋបាលខេត្តគាំទ្រធនធានផ្នែករដ្ឋបាល និងសមត្ថភាពផ្នែករដ្ឋបាល។  សហការគ្នាធ្វើគម្រោងរៀបចំប្លង់ប៉ាន់ស្មានតម្លៃ រៀបចំសំណើគម្រោងសម្រាប់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ខេត្ត គាំទ្របច្ចេកទេសដល់ក្រុង ស្រុក ឃុំ  និងសង្កាត់លើការងារទាំងនេះ និងការធ្វើសហប្រតិបត្តិការ ការគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក ឃុំ និងសង្កាត់ព្រមទាំងការគាំទ្រសមត្ថភាពចាំបាច់  ដល់ក្រុង ស្រុកឃុំ  និងសង្កាត់ក្នុងការអនុវត្តគម្រោងនានា។  ការពិនិត្យ ការផ្តល់យោបល់លើសំណើវិនិយោគ គម្រោង

អភិវឌ្ឍន៍របស់ផ្នែកឯកជន អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ច និងចងក្រងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធគម្រោងអភិវឌ្ឍន៍នានារបស់ខេត្ត ក្រុង ស្រុក ខណ្ឌ និងសង្កាត់។

- **ទីចាត់ការហិរញ្ញវត្ថុ**

ការរៀបចំសេចក្ដីព្រាងថវិកាប្រចាំឆ្នាំ រៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យមការងារហិរញ្ញវត្ថុ ថវិការបាយការណ៍ហិរញ្ញវត្ថុរបស់ខេត្ត និងការរៀបចំឱ្យមានការធ្វើសវនកម្មឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុការគ្រប់គ្រងចំណូលចំណាយ និងគណនេយ្យការគាំទ្រដល់ការងារហិរញ្ញវត្ថុក្រុង ស្រុក ឃុំ និងសង្កាត់ ហើយសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលាខេត្ត និងការងារលទ្ធកម្ម។

- **ទីចាត់ការគ្រប់គ្រងធនធានមនុស្ស**

ការងារក្របខ័ណ្ឌ ការងារគ្រប់គ្រងមន្ត្រីបុគ្គលិកដែលសិទ្ធិក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ផែនការប្រើប្រាស់ ជ្រើសរើសទីប្រឹក្សាបច្ចេកទេសបុគ្គលិកជាកិច្ចសន្យា ការផ្ដល់គ្រឿងឥស្សរិយយសមេដាយ  បណ្ណសរសើរដល់មន្ត្រីបុគ្គលិក និងសប្បុរសជននានា។ ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាព បណ្ដុះបណ្ដាលដល់មន្ត្រីបុគ្គលិក ការរៀបចំតួនាទីភារកិច្ច ល័ក្ខខ័ណ្ឌការងាររបស់មន្ត្រីបុគ្គលិក ការបង្កើត ការកែសម្រួល ការរំសាយពីចាត់ការ ការិយាល័យចំណុះសាលាខេត្ត។ ការកំណត់នីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រីបុគ្គលិក ការផ្សព្វផ្សាយតាមដានការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់លិខិតបទដ្ឋានគតិយុត្ត។

- **ទីចាត់ការអន្តរវិស័យ**

កិច្ចសហការ សម្របសម្រួលក្នុងការពិនិត្យ មើលឡើងវិញនូវមុខងារធនធាន និងការទទួលខុសត្រូវដើម្បីផ្ទេរមកឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់នៅក្នុងខេត្ត សម្រាប់សម្រួលក្នុងការប្រគល់ ការធ្វើប្រតិភូកម្មមុខងារ ធនធានដល់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់នៅក្នុងខេត្ត។ ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់ ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ការគោរពសិទ្ធិមនុស្ស និងយេនឌ័រ ការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត និងការដោះស្រាយវិវាទនៅមូលដ្ឋាន។[១៤]

[១៤] អនុក្រឹត្យ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៥៨

- **អង្គភាពលទ្ធកម្ម**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្មត្រូវបង្កើតអង្គភាពផលិតកម្មមួយដោយប្រកាស សេចក្តីសម្រេច ឬដីការដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកផលិតកម្មសាធារណៈគ្រប់គ្រាន់ព្រមទាំងមានសិទ្ធិអំណាចសមស្របដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ។ ម្យ៉ាងវិញទៀតអង្គភាពលទ្ធកម្មមានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់ និងជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម ហើយអង្គភាពលទ្ធកម្មត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានចំនួន ២រូបយ៉ាងច្រើនជាជំនួយការ។ ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាក្រសួងស្ថាប័នប្រធានអង្គភាពផលិតកម្មមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

- **អង្គភាពច្រកចេញចូលតែមួយ**

អង្គភាពច្រកចេញចូលតែមួយ ត្រូវបានបង្កើតឡើងនៅតាមខេត្តរាជធានីនីមួយៗក្នុងគោលបំណងសម្រាប់ការផ្តល់សេវាសាធារណៈជនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។ លើសពីនេះទៅទៀតអង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានយ៉ាងច្រើនពីរូបជាមួយការ។ ប្រធានអង្គភាពច្រកចេញចូលតែមួយមានឋានៈស្មើនាយកទីចាត់ការនៃរដ្ឋបាលរាជធានីខេត្ត អនុប្រធានច្រកចេញចូលតែមួយមានឋានៈស្មើ នាយករងទីចាត់ការនៅរដ្ឋបាលខេត្ត។[១៥]

- **ការិយាល័យប្រជាពលរដ្ឋ**

ការិយាល័យប្រជាពលរដ្ឋត្រូវបង្កើតឡើងសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនូវរដ្ឋបាលរាជធានីខេត្តមួយៗ។ ការិយាល័យនេះត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយរូបជាមួយការ។ ប្រធាន អនុប្រធាន ការិយាល័យប្រជាពលរដ្ឋ រាជធានីខេត្តត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានីខេត្ត ហើយត្រូវទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់អភិបាលរាជធានីខេត្ត ដោយផ្អែកតាមលទ្ធផលរបស់គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធាន។ ប្រធាន និងអនុប្រធានមិនអាចកាន់តំណែងផ្សេងទៀតក្នុងរាជរដ្ឋាភិបាលអង្គការសង្គមស៊ីវិល និងប្រកបមុខរបរវិជ្ជាជីវៈណាមួយ ឬមុខរបរផ្សេងទៀតដែលមានទំនាស់ផលប្រយោជន៍ និងមុខងាររបស់ខ្លួនឡើយ ព្រមទាំងមានអាណត្តិ ការងាររយៈពេល ៥ឆ្នាំ។[១៦]

---

[១៥] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត, លេខ៣៨៧១ ប្រក, ០៨ សីហា ២០១៧, ប្រការ៥

[១៦] អនុក្រឹត្យ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ១៩ អនក្រ.បក, ០៨ កុម្ភៈ ២០១៧, មាត្រា៣១

### ឃ. គណៈកម្មាធិការលទ្ធកម្ម

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រព្រឹត្តធ្វើឡើង ប្រកបដោយភាពស្មោះត្រង់បើកចំហ តម្លាភាព មិនលំអៀងដោយអនុលោមតាមច្បាប់បទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

### ង. គណៈកម្មាធិការនានា

ក្រុមប្រឹក្សាខេត្តត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួន ៣ ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌដែលរួមមាន៖

- គណៈកម្មាធិការសម្រាប់សម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ។



**១.២.១.១. ក្រុមប្រឹក្សាខេត្ត**

នៅក្នុងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង ដោយការការបោះឆ្នោតជាអសកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលគេហៅកាត់ថា ក្រុមប្រឹក្សា។[១៧] ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយ ការបោះឆ្នោតស្របតាមច្បាប់ ស្ដីពីការបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជា អ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ឱ្យប្រជាពលរដ្ឋទាំងអស់ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទូទៅក្រុមប្រឹក្សាមានអាណត្តិ ៥ឆ្នាំ និងត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ សមាសភាព ក្រុមប្រឹក្សាខេត្តរតនគិរីនៅអាណត្តិទី៣ មានចំនួន ១៩ រូបក្នុងនោះរួមមានមួយរូបជាប្រធានក្រុមប្រឹក្សាខេត្ត និង១៨រូបជាសមាជិកក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួន ៣ដែល តម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។
- គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។
- គណៈកម្មាធិការលទ្ធកម្ម។

**កាប្រជុំក្រុមប្រឹក្សាខេត្ត** គឺជាកិច្ចប្រជុំរបស់ប្រឹក្សាខេត្តដែលអាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះ ត្រូវបានប្រព្រឹត្តត្រឹមត្រូវតាមបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។ សេចក្ដីសម្រេចទាំងឡាយណាដែលធ្វើបាន ឡើងមិនស្របតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាមិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានាសេចក្ដីសម្រេចនោះពុំមានសុពលភាពឡើយ។ម្យ៉ាងវិញទៀតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំ ឬអាច ធ្វើសេចក្ដីអន្តរាគមន៍ក្នុងករណីចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្ដីសម្រេចដែលធ្វើឡើងមិនស្របច្បាប់ នោះឡើងវិញ។ ដោយយោងទៅតាមអនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក លេខ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ខែធ្នូ ឆ្នាំ២០០៩ មាត្រា៦ និងមាត្រា១១។

**១.២.១.២. គណៈអភិបាលខេត្ត**

នៅតាមបណ្ដាសាលាខេត្តនីមួយៗត្រូវតែមានគណៈអភិបាលខេត្តដែលក្នុងនោះរួមមានអភិបាលខេត្ត១ រូប និងអភិបាលរងខេត្តមួយចំនួនដែលត្រូវបានតែងតាំងដោយស្របតាមលក្ខខណ្ឌនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋ

[១៧] ច្បាប់វិសោធនកម្ម ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៤ មករា ២០១៩, មាត្រា១៤

បាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[១៨] រីឯចំណុចសំខាន់មួយទៀត គឺគណៈអភិបាលខេត្តមានចំនួន ៣រូបទៅ ៧រូប។ គួរបញ្ជាក់ផងដែរថាអភិបាលខេត្ត និងអភិបាលរងខេត្តមិនមែនជាសមាជិកក្រុមប្រឹក្សាខេត្តឡើយ។ អភិបាលខេត្ត ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិដូចជា៖

- មានឋានន្តរស័ក្តិចាប់ពីឧត្តមមន្ត្រីឡើងទៅ។
- មានអាយុចាប់ពី ៣៥ ឆ្នាំឡើងទៅគិតដល់ថ្ងៃតែងតាំង។
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ៧ឆ្នាំ។
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង។
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

ចំណែកឯអភិបាលរងខេត្ត ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិដូចជា៖

- មានឋានន្តរស័ក្តិចាប់ពីវរមន្ត្រីឡើងទៅ។
- មានអាយុចាប់ពី ៣៥ឆ្នាំឡើងទៅគិតដល់ថ្ងៃតែងតាំង ។
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ៥ឆ្នាំ។
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង។
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។[១៩]

**ការប្រជុំគណៈអភិបាល** ជាកិច្ចប្រជុំរវាងអភិបាលខេត្ត និងអភិបាលរងខេត្តនៅក្នុង គណៈអភិបាលរបស់ខ្លួន។ គណៈអភិបាលត្រូវជួបជុំជាទៀងទាត់ ប្រចាំពាក់កណ្តាលខែម្តង។ ក្រៅពីកិច្ចការប្រជុំពាក់កណ្តាលខែ និងការប្រជុំប្រចាំខែឃើញថាគណៈអភិបាលជួបប្រជុំតាមការចាំបាច់ ទៅតាមសំណើរអភិបាលខេត្ត រាល់កិច្ចប្រជុំរបស់គណៈអភិបាលអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានរបស់អភិបាលខេត្ត និងអភិបាលរងដែលលើសពីពាក់កណ្តាលសមាសភាពនៃគណៈអភិបាល។ សេចក្តីសម្រេចនៃកិច្ចប្រជុំគណៈអភិបាលអាចយកជាការបានលុះត្រាតែមានសំឡេងអនុម័ត លើសពីពាក់កណ្តាលនៃសមាសភាពគណៈអភិបាលទាំងមូល។ តួយ៉ាងអភិបាលខេត្តជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំហើយក្នុងករណីអភិបាលបានអវត្តមាន

[១៨] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា២៥

[១៩] ច្បាប់វិសោធនកម្ម ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៤ មករា ២០១៩, មាត្រា១៤២-១៤៣

អភិបាលស្តីទីជាអ្នកកោះហៅប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំរបស់គណៈអភិបាលត្រូវមានកំណត់ហេតុដែលរៀបចំឡើងដោយនាយករដ្ឋបាល និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្តដែលបានសម្រេច ឬដែលបានអនុវត្តកិច្ចការមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្តហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្តត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។[២០] ចំណែកក្នុងខេត្តរតនគិរី មានស្រុកចំនួន ៨ដែលក្នុងនោះមានក្រុងចំនួនមួយគឺក្រុងបាលុង មានគណៈអភិបាល ៤រូប ហើយស្រុកទាំង៨ មានគណៈអភិបាល ៣រូបក្នុងមួយស្រុក។

**១.២.២. តួនាទី និងភារកិច្ច**

ជាការពិតណាស់នៅក្នុងតំណែងនីមួយៗតែងតែមានភារកិច្ច និងតួនាទីដែលត្រូវបំពេញទៅតាមមុខងាររៀងៗខ្លួនដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងដំណើរការនៃការមិនអោយមានការកកស្ទះ។ ដូចដែលបានដឹងហើយថាដើម្បីរៀបចំខេត្តក្រុងមួយបានលុះត្រាតែមានការចូលរួមចាត់ចែងពីរដ្ឋបាលខេត្តក្រុងនីមួយៗដែលមានមុខងារភារកិច្ចដូចខាងក្រោម

**១.២.២.១. ក្រុមប្រឹក្សាខេត្ត**

តួនាទី និងភាកិច្ចរបស់ប្រធានក្រុមប្រឹក្សាខេត្ត មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលខេត្តនៅលើកំណត់ហេតុនឹងឯកសាដូចជា៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច។
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារក្រុមប្រឹក្សាខេត្ត។
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត។
- សំណើរដកអភិបាលខេត្ត ឬអភិបាលរងខេត្តចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត។
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តរយៈពេល ១២ខែ។
- សំណើរសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខេត្ត។

[២០] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៣២

- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដោយយោងតាមមាត្រា១៣ កថាខណ្ឌ១ នៃអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក ។

***ភារកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្តមានដូចជា៖***

- ណែនាំផ្នែកគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ខេត្ត។
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍខេត្ត។
- តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ខេត្តក្នុងករណីចាំបាច់។[២១]

***ការធ្វើការងាររបស់ក្រុមប្រឹក្សាខេត្ត*** ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួនក្រុមប្រឹក្សាខេត្តត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ពន្ធ័ និងរបៀបរបបអនុវត្តការងារដូចខាងក្រោម ក្រុមប្រឹក្សាខេត្តត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈនៃការសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សាខេត្តរបស់ខ្លួន និងត្រូវធានាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។[២២]

• ក្រុមប្រឹក្សាខេត្តអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ព្រមទាំងអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះគណៈអភិបាលខេត្តត្រូវដឹកនាំ នាយករដ្ឋបាលសាលាខេត្ត និងការិយាល័យពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់បច្ចេកទេសដែលគាំទ្រដទៃទៀត ដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

• សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួនមិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនោះពុំមានសុពលភាពឡើយ។

[២១] អនុក្រឹត្យ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ២១៩ អនក្រ.បក, ១៤ ធ្នូ ២០១៩, មាត្រា៦

[២២] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា១០

• ក្រុមប្រឹក្សា ខេត្តត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។[២៣]

• ក្នុងករណីកិច្ចណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់ អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួនក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវរៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត និងដើម្បីដោះស្រាយរាល់កិច្ចការទាំងនោះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់បែបបទនីតិវិធីដើម្បីដោះស្រាយកិច្ចការទាំងនេះ។

• ក្នុងករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនស្របទៅនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ដែលក្រុមប្រឹក្សាខេត្តមិនអាចអនុវត្តបាននោះ ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្ត ធ្វើសំណើមក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ តាមយន្តការគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ពាក់ព័ន្ធដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។[២៤]

**ការប្រជុំក្រុមប្រឹក្សាខេត្ត** រាល់កិច្ចប្រជុំរបស់ខ្លួនក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរដ្ឋបាលខេត្ត និងវិធានការបែបបទនីតិវិធីការចាត់ចែង ការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង៖

- ការរៀបចំ ដើម្បីទទួលបាន មុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- អនុវត្តការងារ ជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។
- ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំព្រមទាំងសមាសភាព នៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សា ប្រភេទក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នាក្រសួងស្ថាប័ន ឬមន្ទីរអង្គភាពរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា។

[២៣] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ២៩ មករា ២០០៩, មាត្រា១២ កថាខណ្ឌទី១-កថាខណ្ឌទី៤

[២៤] អនុក្រឹត្យ លេខ២១៦ អនក្រ.បក, មាត្រា១៦ កថាខណ្ឌទី២-កថាខណ្ឌទី៣

- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត។
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរួមទាំងការរៀបចំគណៈកម្មាធិការទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត។
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងគ្នាជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត។
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនដែលនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត។[២៥] ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើ គឺការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែង ក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ។ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន។
- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលខេត្ត។
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយដែលក្រុមប្រឹក្សាខេត្តយល់ថាមានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ។
- ការពិនិត្យស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្តតាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

---

[២៥] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា១៤

- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋាន ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលរៀបចំដោយគណៈអភិបាលខេត្ត។
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានា ដែលក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។[២៦]

### ១.២.២.២. គណៈអភិបាលខេត្ត

គណៈអភិបាលខេត្តមានភារកិច្ច និងតួនាទីចូលរួមប្រជុំក្រុមប្រឹក្សាខេត្ត និងត្រូវជួយក្រុមប្រឹក្សាខេត្តរបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារនោះសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកអភិបាលខេត្តឬអភិបាលរងខេត្តចេញពីមុខតំណែងតែប៉ុណ្ណោះ។[២៧]

**ភារកិច្ចរបស់គណៈអភិបាលក្នុងការកសាងផែនការអភិវឌ្ឍន៍មានដូចជា**

- ដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ស្របតាមការណែនាំរបស់ក្រុមប្រឹក្សាខេត្ត។
- ដឹកនាំសិក្ខាសាលាវេទិកាពិគ្រោះយោបល់នានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។
- ពិនិត្យ និងផ្តល់យោបល់ទៅលើ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ មុនដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត។
- ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត។
- ដាក់សំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ខេត្តជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត។
- ដឹកនាំ និងសម្របសម្រួលការធ្វើវិសោធនកម្ម ផែនការអភិវឌ្ឍន៍ខេត្ត។
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខេត្តតាមការណែនាំរបស់ក្រុមប្រឹក្សា។[២៨]

**គណៈអភិបាលខេត្តមានតួនាទី និងភារកិច្ចដូចជា**

គណៈអភិបាលខេត្តត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធ និងអំណាចបញ្ញត្តិ អំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

---

[២៦] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា១៥

[២៧] អនុក្រឹត្យ លេខ២១៦ អនក្រ.បក, មាត្រា១៣ កថាខណ្ឌទី២

[២៨] សេចក្តីណែនាំ បច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្ត

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឱ្យ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត និងរបៀបរបប នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ។
- រៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធធនធានទទួលយកមុខងារភារកិច្ច និងធនធាន ដែលបានប្រគល់ ឬបានផ្ទេរតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលប្រចាំឆ្នាំ។
- គម្រោងថវិកាប្រចាំឆ្នាំ។
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត។
- ការបង្កើតការកែសម្រួល ឬការរំសាយការិយាល័យនានា។
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក។
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត។
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាខេត្តគណៈអភិបាលខេត្ត និងបុគ្គលិក របស់ក្រុមប្រឹក្សាខេត្ត។
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័តមិនឱ្យលើសពី៤៥ថ្ងៃបន្ទាប់ពី ដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖
    - ដីកា សេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត សកម្មភាពលទ្ធផល នៃការអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុ។
    - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សា។
    - វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត។
    - វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។
    - កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខេត្តយល់ឃើញថាជាចាំបាច់ដែលត្រូវដាក់បញ្ចូលនៅ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។
- របាយការណ៍ប្រចាំខែត្រីមាស និងឆមាស។
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការ អនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត។
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន ដូចជាការរៀបចំក្តារព័ត៌មានការបិទ ផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយ ផ្សព្វផ្សាយព័ត៌មាននានាជូនទៅ ដែលប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។[២៩]
- នៅពេលទទួលបានរបាយការណ៍អំពីការរំលោភអំណាចដូចមានចែងក្នុង មាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើក្នុងករណីដែលរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែននោះគណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាខេត្ត ព្រមទាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[៣០]

**ក្នុងតួនាទីជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច**

- ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងខេត្តអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្ត។
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខេត្តក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងខេត្ត ដើម្បីធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត។
- ណែនាំដល់មន្ទីរ អង្គភាពនានា និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្តឱ្យអនុវត្តតួនាទី និងភារៈកិច្ចខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព ទីភ្នាក់ងារនីមួយៗនោះ។
- សម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្តក្នុងការឆ្លើយតបតម្រូវការជាមូលដ្ឋាន។ ក្នុងករណីដែលមានកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យអភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះដោយពឹងផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពនៅមូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្រាប់សម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ

[២៩] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា២៩

[៣០] អនុក្រឹត្យ លេខ២១៦ អនក្រ.បក, មាត្រា៣០

អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្តក្នុងការធ្វើសមាហរណកម្មផែនការថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាខេត្ត។

- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុនសិនក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរអង្គភាពរបស់ក្រសួងស្ថាប័ននានាប្រចាំនៅខេត្ត។ ក្នុងករណីការមិនគាំទ្របេក្ខភាពណាម្នាក់ដែលបានស្នើតែងតាំងខាងលើនេះ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលការមិនគាំទ្រនេះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីពិនិត្យពិចារណា។

អភិបាលខេត្តមានសិទ្ធិស្នើលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលជាប្រព័ន្ធខុសច្បាប់ដែលមិនអាចធ្វើយុត្តិកម្មបាន។[៣១]

## ការធ្វើការងាររបស់គណៈអភិបាលខេត្ត

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួនគណៈអភិបាលខេត្ត អភិបាលខេត្ត អភិបាលរងខេត្តត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្នុងការអនុវត្តតួនាទី ភារកិច្ចអភិបាលខេត្តត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់រាជរដ្ឋាភិបាលក្រសួងស្ថាប័នត្រូវមាន គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានាស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និងការងារផ្សេងទៀតដែលខ្លួនយល់ឃើញថាពិតជាចាំបាច់ អភិបាលខេត្តត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សានៅក្នុងគណៈអភិបាលខេត្តរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុទ្ធនាព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។
- អភិបាលខេត្តត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តអំពីសកម្មភាពការងារទាំងឡាយណាដែលជារបស់គណៈអភិបាលខេត្តរបស់ខ្លួន។ អភិបាលរងខេត្តត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តលើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលខេត្តរបស់ខ្លួន។

---

[៣១] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៣៥-៣៦-៣៨

- ដើម្បីធានាឱ្យគោលការណ៍នៃការអនុវត្តការងារនេះមានប្រសិទ្ធភាពគណៈអភិបាលខេត្តត្រូវជួបជុំប្រចាំពាក់កណ្តាលខែ។ ការប្រជុំពាក់កណ្តាលខែទី២នៅខែនីមួយៗជាការប្រចាំខែក្រៅពីការប្រជុំនេះនឹងការប្រជុំប្រចាំខែគណៈអភិបាលខេត្តអាចកោះប្រជុំតាមការចាំបាច់។ រៀងរាល់កិច្ចប្រជុំទាំងនេះត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។[៣២]
- គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីធ្វើការបែងចែកភារកិច្ច អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សាខេត្តរបស់ខ្លួន។ អភិបាលរងខេត្តដែលត្រូវបានទទួលការបែងចែកភារកិច្ចនេះត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលខេត្ត។
- អភិបាលខេត្តត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សាខេត្តលើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាម ក្រុមប្រឹក្សាខេត្តរបស់ខ្លួន។ អភិបាលខេត្តអាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាល ចាំបាច់មួយចំនួនក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរង ខេត្តនីមួយៗ។ ប៉ុន្តែអភិបាលខេត្តត្រូវទទួលខុសត្រូវ អំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទនីតិវិធីចំពោះឯកសារលិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។
- អភិបាលខេត្តមានសិទ្ធិដកហូតមកវិញនូវសិទ្ធិដែលបានចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី។ ការប្រគល់និងការដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខានេះអភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សាខេត្តរបស់ខ្លួនដោយយោងតាម អនុក្រឹត្យស្តីពីនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក។
- ក្នុងករណីអភិបាលខេត្តអវត្តមានអភិបាលរងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។ ប្រសិនបើអភិបាលខេត្តអវត្តមានដោយពុំផ្ទេរសិទ្ធិអភិបាលរងខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលនៃគណៈអភិបាលខេត្តត្រូវធ្វើជាអភិបាលខេត្តស្តីទី។ ក្នុងករណីគណៈអភិបាលខេត្តស្តីទីអវត្តមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។

[៣២] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៣១

- អភិបាលខេត្តស្តីទីត្រូវរាយការណ៍ជូននូវរាល់កិច្ចការទាំងឡាយដែលបានអនុវត្តជូនទៅអភិបាលខេត្ត នៅដែលអភិបាលខេត្តមានវត្តមានវិញ។[៣៣]
- គណៈអភិបាល ខេត្តអភិបាលខេត្ត និងអភិបាលរងខេត្តដែលបានសម្រេច ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្តការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលខេត្ត ឬអភិបាលរងខេត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។[៣៤]

## ១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំខេត្ត

ជាការពិតណាស់ការរៀបចំខេត្ត ក្រុង មួយត្រូវធ្វើឡើងដោយចាំបាច់ត្រូវតែមានការគិតគូរឱ្យបានហ្មត់ចត់ល្អិតល្អន់ដូចនេះហើយទើបការរៀបចំខេត្ត ក្រុងនីមួយៗមានប្រសិទ្ធភាពការរៀបចំទីក្រុងមិនមែនធ្វើឡើងដោយភាពចៃដន្យនោះទេពោលកើតឡើងដោយសារតែមានការជំរុញពីកត្តាផ្សេងៗ ដែលមានជាច្រើនដូចជាកំណើនប្រជាជន ភាពក្រីក្ររបស់ប្រជាជន កម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជន និងការដាក់សម្ពាធពីបរិស្ថាន និងគមនាគមន៍ដែលនឹងធ្វើការបកស្រាយនៅតាមចំណុចនីមួយៗនៅខាងក្រោម៖

### ១.៣.១. កំណើនប្រជាជន

ការកើនឡើងនៃចំនួនប្រជាជនតែងតែកើតមានឡើងពីមួយឆ្នាំទៅមួយឆ្នាំហើយវាក៏ជាមូលហេតុមួយយ៉ាងសំខាន់ដែលចាំបាច់តម្រូវឱ្យមានការរៀបចំខេត្តក្រុង។ ជាទូទៅសមាសភាពនៃកំណើនប្រជាជនក្នុងខេត្តក្រុងមានកត្តាល៣សំខាន់ៗ កំណើនប្រជាជនតាមលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយការធ្វើចំណាកស្រុកនៃប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ និងកំណើនដោយសារតែមានការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនតំបន់នោះជាទីជនបទ។ យ៉ាងណាមិញកំណើនប្រជាជនក្នុងខេត្ត តាមលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន រីឯកំណើនដោយសារមានការចំណាក់ស្រុករបស់ប្រជាជននៅជនបទ និងកំណើនដោយសារមានការបែងចែកក្រុងថ្មីត្រឹមតែជាធាតុបន្ទាប់បន្សំប៉ុណ្ណោះ។[៣៥] ដោយសារតែអត្រាកំណើននៃចំនួនប្រជាជន តែងមានការ កើនឡើងបែបនេះដែលជាដើមហេតុដ៏ធំមួយបង្កឱ្យមានបញ្ហាមួយចំនួនដូចជា៖

[៣៣] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៤០

[៣៤] អនុក្រឹត្យ លេខ២១៦ អនក្រ.បក, មាត្រា៣២

[៣៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៦

- **ការកកស្ទះចរាចរណ៍** ជាបញ្ហាដ៏ធំមួយដោយសារចំនួនប្រជាជនមានការកើនឡើង។ ដូចនេះតម្រូវការប្រើប្រាស់យានយន្តគ្រប់ប្រភេទក៏មានការកើនឡើង នោះជាមូលហេតុដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ព្រោះតម្រូវការនូវការប្រើប្រាស់ផ្លូវមានចំនួនច្រើន និងធំហើយអ្នកប្រើប្រាស់ផ្លូវមួយចំនួនក៏មិនបានគោរពច្បាប់ចរាចរណ៍ដោយសារពួកគាត់បើកប្រជែងគ្នាដើម្បីបានទៅមុខរៀងខ្លួនដោយមិនខ្វល់ពីអ្នករួមដំណើរជាមួយនោះទេ។ ផ្លូវដែលមានការកកស្ទះភាគច្រើនជាតំបន់ផ្សារ ឬរោងចក្រដែលបង្កមកពីអាជីវករមួយចំនួនគាត់បានប្រើប្រាស់ចញ្ចើមផ្លូវធ្វើជាការលក់ដូរ។ ម្យ៉ាងការកកស្ទះចរាចរណ៍ជាបញ្ហាដ៏ធំមួយដែលជាឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពផ្លូវចិត្តខាតពេលវេលា និងខាតបង់លុយកាក់ដោយសារនៅពេលស្ទះចរាចរណ៍ម្តងៗអ្នកបើកបរលើដងផ្លូវត្រូវការបញ្ឆេះឡានម៉ូតូកង់បីទុកទម្រាំតែបានចេញដំណើរដែលនោះធ្វើឱ្យមានការខាតបង់ក្នុងការចំណាយលើប្រេងសាំង ឬម៉ាសូតដែលពួកគាត់បានបញ្ឆេះចោលនៅពេលស្ទះចរាចរណ៍ ហើយវាក៏បង្កឱ្យមានការបំពុលបរិស្ថានបន្ថែមទៀត។
- **ការរីករាលដាលនៃសំណង់អាណាធិបតេយ្យ** គឺជាតំបន់ដែលមានប្រជាជនរស់នៅភាគច្រើនសម្បូរទៅដោយលំនៅដ្ឋានដែលមិនមានគុណភាព និងសាងសង់នៅតំបន់ខុសច្បាប់ដូចជានៅលើប្រឡាយ ឬអូរជាដើមដែលភាគច្រើនរស់នៅដោយប្រជាជនក្រីក្រ ឬប្រជាជនដែលចំណាកស្រុកពីរជនបទការកើនឡើងនៅសំណង់អាណាធិបតេយ្យនេះក៏ធ្វើឱ្យមានផលប៉ះពាល់ដល់សោភ័ណទីក្រុងផងដែរ។
- **កង្វះខាតអគ្គិសនី** ដោយសារប្រជាជនមានចំនួនកើនឡើងតម្រូវការនៃការប្រើប្រាស់ថាមពលអគ្គិសនីក៏ត្រូវមានការកើនឡើងដូចគ្នាជាលំដាប់ និងបញ្ហា ឬតម្រូវការផ្សេងៗជាច្រើនទៀត។ ដូច្នេះដើម្បីជាការដោះស្រាយបញ្ហាទាំងអស់នេះបាន គឺទាមទារឱ្យទីក្រុងត្រូវមានការអភិវឌ្ឍរៀបចំកែប្រែទីក្រុងដើម្បីឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយនិងអនាម័យដើម្បីបំពេញនូវតម្រូវការរបស់ប្រជាជនក្នុងក្រុងព្រោះកាលណាប្រជាជននៅតែកើនឡើងតម្រូវការក៏នៅតែមានការកើនឡើងជាមួយគ្នាដែរ។

នៅក្នុងខេត្តរតនគិរី មានការកើតឡើងនៅចំនួនប្រជាជន ដោយសារ ប្រជាជនដែលរស់នៅតំបន់នោះមានការកើនឡើងខ្លាំង និងម្យ៉ាងទៀតចំនួនប្រជាជនមានការកើនឡើងដោយសារមានការចំណាកស្រុកពីខាងក្រៅចូលមករស់នៅក្នុងខេត្តរតនគិរី ទៅតាមបណ្តាលស្រុក និងទីរួមខេត្ត។ ពេលនេះជាកត្តាជាសំខាន់ដែលនាំឱ្យខេត្តរតនគិរីក៏មានការកើនឡើងនូវចំនួនយានយន្ត និងមានការកើនឡើងនៃការសាងសង់លំនៅដ្ឋានក៏ជាកត្តាដែលនាំឱ្យកង្វះខាតអគ្គិសនីនៅក្នុងការប្រើប្រាស់ផងដែរជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមស្រុកភូមិដែលដាច់ស្រយាលពីទីរួមខេត្តពួកគាត់មិនមានអគ្គិសនីសម្រាប់ប្រើប្រាស់នោះទេ។

### ១.៣.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រដែលមានការលំបាក ប៉ុន្តែជាទូទៅភាពក្រីក្រ គឺសំដៅទៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបំពេញដូចជាតម្រូវការរូបកាយចំណីអាហារ លំនៅដ្ឋានការងារធនធានអគ្គិសនីអនាម័យសុខមាលភាពសង្គមនៅមានការខ្វះខាត។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលម្នាក់ៗពីព្រោះតែបញ្ហាផ្សេងៗដូចជាចំនួននៃការកើនឡើង នូវកំណើនឧក្រិដ្ឋកម្មអំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលបាននោះឡើយ ដែលជាធម្មតាអ្នកដែលទទួលបាននូវប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានសន្មត់ថាជាជនក្រីក្រ។[៣៦] បើយើងធ្វើការប្រៀបធៀបភាពក្រីក្រនៅតាមជនបទ និងភាពក្រីក្រនៅតាមទីក្រុងឃើញថាមានលក្ខណៈខុសគ្នាដោយហេតុថានៅទីក្រុងត្រូវមានការចំណាយខ្ពស់ជាងនៅតាមជនបទ ហើយម្យ៉ាងវិញទៀតអ្នករស់នៅតាមជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈការទទួលផលពីធម្មជាតិច្រើនជាងអ្នកទីក្រុង។ តាមរយៈនេះគេអាចនិយាយបានថាអ្នកក្រនៅទីក្រុងមានស្ថានភាពលំបាកជាងអ្នកក្រនៅតាមជនបទ។ មួយវិញទៀតភាពក្រីក្រនេះបានធ្វើឱ្យមានបញ្ហាដល់សោភ័ណភាពផងដែរ ដោយសារតែប្រជាជនក្រីក្រភាគច្រើនមិនមានកន្លែងស្នាក់សមរម្យដែលអ្នកខ្លះត្រូវស្នាក់ ឬសម្រាកនៅតាមចញ្ចើមផ្លូវ ឬសួនច្បារ វត្តអារាមជាដើមហើយក៏មានប្រជាពលរដ្ឋមួយចំនួនត្រូវដើរសុំទាននៅតាមភ្លើងស្តុប វត្តអារាមឬតាមផ្ទះ សាលារៀនដើម្បីយកប្រាក់ទាំងនោះមកចិញ្ចឹមជីវិត។ តួយ៉ាងបញ្ហាទាំងអស់នេះបានធ្វើឱ្យមានការប៉ះពាល់ខ្លាំងណាស់ដល់សណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ខេត្តដែលជាហេតុនាំឱ្យអាជ្ញាធរខេត្តត្រូវតែយកចិត្តទុកដាក់ក្នុងការស្វែងរកដំណោះស្រាយដើម្បីរៀបចំធ្វើយ៉ាងណាឱ្យមានលក្ខណៈល្អប្រសើរ។

ករណីនៅក្នុងខេត្តរតនគិរី គឺជាខេត្តមួយដែលមានការសាងសង់ឡើងនូវវារីអគ្គិសនីមុនគេបង្អស់ក្នុងឆ្នាំ១៩៧៩ តែទោះជាយ៉ាងនេះក្តីក៏វារីអគ្គិសនីនេះមិនអាចប្រើប្រាស់គ្រប់គ្រាន់សម្រាប់ប្រជាជន នៅក្នុងខេត្តរតនគិរីនៅឡើយទេដូចជាប្រជាពលរដ្ឋដែលរស់នៅតាមស្រុកដែលដាច់ស្រយាលមួយចំនួនដែលមិនទាន់ទទួលបាននូវថាមពលវារីអគ្គិសនីប្រើប្រាស់នៅឡើយ។ ម្យ៉ាងវិញទៀតបើនិយាយអំពីចំណូលរបស់ប្រជាជនដែលរស់នៅក្នុងខេត្តរតនគិរីនេះឃើញថាប្រជាជនភាគច្រើនគាត់ គឺជាជនជាតិដើមភាគតិច ហេតុនេះចំណូលប្រចាំថ្ងៃរបស់គាត់គឺមានចំណូលទាបដោយសារតែគាត់ធ្វើការប្រកបមុខរបរចិញ្ចឹមជីវិតតាមបែបប្រពៃណីដោយការធ្វើចម្ការវិលជុំ និងអាស្រ័យផលទៅលើធនធានធម្មជាតិ។

[៣៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៧

### ១.៣.៣. កម្រិតជីវភាពនៃការរស់នៅ

ដោយសារតែភាពខុសគ្នារវាងស្ថានភាពជីវភាពនៃការរស់នៅរបស់ប្រជាជនដែលរស់នៅជនបទមានភាពខុសគ្នាពីប្រជាជនដែលរស់នៅទីក្រុង មូលហេតុកម្រិតជីវភាព និងប្រាក់បៀវត្សរ៍របស់ប្រជាជននៅទីក្រុងខ្ពស់ និងការងារនៅជនបទនៅមានកម្រិតជាហេតុនាំឱ្យប្រជាជនរស់នៅតាមជនបទចង់មករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ នោះប្រជាជននៅតាមជនបទនៅតែធ្វើការចំណាកស្រុកមករស់នៅក្នុងទីក្រុង ដើម្បីស្វែងរកការងារធ្វើដោយកត្តាទាំងនេះធ្វើឱ្យមានកំណើនប្រជាជនក្នុងក្រុង។ លើសពីនេះទៅទៀតនៅទីក្រុងមានការប្រមូលផ្តុំនៅកត្តាសង្គមនយោបាយល្អប្រសើរខណៈសេវាសុខាភិបាល និងអប់រំមានសំបូរបែបដែលធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាទាំងអស់។[៣៧] ម្យ៉ាងវិញទៀតនៅក្នុងទីក្រុងការបម្រើសេវាសាធារណៈតែងតែមានច្រើន និងឆាប់រហ័សជាងនៅទីជនបទក៏ដូចជាសេវាសុខាភិបាលនៅតាមជនបទដាច់ស្រយាល ដោយឃើញថានៅមណ្ឌលសុខភាពមួយចំនួននៅពុំទាន់មានសម្ភារៈគ្រប់គ្រាន់ មិនទាន់មានកន្លែងស្នាក់នៅសម្រាប់របស់អ្នកជំងឺគ្រប់គ្រាន់។ បើនិយាយពីវិស័យអប់រំវិញឃើញថា នៅក្នុងក្រុងមានទាំងសាលារដ្ឋ និងសាលាឯកជន មានទាំងភាសាខ្មែរ ភាសាបរទេស។ រីឯសាលារៀននៅតាមជនបទវិញមានតែសាលារដ្ឋហើយសាលារៀនខ្លះមិនទាន់មានអគារសិក្សាត្រឹមត្រូវនៅឡើយទេ និងសាលាខ្លះមានចម្ងាយឆ្ងាយពីកន្លែងដែលប្រជាពលរដ្ឋរស់នៅ។ បញ្ហាទាំងនេះហើយជាហេតុនាំឱ្យប្រជាជនប្រមូលផ្តុំគ្នាមករស់នៅក្នុងទីក្រុងដើម្បីងាយស្រួលក្នុងការទទួលបានសេវាសាធារណៈដែលតម្រូវឱ្យទីក្រុងត្រូវតែមានការរៀបចំជាបន្តបន្ទាប់ដើម្បីរក្សានៅសណ្តាប់ធ្នាប់ អនាម័យ និងសោភ័ណភាពនៃទីក្រុង។

ខេត្តរតនគិរីទាក់ទងទៅនឹងការទទួលសេវាសុខាភិបាលដោយនៅមានកម្រិតនៅឡើយទេដោយសារប្រជាជនដែលរស់នៅតាមស្រុកដាច់ស្រយាលមណ្ឌលសុខភាពមិនទាន់មានសម្ភារៈគ្រប់គ្រាន់សម្រាប់ព្យាបាលអ្នកជំងឺ ហើយមណ្ឌលសុខភាពខ្លះនៅឆ្ងាយពីកន្លែងដែលប្រជាពលរដ្ឋរស់នៅ។ រីឯវិស័យអប់រំវិញនៅក្នុងក្រុងបានលុងមានសាកលវិទ្យាល័យ វិទ្យាល័យទាំងរដ្ឋ និងសលាឯកជនដែលមានបង្រៀនទាំងភាសាខ្មែរ និងភាសាបរទេស ហើយមានអគារសម្រាប់សិក្សាគ្រប់គ្រាន់។ ដោយឡែកប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាលនៅតាមស្រុកមានតែសាលារដ្ឋស្រុកខ្លះមានវិទ្យាល័យស្រុកខ្លះនៅមិនទាន់មានវិទ្យាល័យនៅឡើយទេ ហើយសាលាខ្លះមិនទាន់មានអគារសិក្សាត្រឹមត្រូវទេ ហើយសាលាខ្លះទៀតនៅឆ្ងាយពីផ្ទះរបស់ប្រជាពលរដ្ឋ។

[៣៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៨

### ១.៣.៤. ការដាក់សម្ពាធបរិស្ថាន

ការដាក់សម្ពាធបរិស្ថាន គឺសំដៅទៅលើគ្រោះមហន្តរាយធម្មជាតិដូចជា គ្រោះរាងស្ងួត ដីខ្សោះជីវជាតិមិនសមល្មមសម្រាប់ធ្វើកសិកម្មខ្វះទឹកហើយពេលខ្លះមានទឹកជំនន់ជនលិចផលដំណាំរបស់ប្រជាជន។[៣៩] មួយវិញទៀតឃើញថាសម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅតាមជនបទមិនមានដីគ្រាប់គ្រាន់សម្រាប់បង្កបង្កើនផល ដើម្បីធ្វើកសិកម្ម មានប្រព័ន្ធធារាសាស្ត្រ សម្រាប់ស្រោចស្រពមិនទាន់គ្រប់គ្រាន់ដែលជាកត្តាមួយផ្តល់ផលវិបាកយ៉ាងខ្លាំងចំពោះប្រជាជនរស់នៅតាមជនបទដែលពួកគាត់ត្រូវបង្អែកលើការប្រកបរបរធ្វើស្រែចំការសម្រាប់ចិញ្ចឹមជីវិត។

នៅក្នុងខេត្តរតនគិរីដែលជាប្រជាជនភាគច្រើន គឺជាជនជាតិដើមភាគតិចដែលពួកគាត់ប្រកបមុខរបរដោយការធ្វើចម្ការវិលជុំ និងអាស្រ័យផលធនធានធម្មជាតិ។ ហេតុនេះបរិស្ថាននៅជុំវិញ គឺជាជីវិតរបស់ពួកគេ។ ការធ្វើចម្ការវិលជុំនេះទៀតសោតពួកគាត់ពឹងផ្អែកទៅលើអាកាសធាតុដោយសារតែពួកគាត់ដាំស្រូវនៅតាមជ្រលងភ្នំ និងពឹងផ្អែកទៅលើទឹកភ្លៀងពីធម្មជាតិហើយទិន្នផលប្រចាំឆ្នាំដែលទទួលបានតិចតួចគ្រាន់តែសម្រាប់ផ្គត់ផ្គង់គ្រួសារតែប៉ុណ្ណោះមិនអាចនាំចេញលក់នោះទេ។

### ១.៣.៥. គមនាគមន៍

គមនាគមន៍ គឺជាផ្លូវសម្រាប់ធ្វើដំណើរទៅវិញទៅមកដែលជាមធ្យោបាយយ៉ាងសំខាន់សម្រាប់ចរាចរណ៍ និងជាតម្រូវការដ៏ចាំបាច់ដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបានឡើយ ព្រមទាំងនៅក្នុងប្រទេសកម្ពុជាផ្លូវគមនាគមន៍មានបីប្រភេទផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។

- ផ្លូវគោកជាផ្លូវសម្រាប់ធ្វើដំណើរទៅវិញទៅមក ហើយលើគោកចែកចេញជាពីរផ្លូវថ្នល់ និងផ្លូវដែក។ ផ្លូវថ្នល់មាន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំ និងផ្លូវរុក្ខបាល រីឯផ្លូវដែកមាន ២ខ្សែ ខ្សែទី១ពីភ្នំពេញទៅអូរជ្រៅមានប្រវែង ៣៨៥គីឡូម៉ែត្រ និងខ្សែទី២ ពីភ្នំពេញទៅខេត្តព្រះសីហនុមានប្រវែង ២៦៦គីឡូម៉ែត្រ។
- ផ្លូវទឹក គឺសំដៅលើផ្លូវមួយយ៉ាងសំខាន់សម្រាប់ការដឹកជញ្ជូន និងការប្រកបរបរដែលមានដូចជាទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ និងដៃនានា។
- ផ្លូវអាកាស គឺជាផ្លូវមួយដែលមានសារៈសំខាន់ណាស់ក្នុងការដឹកជញ្ជូន។

ផ្លូវគមនាគមន៍ ជាផ្លូវមួយយ៉ាងសំខាន់ដែលជំរុញឱ្យមានការរៀបចំហេដ្ឋានរចនាសម្ព័ន្ធក្រុង ព្រោះការរីកចម្រើនលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍វាក៏ជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ ជាពិសេសវាជាមធ្យោបាយមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន សម្រាប់ទំនាក់ទំនងអន្តរជាតិដោយសារវាអាចជួយសម្រួលដល់ការនាំចេញ និងការនាំចូលការអភិវឌ្ឍលើគ្រប់វិស័យ។ ផ្ទុយទៅវិញប្រសិនជាទីក្រុង

[៣៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៨

ឬប្រទេសខ្វះខាតនៅផ្លូវគមនាគមន៍ និងបង្កឱ្យមានការកកស្ទះដល់ដំណើរការនៃការដឹកជញ្ជូន និងការអភិវឌ្ឍផ្សេងៗដែលនាំឱ្យមានការបាត់បង់នូវសណ្តាប់ធ្នាប់ សោភ័ណភាព របៀបរៀបរយព្រមទាំងជាឧបសគ្គដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។

ខេត្តរតនគិរីនាពេលបច្ចុប្បន្ននេះមានការរីកចម្រើនយ៉ាងគួរឱ្យកត់សម្គាល់ដោយក្នុងក្រុងមានផ្លូវចាក់កៅស៊ូគ្រប់ទីកន្លែងព្រមទាំងមានការរៀបចំគំនូសលើទ្រូងផ្លូវ មានសួនផ្កានៅតាមដងផ្លូវជាដើម។ លើសពីនេះទៅទៀតនោះផ្លូវដែលចេញពីក្រុងទៅតាមបណ្តាស្រុកនានាមានក្រាលកៅស៊ូស្ទើរគ្រប់ផ្លូវដែលបង្កឱ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ ដែលជួយកាត់បន្ថយការចំណាយថវិកាច្រើន ព្រមទាំងមិនខាតពេលវេលាក្នុងការធ្វើដំណើរយូរថ្ងៃ។ ក្រៅពីនេះស្រុកខ្លះមានក្រុមហ៊ុនឡាន និងឡានតាក់ស៊ីរត់ពីស្រុកមួយទៅស្រុកមួយផងដែរ។

# ជំពូកទី២

# ការរៀបចំសណ្ឋាប់ធ្នាប់

# និងសោភ័ណភាពខេត្តរតនគិរី

# ជំពូកទី២
# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរី

## ២.១. ការរៀបចំខេត្តរតនគិរី

ដើម្បីងាយស្រួលក្នុងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងបណ្ដាខេត្តនីមួយៗតែងតែមាននូវគម្រោងនៅក្នុងការកសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើនកន្លែង។ ចំពោះការអភិវឌ្ឍទាំងអស់នេះ គឺធ្វើឡើងដើម្បីបម្រើ និងផ្គត់ផ្គង់ឱ្យបានទាន់តម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តដែលកំពុងតែមានកំណើនជារៀងរាល់ថ្ងៃជាលំដាប់។ បន្ទាប់ពីនេះមកដល់ពេលបច្ចុប្បន្នក្នុងឆ្នាំ២០២៣នេះយើងសង្កេតឃើញថានៅក្នុងខេត្តរតនគិរីនេះមានការអភិវឌ្ឍជាច្រើនគួរឱ្យកត់សម្គាល់ ហើយការអភិវឌ្ឍនេះមិនមែនត្រឹមតែនៅក្នុងវិស័យណាមួយនោះទេ ពោល គឺមានការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់។ ប៉ុន្តែដោយការរៀបរាប់ពីការអភិវឌ្ឍទាំងអស់នោះ គឺវាមានភាពធំទូលំទូលាយពេកដូចនេះយើងនឹងធ្វើការរៀបរាប់ផ្ដោតសំខាន់តែទៅលើចំណុចដែលមានការប្រាស្រ័យពាក់ព័ន្ធទៅនឹងវិស័យនគរូបនីយកម្មតែប៉ុណ្ណោះ។

### ២.១.១. ការរៀបចំសោភ័ណភាពខេត្តរតនគិរី

ខេត្តរតនគិរីមានទីតាំងស្ថិតនៅភូមិភាគឦសាន្តនៃព្រះរាជាណាចក្រកម្ពុជាដែលមានចម្ងាយពីភ្នំពេញ ៥៨៨គីឡូម៉ែត្រមានព្រំប្រទល់ខាងកើតដែលជាប់នឹងខេត្តកន្ទូម និងខេត្តយ៉ាឡាយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងលិចជាប់នឹងខេត្តស្ទឹងត្រែង ខាងជើងជាប់នឹងខេត្តអត្តពឺនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងត្បូងជាប់នឹងខេត្តមណ្ឌលគិរី។[៣៩] ហើយមិនតែប៉ុណ្ណោះខេត្តរតនគិរីពោរពេញទៅដោយកន្លែង ដែលសុទ្ធសឹងជារមណីយដ្ឋានធម្មជាតិ វប្បធម៌ និងភាពសម្បូរបែបផ្សេងៗគ្នាក្នុងនោះវាមានសំណង់ស្នាដៃរទំនើបៗមានដូចជា ភោជនីយដ្ឋាន បារ សណ្ឋាគារ ផ្លូវសួនច្បារ និងទីកន្លែងផ្សេងៗទៀតជាច្រើនដែលវាជាកន្លែងដ៏មានសកម្មភាពខ្លាំងក្លា។ ទាក់ទងទៅនឹងទេចរណ៍វិញ តំបន់ដងទន្លេ និងតំបន់បេតិកភណ្ឌដែលស្ថិតនៅក្នុងខេត្ត គឺជាទិសដៅមួយសម្រាប់ភ្ញៀវទេសចរដែលចូលមកលេងកម្សាន្តក្នុងក្រុងបានលុងហើយក៏ជាកន្លែងកម្សាន្តមួយដែលពោរពេញដោយធម្មជាតិបៃតង  ព្រមទាំងផ្លូវធ្វើដំណើរក៏មានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ហើយម្យ៉ាងវិញទៀតក៏មិនមានការស្ទះចរាចរណ៍នៅតាមបណ្ដាផ្លូវសម្រាប់ប្រជាជននៅខាងក្រៅខេត្តអាចមកទស្សនាបានយ៉ាងងាយស្រួលផងដែរ។ យ៉ាងណាមិញនៅតាមមាត់បឹងកន្សែងក៏មានភោជនីយដ្ឋាន និងកន្លែងកម្សាន្តសម្រាប់ប្រជាពលរដ្ឋអាចដើរហាត់ប្រាណបានយ៉ាងងាយស្រួល ព្រមទាំងមានកន្លែងអង្គុយញ៉ាំអាហារយ៉ាងស្រស់ស្រាយ និងរីករាយ។ ជាងនេះទៅទៀតនៅក្នុងខេត្តក៏មានកន្លែងមួយចំនួនទៀត សម្រាប់កម្សាន្តដូចជាមានលក់នូវវត្ថុអនុស្សាវរីយ៍ ផលិតផល សិប្បកម្ម សម្លៀកបំពាក់បែប

[៣៩] គេហទំព័រ https://www.ratanakiri.gov.kh/ ដកស្រង់នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣

ប្រពៃណី ទំនៀមទម្លាប់របស់បងប្អូនជនជាតិដើមភាគតិច ព្រមទាំងមានលក់ គ្រឿងអលង្ការ ត្បូងធម្មជាតិ រ៉ែ និងសម្ភារៈដទៃទៀតយ៉ាងសម្បូរបែប។

**២.១.១.១. សោភ័ណភាពពេលថ្ងៃ**

ដោយយោងទៅតាមសៀវភៅ នីតិនគរូបនីយវិទ្យារបស់"លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា" បានឱ្យនិយមន័យសោភ័ណភាពពេលថ្ងៃថាគឺសំដៅទៅដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អគារតូច ធំទាំងអស់របស់រដ្ឋ ព្រមទាំងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផងប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អថែមទៀតសរុបមកគឺអ្វីៗដែលកើតមានឡើងនៅលើដី។ [៤០]ប្រសិនបើក្រឡេកមកមើលទិដ្ឋភាពក្នុងខេត្តរតនគិរីនេះវិញសង្កេតឃើញថានៅតាមដងផ្លូវមានដាំដើមឈើស្រស់បំព្រងគួរជាទីចាប់អារម្មណ៍ព្រមទាំងរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក៏រៀបចំបានយ៉ាងល្អហ្មត់ចត់ដោយរៀបចំឱ្យមានស្លាកសញ្ញា គំនូរសញ្ញាចរាចរណ៍បង្គោលភ្លើងបំភ្លឺផ្លូវ ការរៀបចំដាក់ឱ្យមានលូទំហំធំក៏ដូចជាប្រព័ន្ធបង្ហូរទឹកឱ្យបានឆាប់រហ័សចៀសវាងមានការជន់លិចផ្លូវរយៈពេលយូរដែលបង្កការរំខានដល់ការធ្វើដំណើរ ហើយមានការរៀបចំសួនច្បារបានយ៉ាងល្អស្រស់ស្អាត និងបង្កភាពងាយស្រួលដល់ប្រជាជនអាចដើរកម្សាន្ត។

**ក. ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដី**

ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដី គឺសំដៅទៅលើការកសាងសំណង់នានាដូចជាផ្លូវ ថ្នល់សាលារៀន មន្ទីរពេទ្យ អគារ បុរីតម្រៀបគ្នាជាជួរៗស្លាកសញ្ញា និងភ្លើងសញ្ញាចរាចរណ៍ជាដើម។ ជាក់ស្តែងនៅក្នុងខេត្តរតនគិរីរដ្ឋបាលខេត្តបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកសាង និងរៀបចំទៅលើហេដ្ឋារចនាសម្ព័ន្ធជាច្រើនកន្លែងសម្រាប់បំពេញតម្រូវការទាំងភ្ញៀវទេសចរ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ នៅប៉ុន្មានឆ្នាំចុងក្រោយមកនេះសាលានៅខេត្តរតនគិរីបានរៀបចំកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជាកសាងអគារថ្មីៗ និងបន្ទប់ទឹកនៅតាមសាលារៀនបឋមសិក្សា និងអនុវិទ្យាល័យមួយចំនួនធំដែល ហើយមិនតែប៉ុណ្ណោះសាកលវិទ្យាល័យនៅក្រុងបានលុងមានពីរ គឺសាកលវិទ្យាល័យបៀលប្រាយ ដែលនៅជិតសាលាខេត្តរតនគិរីមានទីតាំងស្ថិតនៅជិតបឹងកន្សែងទល់មុខមន្ទីរទាហ៊ានក្រុងបានលុង។ លើសពីនេះទៀតសាកលវិទ្យាល័យបៀលប្រាយនេះក៏មាននិស្សិតចូលរៀនកាន់តែមានចំនួនច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំសាកលវិទ្យាល័យនេះដែរមិនគ្រប់គ្រាន់សម្រាប់និស្សិតក្នុងខេត្តរតនគិរីទេពីព្រោះសាកលវិទ្យាល័យបៀលប្រាយនេះមានតែពីរផ្នែក គឺគ្រប់គ្រងទូទៅ និងទេសចរណ៍ សេដ្ឋកិច្ច។ ចំពោះសាកលវិទ្យាល័យអាស៊ានព្រិច នៅក្នុងក្រុងបានលុង គឺជាសាកល

[៤០] សៀវភៅ នីតិនគរូនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១

វិទ្យាល័យមួយដែលគេទើបតែបង្កើតថ្មី ។ បន្ទាប់ពីនេះវិទ្យាល័យមានចំនួន៣គឺ វិទ្យាល័យសម្តេចឪសម្តេចម៉ែ វិទ្យាល័យហ៊ុនសែនភូមិថ្មី និងវិទ្យាល័យអន្តរវាសិកដ្ឋានក្រុងបានលុង។ ម្យ៉ាងវិញទៀតបើយើងក្រឡេកមកមើល សាលាបឋមសិក្សានៅក្នុងក្រុងបានលុងវិញដែលមានដូចជាសាលាបឋមសិក្សាឡាបានសៀក សាលាបឋម សិក្សាយក្សឡោម សាលាបឋមសិក្សាប៊ុំថង សាលាបឋមសិក្សាក្រុមព្រះ សាលាបឋមសិក្សាហ៊ុនសែនភូមិថ្មី សាលាបឋមសិក្សាកម្មករបួន សាលាបឋមសិក្សាកម្មករមួយ។ រីឯសាលាឯកជន រួមមានសាលាគ្រូយើង សាលារៀនគោលសម្ព័ន្ធ សាលាអាស៊ានព្រិច សាលារៀនហេងលៀងជាដើម។ល។

**ខ. ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដី**

ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដី គឺសំដៅទៅលើការកសាងប្រព័ន្ធលូការដាក់ខ្សែភ្លើង និងខ្សែកាបអុបទិចក្រោមដីជាដើម។ ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដីនេះក៏ជារឿងមួយសំខាន់ផងដែរក្នុងការអភិវឌ្ឍក្រុងពីព្រោះថាប្រព័ន្ធលូ និងប្រព័ន្ធខ្សែភ្លើងត្រូវមានការកសាង និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ ដើម្បីចៀសវាងនូវបញ្ហាកើតមានឡើង។ ដោយមើលឃើញពីបញ្ហានេះសាលាក្រុងក៏បានខិតខំយកចិត្តទុកដាក់ធ្វើការសហការជាមួយនឹងដៃគូអភិវឌ្ឍន៍នានាក្នុងការសាងសង់បណ្តាញលូនឹងរងទឹកកខ្វក់ដែលតភ្ជាប់ពីផ្ទះប្រជាពលរដ្ឋទៅកាន់បណ្តាញលូមេដើម្បីប្រមូលទឹកកខ្វក់យកទៅព្រោះសម្អាតនៅស្ថានីយន៍ច្រោះសម្អាតទឹកសំណល់មុននឹងបញ្ចេញទៅប្រភពទឹកសាធារណៈវិញ ដើម្បីធានាបាននូវសុខភាពសាធារណៈ បរិស្ថាន និងអនាម័យសាធារណៈ។

ពិសេសជាងនេះទៅទៀតហេដ្ឋារចនាសម្ព័ន្ធខេត្តរតនគិរីបានចូលរួមចំណែកក្នុងការអភិវឌ្ឍសោភ័ណភាពក្នុងខេត្តឱ្យកាន់តែមានភាពទាក់ទាញ និងដើម្បីក្រកួតប្រជែងជាមួយ និងខេត្តដទៃទៀត។ បើងាកមកមើលអំពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធ គឺអភិបាលនៃគណៈអភិបាលត្រូវតែត្រួតពិនិត្យមើលចំពោះការកសាងមន្ទីរពេទ្យ សាលារៀនដោយត្រូវគោរពតាមស្តង់ដារ និងបទដ្ឋានដែលច្បាប់បានកំណត់។ ចំពោះការរៀបចំចរាចរណ៍ឱ្យមានសោភ័ណភាព គឺត្រូវមានការចូលរួមចំណែកពីសំណាក់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ និងកត្តាមួយចំនួនផ្សេងៗទៀតដូចជាៈ

**កត្តាប្រជាជន** កត្តានេះត្រូវបានសង្កេតឃើញថាមានភាគច្រើនជាងគេ ដោយសារតែកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងការធ្វេសប្រហែសមិនយកចិត្តទុកដាក់នៅក្នុងការបើកបរនៅមានចំនួនច្រើន។ ដូច្នេះថ្នាក់ដឹកនាំត្រូវតែសហការជាមួយអង្គភាពពាក់ព័ន្ធនានាដើម្បីធ្វើការផ្សព្វផ្សាយ និងបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលណែនាំដល់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឱ្យយល់ដឹងអំពីច្បាប់ចរាចរណ៍ និងមានសីលធម៌ខ្ពស់ក្នុងការបើកបរដើម្បីកាត់បន្ថយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ និងធ្វើឱ្យមានសណ្តាប់ធ្នាប់ សោភ័ណភាពល្អផងដែរ។

**កត្តាផ្លូវ** ផ្លូវជាផ្នែកមួយដែលចូលរួមចំណែកក្នុងការធ្វើឱ្យមានសោភ័ណភាពល្អថែមទៀតផង។

**កត្តាយានជំនិះ** បញ្ហាយានជំនិះចាស់ៗ ឬយានជំនិះកែច្នៃគ្រប់ប្រភេទដែលចរាចរណ៍នៅលើដងផ្លូវជាកត្តាមួយដែលនាំឱ្យបាត់នូវសោភ័ណភាព និងបង្កជាគ្រោះថ្នាក់ផ្សេងៗជាយថាហេតុទៀតផង។ ហេតុនេះថ្នាក់ដឹកនាំគួរចាត់វិធានការតឹងរ៉ឹងចំពោះបញ្ហាបច្ចេកទេសយានយន្តគ្រប់ប្រភេទ ជាពិសេសយានយន្តកែច្នៃ។

**២.១.១.២. សោភ័ណភាពពេលយប់**

សោភ័ណភាពពេលយប់ គឺសំដៅទៅលើអ្វីដែលយើងមិនអាចខ្វះបាននោះទេពីព្រោះជាតម្រូវការចាំបាច់បំផុតសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ។ ការយកចិត្តទុកដាក់ អភិវឌ្ឍន៍សោភ័ណភាពពេលថ្ងៃតែមួយមុខក៏មិនអាចទាក់ទាញយកបេះដូងរបស់ប្រជាជន និងភ្ញៀវទេសចរដែលមកដើរលេងកម្សាន្តបានដែរ។ ដូច្នេះសោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់ គឺត្រូវតែដើរទន្ទឹមគ្នាដែលមិនអាចខ្វះបានមួយណាបានប្រាកដណាស់បើយើងនិយាយពីសោភ័ណភាពពេលយប់វិញ គឺអាចនឹកឃើញទៅដល់ភ្លើងពណ៌ចម្រុះដែលភ្លឺចិញ្ចែងចិញ្ចាចហាក់បីដូចជាការរស់នៅតំបន់មួយផ្សេងដែលខុសពីអ្វីដែលយើងបានឃើញនៅពេលថ្ងៃ។ បើយើងនិយាយពីសោភ័ណភាពពេលយប់ គឺសំដៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំបំពាក់នូវភ្លើងបំភ្លឺនៅតាមដងផ្លូវ តាមស្ថានអគារសាធារណៈ ឬអគារឯកជននាពេលរាត្រី និងការបំពាក់ភ្លើងចម្រុះពណ៌នៅតាមកន្លែងកម្សាន្តនានាដូចជា នៅតាមសួនច្បារកម្សាន្តផ្សេងៗឱ្យមានលក្ខណៈស្រស់ស្អាត ការច្នៃប្រឌិតដាក់ភ្លើងពណ៌ចម្រុះនៅតាមដើមឈើដែលនៅអមសងខាងផ្លូវ។ ការដាក់ភ្លើងបំភ្លឺនៅតាមសួនច្បារកម្សាន្តដែលអំណោយផលដល់ប្រជាជនដែលចង់មកលំហែកាយ ក៏ដូចជាការធ្វើលំហាត់ប្រាណនៅពេលល្ងាចក្រោយបំពេញការងារអស់រយៈពេលមួយថ្ងៃកន្លងទៅ។

**ក. ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និងអគារ**

ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និងអគារវាពិតជាមានសារៈសំខាន់ណាស់ព្រោះវាផ្តល់នូវសុវត្ថិភាពដោយជួយបំភ្លឺផ្លូវឱ្យភ្លឺជូនដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរនាពេលយប់ជ្រៅចៀសវាងការមើលផ្លូវមិនឃើញនាំឱ្យបង្កគ្រោះថ្នាក់ដល់ពួកគាត់។ សាលាខេត្តរតនគិរី ក៏បានគិតគូរដល់ការដាក់បង្គោលភ្លើងបំភ្លឺ តាមដងផ្លូវ និងអគារនាពេលរាត្រីផងដែរដែលក្នុងនោះយើងឃើញថាមានការបំពាក់នូវបង្គោលភ្លើងបំភ្លឺផ្លូវនៅតាមដងផ្លូវថ្នល់ អគារសាធារណៈ សណ្ឋាគារ អគារ ពាណិជ្ជកម្មផ្សេងៗជាដើម។

**ខ. ការដាក់ភ្លើងលម្អ រាត្រីតាមឧទ្យាន និងសួនច្បារសាធារណៈ**

ការដាក់ភ្លើងលម្អពេលរាត្រី គឺជាការដាក់ភ្លើងចម្រុះពណ៌ផ្សេងៗនៅតាមឧទ្យាន តាមទីធ្លា ឬសួនច្បារសាធារណៈដើម្បីបង្កើនឱ្យមានភាពស្រស់ស្អាត និងទាក់ទាញនៅក្នុងខេត្តទាំងមូល។ ការរៀបចំភ្លើងលម្អដើម្បីធ្វើឱ្យមានសោភ័ណភាពកាន់តែស្រស់ត្រកាល ក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ អន្តរជាតិឱ្យមកទស្សនាកម្សាន្ត។ ក្នុងនោះឃើញមានការបំពាក់ និងការតុបតែងភ្លើងលម្អនៅតាមដងផ្លូវសាធារណៈ ដងវិថីនានា ទីប្រជុំជន។ ម្យ៉ាងទៀតក្រុមបច្ចេកទេសការរៀបចំលម្អភ្លើង គឺត្រូវរៀបចំយ៉ាងណាដើម្បីលេចនូវសោភ័ណភាពសម្រស់

បែតងនៅតាមដងផ្លូវ ដងបឹងកន្សែង ដងផ្លូវផ្កាឈូកនាពេលរាត្រីឱ្យកាន់តែធ្វើការទាក់ទាញអារម្មណ៍ភ្ញៀវទេសចរជាតិ អន្តរជាតិចូលមកទស្សនាកម្សាន្តជាពិសេសក្នុងឱកាសព្រឹត្តិការណ៍សង្ក្រាន្តជាដើម។

ជាមួយគ្នានេះដែរនៅក្នុងខេត្តរតនគិរីការដែលរៀបចំឱ្យមានការបំពាក់ភ្លើងបំភ្លឺ និងភ្លើងចម្រុះពណ៌មិនត្រឹមតែផ្តោតសំខាន់លើភាពស្រស់ស្អាតនោះទេតែផ្ទុយទៅវិញ គឺជៀសវាងកើតមានករណីចោរកម្ម ការប្រព្រឹត្តអំពើអនាចារ ក៏ដូចជាការសេពគ្រឿងញៀននៅតាមទីសាធារណៈដែលមិនមានការដាក់កាំមេរ៉ា និងមិនមានការបំពាក់នូវភ្លើងបំភ្លឺឱ្យបានគ្រប់គ្រាន់ដែលជាហេតុនាំឱ្យមានភាពអសន្តិសុខក្នុងខេត្ត។ បន្ថែមលើនេះទៅទៀតរដ្ឋបាលខេត្តរតនគិរី ក៏បានរៀបចំឱ្យមានភ្លើងនៅតាមដងផ្លូវដើរតូចៗ និងសម្រាប់ចូលទៅក្នុងគេហដ្ឋានរបស់ប្រជាជនដែលជាចំណុចដែលថ្នាក់ដឹកនាំបានគិតយ៉ាងហ្មត់ចត់ពីសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តរតនគិរីទាំងមូល ដើម្បីចៀសវាងពីការបង្កឱ្យមានភាពភ័យខ្លាចក្នុងការបំពេញការងារអាជីវកម្មប្រចាំថ្ងៃ។

**២.១.២. ការរៀបចំសណ្តាប់ធ្នាប់**

សណ្តាប់ធ្នាប់សាធារណៈ គឺជាបញ្ហាមួយដ៏សំខាន់ដែលអាចកើតឡើងតាមរយៈភាពអសន្តិសុខ និងនៅក្នុងសង្គមក៏ជាកត្តាមួយដែលជម្រុះឱ្យមានការអភិវឌ្ឍ និងរៀបចំក្រុងបានលុង។ ដោយសារតែអនាធិបតេយ្យនេះបានធ្វើឱ្យមានផលប៉ះពាល់ទៅដល់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងក្រុងបានលុង។ ចំពោះបញ្ហានេះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដើម្បីជាការធានាដល់សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របស់ប្រជាពលរដ្ឋមិនឱ្យមានអំពើចោរកម្ម លួច ឆក់ ប្លន់ គ្មានក្មេងទំនើងគ្រប់ប្រភេទ គ្មានល្បែងស៊ីសងគ្រប់ប្រភេទ គ្មានអំពើហិង្សា គ្មានបទល្មើសគ្រប់ប្រភេទ គ្មានការជួញដូរស្ត្រី និងកុមារពេស្យាចារ ការជួញដូរមនុស្ស និងគ្មានការជួញដូរគ្រឿងញៀនរួមទាំងចែកចាយគ្រឿងញៀន។[៤១]

ជាក់ស្តែងចំពោះការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាព បរិស្ថាន និងអនាម័យ ជាកត្តាមួយដែលគួរទទួលបាននូវការរៀបចំយកចិត្តទុកដាក់ឱ្យបានល្អប្រសើរដើម្បីលើកកម្ពស់ក្រុងស្អាតក្នុងគោលបំណងផ្តល់ផាសុកភាពសុខុមាលភាពជូនភ្ញៀវទេសចរជាតិ អន្តរជាតិ មកទស្សនា និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ក៏ដូចជាភ្ញៀវដែលបានមកកម្សាន្ត និងស្នាក់នៅផងដែរ។ នៅក្នុងពិភពលោក ទាំងប្រទេសដែលអភិវឌ្ឍន៍ និងប្រទេសដែលកំពុងអភិវឌ្ឍន៍ គឺសុទ្ធសឹងតែយកចិត្តទុកដាក់លើកកម្ពស់សោភ័ណភាពអ្វីដែលជាពិសេសជាងនេះទៅទៀតនោះ គឺអនាម័យ បានល្អ សណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាព ល្អក្នុងក្រុងទើបធ្វើឱ្យខេត្តនិមួយទទួលបាននូវភាពស្រស់ស្អាត និងមានភ្ញៀវទេសចរមកទស្សនាជាច្រើន។ យ៉ាងណាមិញខេត្តរតនគិរីក៏បានផ្តោតសំខាន់ទៅលើការយកចិត្តទុកដាក់បញ្ហាសោភ័ណភាព សណ្តាប់ធ្នាប់ សុវត្ថិភាពរបស់ប្រជាពលរដ្ឋ

[៤១] ផែនការណែនាំ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព, លេខ០២០ ផក, ១៦ សីហា ២០១០, ទំព័រទី២

ឱ្យកាន់តែល្អប្រសើរជាងមុនទៅទៀតតាមរយៈផែនការអនុវត្តន៍ និងការដាក់ចេញនូវផែនការផ្សេងៗដើម្បីកែលម្អសណ្តាប់ធ្នាប់ឱ្យកាត់តែមានភាពល្អប្រសើរ និងឈានទៅមុខគេជាងក្នុងខេត្តចំណោមខេត្តផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២.១.២.១. សន្តិសុខ**

ជាការពិតណាស់មិនថានៅក្នុងខេត្តណាមួយនោះទេ ពាក្យថាសន្តិសុខវាពិតជាមានសារៈសំខាន់ណាស់ព្រោះបើមានសន្តិសុខនៅក្នុងសង្គមនោះប្រទេសនីមួយៗក៏ទទួលបាននូវការរស់នៅបែបសុខសន្តិភាព មិនមានភាពភ័យខ្លាចមានសណ្តាប់ធ្នាប់ល្អក្នុងខេត្តផងដែរ។ ម្យ៉ាងវិញទៀតដើម្បីឱ្យខេត្តមួយមានសណ្តាប់ធ្នាប់ គឺត្រូវធ្វើយ៉ាងណាធានាឱ្យបាននូវ សន្តិភាព សុវត្ថិភាពដែលជាសេចក្តីសុខសាន្ត និងគ្មានភាពចលាចលផ្សេងៗកើតមានឡើង។ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរស់នៅប្រកប ដោយសុវត្ថិភាព និងសន្តិភាព នោះក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ដោយមានការជួយជ្រោមជ្រែង ពីស្ថាប័នជំនាញពាក់ព័ន្ធនានាជាពិសេស ដោយមានការចង្អុលបង្ហាញពីគណៈបញ្ជាការ ឯកភាព រដ្ឋបាលខេត្ត បានបង្ក្រាបសកម្មភាពបទល្មើសផ្សេងៗដូចជាការចែកចាយ និងសេពគ្រឿងញៀន ក្មេងទំនើង ចោរលួច ឆក់ ប្លន់ អំពើហិង្សា ការល្មើសច្បាប់ចរាចរណ៍ផ្លូវគោកនិងបទល្មើសដទៃទៀត ហើយព្រមទាំងបានរៀបចំសណ្តាប់ធ្នាប់ក្នុងឱកាសពិធីបុណ្យផ្សេងៗទៀត។

លើសពីនេះរាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ក្នុងគោលបំណងធានាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋតាមភូមិ ឃុំនីមួយៗ មិនត្រឹមតែរក្សាការពាររូបរាងកាយរបស់បុគ្គលម្នាក់ៗនោះទេ ថែមទាំងទប់ស្កាត់មិនឱ្យកើតមានអសន្តិសុខលើរបស់ទ្រព្យដែលជាកម្លាំងញើសឈាមរបស់ប្រជាពលរដ្ឋ និងមួយវិញទៀតគិតគូរលើសុខភាពអនាម័យរបស់ប្រជាជនថែមទៀតផង។ ជាការពិតណាស់ការការពារសន្តិសុខមិនបានសំដៅត្រឹមតែបរិបទសង្គមនោះទេ ប៉ុន្តែសន្តិសុខបានផ្តោតទៅលើសុវត្ថិភាព បីសំខាន់ៗដែលរួមមាន៖

- **សុវត្ថិភាពបុគ្គល** គឺសំដៅដល់សុវត្ថិភាពរបស់បុគ្គលគ្រប់រូប និងសេរីភាពរបស់បុគ្គលម្នាក់ៗដែលគ្មានការបំពានពីសំណាក់បុគ្គលណាមួយឡើយ ដែលជាហេតុនាំឱ្យមានការបង្កបញ្ហាពោល គឺមានសុវត្ថិភាព និងមានការការពារជូនដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ មួយទៀតយើងអាចឱ្យនិយមន័យថាការពារសុវត្ថិភាពបុគ្គលគឺសំដៅទៅលើទីកន្លែងដែលជាមជ្ឈមណ្ឌលមួយមានមនុស្សរស់នៅប្រកបដោយសេចក្តីសុខទាំងផ្លូវកាយទាំងផ្លូវចិត្ត ឬសុវត្ថិភាពរូបរាងកាយរបស់បុគ្គលម្នាក់ៗត្រូវបានការពារ។ ដោយបញ្ចៀសមិនឱ្យមានការប៉ះពាល់ដល់រូបរាងកាយរបស់ប្រជាពលរដ្ឋដោយកត្តាមួយចំនួនដូចជាក្មេងទំនើង អំពើហិង្សាគ្រប់រូបភាពជាពិសេសបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលបង្កជាភាពព្រួយបារម្ភដល់ប្រជាជនមូលដ្ឋាន រហូតឈានដល់ការដាក់

ចេញនូវយុទ្ធសាស្ត្រ ក្នុងផែនការអភិវឌ្ឍន៍ខេត្តរតនគិរីផងដែរ។ ជាមួយគ្នានេះផងដែរការជំរុញឱ្យមានការពង្រឹងគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព។ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព បានចូលរួមយ៉ាងសកម្មក្នុងការការពារ សុវត្ថិភាពបុគ្គលផងដែរ ហើយគោលនយោបាយនេះមានលក្ខណៈសម្បត្តិ៩មានដូចខាងក្រោម៖

១. គ្មានសកម្មភាពលួច ឆក់ប្លន់ គ្រប់ប្រភេទ។
២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ។
៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ។
៤. គ្មានក្មេងទំនើង។
៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើស គ្រប់ប្រភេទ។
៦. គ្មានគ្រោះថ្នាក់ចរាចរណ៍។
៧. គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។
៨. មានវិធានការណ៍ទប់ស្កាត់គ្រប់គ្រង និងការឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
៩. គ្មានការត្រួតពិនិត្យខុសច្បាប់។[៤២]

ក្នុងនោះបានជំរុញឱ្យមានការពង្រឹងនូវការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ជាពិសេសផ្តោតសំខាន់លើការ គោរពច្បាប់ចរាចរណ៍ ព្រមទាំងរៀបចំនូវដំណោះស្រាយដោយធ្វើយ៉ាងណាឱ្យគ្រោះថ្នាក់ចរាចរណ៍មានការថយចុះដោយមានការបែងចែកជាពីរផ្នែករួមមាន៖

- ប្រជាពលរដ្ឋគោរពច្បាប់ចរាចរណ៍
    - ផ្សព្វផ្សាយច្បាប់ចរាចរណ៍ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
    - ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីផលប៉ះពាល់នៃការបើកបរមានជាតិស្រវឹង
    - ផាកពិន័យតាមច្បាប់ ដែលបានកំណត់ដោយមិនមានការយោគយល់។
- គ្រឿងយន្តមានគុណភាព
    - ពន្យល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់រថយន្តចាស់
    - អនុវត្តច្បាប់ចំពោះប្រជាពលរដ្ឋដែលប្រើប្រាស់រថយន្តកែច្នៃមិនត្រឹមត្រូវតាមបច្ចេកទេស
    - ផ្សព្វផ្សាយពីបច្ចេកទេសត្រួតពិនិត្យគ្រឿងយន្តដល់ប្រជាពលរដ្ឋ។

[៤២] ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព, លេខ០២០, ១៦ សីហា ២០១០

ព្រោះតែបញ្ហានេះតែងតែបង្កការឈឺចាប់ដល់រូបរាងកាយរបស់បុគ្គល ដែលទទួលរងគ្រោះក្នុងហេតុការណ៍ខ្លះប៉ះពាល់ ដល់អាយុជីវិតមនុស្សថែមទៀត ទើបបានជំរុញឱ្យអាជ្ញាធរខេត្តរតនគិរីមានការយកចិត្តទុកដាក់ជាសំខាន់។

- **សុវត្ថិភាពចំណីអាហារ** ការបរិភោគអាហារវាពិតជាមានសារៈសំខាន់ណាស់សម្រាប់មនុស្សដើម្បីទ្រទ្រង់ជីវិត ក៏ប៉ុន្តែប្រសិនបើទទួលទានអាហារដែលគ្មានគុណភាព ឬប្រើប្រាស់បច្ចេកទេសផលិតមិនត្រឹមត្រូវតាមស្តង់ដា វានឹងជះផលអាក្រក់ដល់សុខភាពជាទម្ងន់ ដូច្នេះរាល់អាហារដែលដាក់លក់នៅលើទីផ្សារ ត្រូវមានការត្រួតពិនិត្យគុណភាព ក៏ដូចជាសុពលភាពរបស់មុខទំនិញនីមួយៗឱ្យបានជាក់លាក់។ ម៉្យាងវិញទៀតក្នុងនាមជាប្រជាជនធម្មតា គឺមិនអាចមើលដឹងពីសមាសភាពផ្សំ ដែលប៉ះពាល់ដល់សុខភាពនោះទេ ដូចនេះវាបានក្លាយជា"តួនាទីរបស់មន្ត្រីជំនាញក្នុងការពិនិត្យមើលលើអនាម័យចំណីអាហារដែលវាជាកិច្ចការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន និងរដ្ឋាករកម្ពុជា អាចស្នើសុំសហការពីស្ថាប័នឯកទេសផ្សេងៗ។[៤៣] ក្នុងនោះដែរមានដូចជាក្រសួងសុខាភិបាល គឺនាយកដ្ឋានឱសថ គ្រឿងសំអាង ក្រសួងឧស្សាហកម្ម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម គឺខាងនាយកដ្ឋានសេដ្ឋសាស្ត្រ ដែលគ្រប់គ្រងការនាំចេញថ្នាំសម្លាប់សត្វ និងការចាក់ថ្នាំបង្ការសត្វផងដែរ និងក្រសួងជាច្រើនទៀត ដើម្បីការពារសុវត្ថិភាពខាងចំណីអាហារក៏ត្រូវការមន្ត្រីពាក់ព័ន្ធដទៃទៀតដែរ។
- **សុវត្ថិភាពសម្ភារៈ** សុវត្ថិភាពសម្ភារៈនៅពេលនេះ គឺចង់បានន័យថាមិនត្រឹមតែមិនមានការឆក់ប្លន់នោះទេពោល គឺមានសុវត្ថិភាពដល់សម្ភារៈដែលបម្រើដល់ការរស់នៅរបស់ប្រជាជនរួមមានដូចជាមិនមាននូវការគាស់ផ្ទះ ផ្លោះរបង ឬការគាស់ទូរធនាគារ (ATM) ក្មេងពាល ល្បែងស៊ីសង ឬសកម្មភាពផ្សេងទៀតដែលបង្កឱ្យមានភាពអសន្តិសុខ ដែលធ្វើឱ្យមានភាពភ័យខ្លាចដល់ការរស់នៅរបស់ប្រជាជនភូមិ ឃុំ សង្កាត់ផងដែរ។ ជាមួយគ្នានេះក៏ត្រូវមានសន្តិសុខ សុវត្ថិភាព ដោយមានការយាមពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធបន្ថែមទៀតសម្រាប់ភាពកក់ក្តៅរបស់ប្រជាពលរដ្ឋជាមួយនឹងការការពារដោយការយកចិត្តទុកដាក់ខ្ពស់ជាមួយ និងបញ្ហាសន្តិសុខ។ ការគិតគូរបែបនេះ មិនត្រឹមតែធ្វើឱ្យប្រជាជនមានទំនុកចិត្តនោះទេ ថែមទាំងធ្វើឱ្យជនជាតិបរទេសក៏មានការទុកចិត្តសម្រាប់ទៅទស្សនាផងដែរ ជាពិសេសជាមួយផ្នែកទេសចរណ៍ដែលធ្វើឱ្យមានទំនុកចិត្តជាមួយដំណើរកម្សាន្ត។ លើសពីនេះទៅទៀតកាលណាពួកគាត់មាននូវសុវត្ថិភាពពេលចូលមកដល់ប្រទេសកម្ពុជានោះធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងសម្រាប់ការងារ រកស៊ីបណ្តាក់ទុន ព្រោះជាប្រទេសមួយដែលមានសុវត្ថិភាព ដូច្នេះការរកស៊ីក៏មានសុវត្ថិភាពផងដែរ។ បើស្ថិតនៅក្នុងបរិបទ បែបនេះការវិនិយោគកាន់តែកើនឡើងជាហេតុបណ្តាលឱ្យសេដ្ឋកិច្ចជាតិកាន់តែមានការអភិវឌ្ឍ និងជួយបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋផងដែរ

[៤៣] អនុក្រឹត្យ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ នាំចូលដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា, លេខ២៧ អនក្រ.បក, ២៨ កមរា ២០១៩, មាត្រា២

តាមរយៈទេសចរណ៍ក៏ដូចជាការវិនិយោគ។ ជាក់ស្តែងដើម្បីធានាឱ្យបាននូវសុវត្ថិភាពខាងផ្នែកសម្ភារៈលុះត្រាតែនៅក្នុងមូលដ្ឋាននោះគ្មានសកម្មភាពនៃការប្រព្រឹត្តបទល្មើសផ្សេងៗដូចជា៖

**គ្មានសកម្មភាពភាពនៃការប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់គ្រឿងញៀន** ករណីគ្រឿងញៀនវាជាបញ្ហាដែលបង្កចលាចលដល់សង្គម ជាការពិតបុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀននេះតែងតែមាននូវតម្រូវការថវិកាច្រើនក្នុងការទិញ និងលក់នូវសារធាតុញៀននោះ។ ដោយសារមិនមានប្រាក់គ្រប់គ្រាន់ជាហេតុធ្វើឱ្យបុគ្គលទាំងនោះព្យាយាមរិះរកវិធីយ៉ាងណាដើម្បីទទួលប្រាក់ដែលខ្លួនត្រូវការពេលខ្លះឈានដល់ការគំរាមយកទ្រព្យរបស់អ្នកដទៃទៀតផង។

**គ្មានអំពើលួច ឆក់ ប្លន់ និងការចាប់ជំរិតគ្រប់ប្រភេទ** សំដៅក្នុងមូលដ្ឋានគ្មានការកំហែងយកទ្រព្យរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនដោយពុំមានការអនុញ្ញាតពីម្ចាស់នៃទ្រព្យនោះទេ ឬអំពើដែលអាចបណ្តាឱ្យម្ចាស់ទ្រព្យត្រូវទទួលរងនូវសកម្មភាពនៃអំពើរំលោភបំពានផ្សេងៗថែមទៀតផង។

**គ្មានការលេងល្បែងស៊ីសងខុសច្បាប់** ការប្រព្រឹត្តល្បែងស៊ីសងតែងតែមានការភ្នាល់ដោយប្រើប្រាស់ប្រាក់ហើយគ្រប់ល្បែងស៊ីសងទាំងអស់តែងមានចាញ់ និងឈ្នះ។ ដូច្នេះជាធម្មតានៅពេលដែលមានការចាញ់ល្បែងបុគ្គលដែលប្រព្រឹត្តតែងតែចង់ស្រង់ដើមមកវិញ ដែលសកម្មភាពនេះអាចធ្វើឱ្យឈានដល់ការខាតបង់ទ្រព្យទាំងអស់ ហើយខណៈដែលមកដល់ផ្លូវទាល់ច្រក បុគ្គលមួយចំនួនច្បាស់ជាសម្លឹងឃើញទ្រព្យអ្នកដទៃ និងមានគំនិតចង់បានរបស់ទ្រព្យនោះរហូតដល់អាចប្រព្រឹត្តបទល្មើសផ្សេងៗផងដែរ។

**២.១.២.២. ផាសុកភាព**

ចំពោះផាសុកភាពក៏អាចបណ្តាលមកពីបញ្ហាមួយចំនួននៃការបំពុលបរិស្ថានដែលជាការព្រួយបារម្ភជាចម្បងដែលប្រជាពលរដ្ឋនិងថ្នាក់ដឹកនាំនានាកំពុងជួបប្រទះ។ ទន្ទឹមនឹងនេះផងដែរការអភិវឌ្ឍច្បាស់ណាស់បញ្ហាផ្សេងៗទៀតនឹងកើតឡើងជាមួយគ្នាដែរ ហើយក្នុងចំណោមបញ្ហាទាំងនោះ បរិស្ថាន គឺទទួលរងនូវការគំរាមគំហែង និងប៉ះពាល់ខ្លាំងជាងគេបំផុត។ ករណីនៅក្នុងខេត្តរតនគិរី គឺកំពុងមានការអភិវឌ្ឍដូច្នេះការបំពុលគឺមិនអាចចៀសវាងផុតបានឡើយ គ្រាន់តែទំហំនៃការបំពុលទាំងនោះមានកម្រិតណាមួយ។ ដោយឡែកដើម្បីឱ្យយល់កាន់តែច្បាស់ និងកាត់តែស៊ីជ្រៅយើងគួរតែសិក្សានូវពាក្យគន្លឹះសំខាន់ៗមួយចំនួនជាមុនសិន។

- **ការបំពុល** គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យពុល។[៤៤]
- **សំណល់រឹង** គឺសំដៅទៅលើវត្ថុរឹង សាធាតុរឹង ផលិតផល ឬរបស់កំទេចកំទី ដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។[៤៥]

[៤៤] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[៤៥] អនុក្រឹត្យ ស្តីពីការគ្រប់គ្រង សំណល់រឹង, លេខ៣៦ អនក្រ/បក, ២៧ មេសា ១៩៩៩, មាត្រា៣

- **សំណល់រាវ** គឺសំដៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្ដាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបាន ធ្វើប្រព្រឹត្តកម្មក្ដី។
- **ប្រភពបំពុល** គឺសំដៅទៅលើទីតាំងទាំងឡាយណារួមទាំងលំនៅដ្ឋាន និងអគាររដ្ឋបាលសាធារណៈ ទីបរិវេណមធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្មដែលបញ្ចេញសំណល់រាវសារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ដោយផ្ទាល់ក្ដី ឬមិនផ្ទាល់ក្ដីចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្ដាញលូសាធារណៈ។ ជាទូទៅមូលហេតុដែលនាំឱ្យមានការបំពុលបរិស្ថាន គឺកើតមានឡើងច្រើនករណីដូចជាការបំពុលទឹកដី ខ្យល់ សំឡេង និងសំណង់រឹង រាវ។

❖ **ការបំពុលទឹក**

ទឹកមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់មនុស្សគ្រប់រូបព្រមទាំងជាប្រភពយ៉ាងសំខាន់ដែលមិនអាចខ្វះបានសម្រាប់ទ្រទ្រង់ជីវិតមនុស្សសត្វក៏ដូចជារុក្ខជាតិនានា។ ម្យ៉ាងវិញទៀតទឹកគឺជាប្រភពចំណែកមួយដែលជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចឱ្យជឿនលឿនក្នុងវិស័យ ឧស្សាហកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍ និងតំបន់នៅតាមភូមិរបស់សហគមន៍។ល។ ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមានទៅលើគុណភាពបរិស្ថានបានបង្កឱ្យមានផលវិបាកដល់ជីវិតមនុស្សសត្វដោយសារការប៉ះពាល់សារធាតុគីមីរាប់ម៉ឺនរាប់សែនប្រភេទរួមទាំងកាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗជាច្រើន។ ការបោះកាកសំណល់លាមក ឬសំរាមទៅតាមដងផ្លូវប្រព័ន្ធលូបង្ហូរទឹកជាហេតុនាំឱ្យបរិស្ថានទឹកត្រូវបានបំពុល។ ទឹកពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាមនុស្ស និងបរិស្ថានឱ្យមានសុខភាពល្អដោយផ្ទាល់ ឬដោយប្រយោលក្ដី ហើយការបំពុលអាសេនិចអាចនឹងឱ្យប្រជាពលរដ្ឋរាប់លាននាក់ ប្រឈមនឹងគ្រោះថ្នាក់ប្រសិនបើគ្មានសកម្មភាពណាមួយត្រូវបានអនុវត្ត។ ការបំពុលទឹក គឺជាសកម្មភាពទាំងឡាយដែលធ្វើឱ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម។ ការបំពុលទឹកអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថាន អាស្រ័យទៅតាមកម្រិតនៃការបំពុលភាគច្រើនមាននៅតាមទីកន្លែងសំខាន់មួយចំនួនដូចជា រមណីយដ្ឋាន ក្រុង កម្សាន្ត និងទីសាធារណៈជាដើម។[៤៦]

**ក. មូលហេតុដែលបង្កឱ្យមានការបំពុលទឹក**

ការបំពុលទឹកអាចកើតឡើងតាមរយៈមូលហេតុផ្សេងៗជាច្រើនដូចជា៖

- **កត្តាមនុស្ស** ទាក់ទងទៅនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបរាល់ថ្ងៃដូចជាវិស័យកសិកម្មការប្រើប្រាស់ជីគីមីបានបន្សល់ទុកនៅកាកសំណល់ដោយសារការគ្រប់គ្រងមិនបានត្រឹមត្រូវតាមបច្ចេកទេសដែលនាំឱ្យកាកសំណល់ធ្លាក់ហូចូលប្រឡាយទឹកដែលបណ្ដាលឱ្យបំពុលទឹក។ ចំណែកទឹកស្រះនៅតាមជនបទដែលថ្លានិងគ្មានក្លិនស្អុយ គឺបានប្រើសម្រាប់បរិភោគ និងងូតប៉ុន្តែដោយសារតែមានការបង្ហូរកាកសំណល់ ឬក៏ភាពកខ្វក់

[៤៦] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ដកស្រង់នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

ចេញពីការជីកយករ៉ែដោយក្រុមហ៊ុនក៏ដូចជាកសិដ្ឋានផ្សេងៗនោះនឹងអាចធ្វើឱ្យស្រះទឹកក្លាយជាកខ្វក់ទៅជាមានក្លិនស្អុយ។ ម៉្យាងវិញទៀតការបំពុលបរិស្ថាននៃទឹកគឺជាអ្វីៗដែលនៅជុំវិញខ្លួនយើងហេតុនេះដើម្បីអភិវឌ្ឍន៍ការរស់នៅប្រចាំថ្ងៃបំពេញតម្រូវការអ្នកប្រើប្រាស់ការប្រើសារធាតុគីមីនានាធ្វើឱ្យមនុស្សបានបំផ្លាញបរិស្ថានជាពិសេសប្រភពទឹកនេះតែម្តង។ ដោយយើងសង្កេតឃើញថាមានមូលហេតុជាច្រើនដែលកើតចេញពីសកម្មភាពរបស់មនុស្សបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រភពទឹករួមមានដូចជា៖

- **ការបង្ហូរទឹកកខ្វក់** មិនត្រឹមតែការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រ សហគ្រាស ដែលជាប្រភពនាំឱ្យមានការបំពុលទឹកនោះទេ ប៉ុន្តែក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ យើងក៏ចូល រួមចំណែក ក្នុងការបំពុលដោយប្រយោលផងដែរ។ ទឹកកខ្វក់ទាំងនោះកើតឡើង ពីការប្រើប្រាស់របស់យើងដូចជាការបញ្ចេញទឹកកខ្វក់ពីបន្ទប់ទឹកផ្ទះបាយ ដែលទឹក កខ្វក់ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងប្រភពទឹក ដូចជាបឹង ទន្លេ។ ការបង្ហូរទឹកកខ្វក់ចូលទៅក្នុងប្រភពទឹក គឺជាការបំពុលដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងជាពិសេសនៅរដូវប្រាំងព្រោះរដូវប្រាំងជាប្រភពទឹករាក់ដូចនេះនៅពេលដែលមានការបង្ហូរទឹកកខ្វក់ចូលទៅនោះនាំឱ្យបរិមាណទឹកទន្លេមិនគ្រប់គ្រាន់ក្នុងការបន្សាបទឹកកខ្វក់ដែលហូរចូលជាហេតុនាំឱ្យការបំពុលទឹកមានការប៉ះពាល់ខ្លាំងដល់សុខភាពប្រជាជន។ ជាពិសេសបងប្អូនដែលរស់នៅតាមដងទន្លេសាបដែលពួកគាត់ស្នាក់នៅលើទឹក បន្ទោរបង់ ប្រើប្រាស់ ទឹកទន្លេជាហេតុនាំឱ្យមានការបំពុលទឹកដោយផ្ទាល់។ ដោយឡែកការបង្ហូរទឹកកង្វក់នេះត្រូវមានការប្រុងប្រយ័ត្នជាខ្លាំងទើបជៀសវាងការការប៉ះពាក់យល់ប្រជាពលរដ្ឋ រុក្ខជាតិ ត្រីជាដើម។
- **សំរាម** គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកម្សាន្ត។ល។[៤៧]ទោះជាមានមតិភាគច្រើនបានគិតថាសំរាម គឺមិនសូវមានការប៉ះពាល់ដល់ការបំពុលទឹកប៉ុន្មានទេ ប៉ុន្តែផ្ទុយទៅវិញសំរាម គឺមានផលប៉ះពាល់ខ្លាំងទៅដល់ ប្រភពទឹក។ នៅពេលដែលសំរាមទាំងនោះធ្លាក់ចូល ឬក៏នៅពេលដែលមានភ្លៀងធ្លាក់នោះទឹកដែលហូរចេញពីគំនរសំរាមបានធ្លាក់ចូលទៅក្នុងប្រភពទឹក គឺជាបញ្ហាធំបង្កឱ្យកើតជាបាក់តេរី និងសារជាតិពុលយ៉ាងខ្លាំងដល់សុខភាពអ្នកដែលប្រើប្រាស់។

**កត្តាធម្មជាតិ**

- **អាកាសធាតុ** ជាកត្តាបំពុលបរិស្ថានទឹកផងដែរ គឺតាមរយៈទឹកភ្លៀងព្យុះ។ ដោយសារធាតុអ៊ីដ្រូសែនដែលមានផ្ទុកនៅក្នុងទឹកភ្លៀង គឺបានបំពុលទឹកនៅពេលដែលទឹកភ្លៀងទាំងនោះបានហូរចូលទៅក្នុងប្រភពទឹកស្ទឹង

[៤៧] អនុក្រឹត្យ ស្តីពីការគ្រប់គ្រង សំណល់រឹង, លេខ៣៦ អនក្រ/បក, ២៧ មេសា ១៩៩៩, មាត្រា៣

ស្រះ ឬទន្លេ ហើយអាចនឹងបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗចំពោះសុខភាពអ្នកប្រើប្រាស់។សារធាតុនេះក៏បានបំផ្លាញរុក្ខជាតិព្រមទាំងជីវៈចម្រុះដែលរស់នៅក្នុងទឹកផងដែរ។[៤៨]

## ខ. ផលប៉ះពាល់នៃការបំពុលទឹក

សកម្មភាពមួយចំនួនអាចធ្វើឱ្យមានការបំពុលទឹក ហើយបានជះឥទ្ធិពលដល់មនុស្សសត្វ និងរុក្ខជាតិ។ ដូច្នេះវាបានឆ្លើយតបទៅវិញចំពោះការកង្វះនូវបច្ចេកវិទ្យាដែលសមស្របសម្រាប់សម្អាតកាកសំណល់រឹងដែលបានកែច្នៃផង ឬក៏បណ្តាលមកពីការជីកយករ៉ែរបស់ក្រុមហ៊ុននានា ។ ការបង្ហូរកាកសំណល់ចេញពីលំនៅដ្ឋាន (ការបង្ហូរកាកសំណល់ចេញពីផ្ទះសម្បែង)តាមទីប្រជុំជននានា ឬពីផ្សារហូរទៅក្នុងថ្លុកផ្សេងៗដែលបង្កើតឱ្យមានទឹកស្អុយជាប្រចាំ និងកាកសំណល់ដែលនៅតាមដងផ្លូវរាយប៉ាយជាសាធារណៈមិនសមស្របទើបនៅពេលមានភ្លៀងបាននាំមកនូវកាកសំណល់ទាំងនោះហូរចូលក្នុងទឹកស្ទឹង ស្រះ ឬទន្លេ។

- **ការបំពុលទឹកក្រោមដី**

ទឹកក្រោមដីខ្លះមានការបំពុលកើតឡើងតាមធម្មជាតិរបស់វា។ ការហូរចូលទឹកប្រៃកើតឡើងនៅពេលទឹកសាបត្រូវបានគេបូមចេញពីស្រទាប់សិលាពេលនោះទឹកប្រៃបានហូរពីសមុទ្រមកបំពេញទឹកសាបនៅក្នុងដីដែលបាត់បង់។ បញ្ហាបំពុលដ៏ធ្ងន់ធ្ងរបានកើតឡើងដោយសារតែសកម្មភាពរបស់មនុស្សដូចជាប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតការលាងសម្អាតរថយន្ត និងបោកគក់សម្លៀកបំពាក់ ចំណែកឯការលេចធ្លាយនៃប្រព័ន្ធទឹកស្អុយ និងបង្គន់ក៏អាចបង្កឱ្យមានការបំពុលដល់ប្រភពទឹកក្រោមដីបាន។ គ្រោះថ្នាក់ដ៏ធំបំផុតចំពោះសុខភាព គឺចេញពីវត្តមាននៃសារធាតុអាសេនិចសរីរាង្គនៅតាមតំបន់មួយចំនួនដែលស្ថិតនៅបណ្តោយដងទន្លេសំខាន់ៗ។ បន្ទាប់ពីការបរិភោគទឹកក្រោមដី(ទឹកអណ្តូង)ដែលមានជាតិអាសេនិចមួយរយៈក្រោយមកអ្នកបរិភោគអាចនឹងកើតមានជំងឺម្យ៉ាងហៅថា អាលនីកូស៊ីសដែលអាចបណ្តាលឱ្យស្លាប់បាន។[៤៩]

- **ការបំពុលទឹកភ្លៀង**

មនុស្សភាគច្រើនតែងតែគិតថាទឹកភ្លៀងមានសុវត្ថិភាពសម្រាប់ផឹកតាមពិតវាមិនប្រាកដថាមានសុវត្ថិភាពគ្រប់ពេលនោះទេ ព្រោះនៅតាមតំបន់ដែលមានរោងចក្រឧស្សាហកម្ម មធ្យោបាយធ្វើដំណើរបែបទំនើប (រថយន្ត ទោចក្រយានយន្ត និងគ្រឿងចក្រអាចបង្កឱ្យកើតមានភ្លៀងអាស៊ីតដែលជាប្រភពទឹកដ៏គ្រោះថ្នាក់ដល់សុខភាពមនុស្ស។[៥០]ជាការពិតណាស់ថ្វីត្បិតតែទឹកភ្លៀងជាប្រភពទឹកស្អាតក៏ដោយប្រសិនបើប្រជាជនមិនបានប្រាកដថាទឹកដែលស្តុកទុកនោះស្អាតទេនោះវាប្រាកដជាប៉ះពាល់ដល់ខ្លួនជាក់ជាមិនខាន។

---

[៤៨] គេហទំព័រសុខភាពកម្ពុជា http://www.healthcambodia.com/p6241 ដកស្រង់នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

[៤៩] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣, ទំព័រ៤៣-៤៤

[៥០] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣, ទំព័រ៤៤

### គ. ដំណោះស្រាយពាក់ព័ន្ធ នឹងការបំពុលទឹក

ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកដើម្បីការពារដល់សុខភាពមនុស្ស។[៥១]ការត្រួតពិនិត្យទៅតាមតំបន់ទឹកសាធារណៈជាការដោះស្រាយមួយដែលល្អដើម្បីធ្វើឱ្យបរិស្ថានគ្មានការបំពុលទឹកអ្វីដែលពិសេសនោះគឺជួយឱ្យមានសោភ័ណ្ឌភាព និងប្រកបដោយផាសុកភាពល្អក្នុងការរស់នៅប្រចាំថ្ងៃ។ មួយវិញទៀតគឺក្រសួងបរិស្ថានត្រូវរៀបចំកម្រិតកំណត់ស្តង់ដារបរិមាណសារធាតុពុលទាំងឡាយណាដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានាដោយយោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកលេខ ២៧ អនក្រ បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ មាត្រា១ មាត្រា២។ ម្យ៉ាងវិញទៀតចំពោះអនុក្រឹត្យក៏បានចែងដែរថាក្រសួងបរិស្ថានមានតួនាទី និងទំនួលខុសត្រូវក្នុងការដឹកនាំត្រួតពិនិត្យ និងរាយការណ៍អំពីសកម្មភាពនានាដែលអាចបណ្តាលឱ្យមានការបំពុលជាយថាហេតុ។ ក្រុមហ៊ុន ឬអង្គភាពនានាដែលបញ្ចេញ ឬដឹកជញ្ជូនសំណល់រាវទៅទីដទៃ ចាំបាច់ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក បានចែកប្រភេទប្រភពបំពុលទឹកជាពីរះ

**ប្រភេទទី១** តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០មែត្រគូបក្នុងមួយថ្ងៃ។

**ប្រភេទទី២** ចាំបាច់តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថានមុនពេលបញ្ចេញចោល ឬដឹកសំណល់រាវទៅទីដទៃ។ ចំណែកវិធានការដោះស្រាយសំខាន់ៗដែលគួរតែអនុវត្តឱ្យបានមួយចំនួនទៀតសម្រាប់ប្រជាជនដែលរស់នៅក្នុងខេត្តនៅតាមតំបន់ផ្សេងៗទៀតដែលមានវិធានការសម្រាប់សាធារណៈវាជាកត្តាចាំបាច់បំផុតដើម្បីសម្អាត និងអនាម័យទីក្រុងដោយជំរុញជាលក្ខណៈអប់រំតាមវិទ្យុ ទូរទស្សន៍ និងការបង្កើតទិវាបរិស្ថាន។ ចំណែកវិធានការរៀបចំតាក់តែងច្បាប់គ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវរៀបចំផែនការឱ្យបានល្អច្បាស់លាស់សម្រាប់គ្រប់គ្រងសំណល់គ្រប់ប្រភេទ។ បច្ចុប្បន្ននេះការចែងពីបទបញ្ញត្តិបានចេញរួចហើយក៏ពិតមែនតែនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេដូច្នេះស្ថាប័នដែលត្រួតពិនិត្យ និងគ្រប់ម្ចាស់ដែលបំពុលទឹកត្រូវចូលរួមគោរព និងពង្រឹងច្បាប់នេះឱ្យបានប្រសើរឡើង។ ហេតុដូច្នេះដើម្បីឱ្យមានសោភ័ណភាពទីក្រុង និងរួមទាំងមានសណ្តាប់ធ្នាប់ និងបរិស្ថានរស់នៅបានល្អមនុស្សទាំងអស់គួរចូលរួមចំណែកដោយបំពេញភារកិច្ចក្នុងការកែប្រែនៃការបំពុលទឹកឱ្យមានជាសុខភាព។

- **ការបំពុលខ្យល់**

បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្សសត្វនានា នៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ ការបំពុលខ្យល់ គឺជាការបង្កើតឡើងដោយ សារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្តាលឱ្យ

[៥១] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ២៧ មេសា ១៩៩៩, មាត្រា១

មានផលប៉ះពាល់ដល់មនុស្ស ឬភាវៈ មានជីវិតទាំងឡាយ ព្រមទាំងបំផ្លាញដល់បរិស្ថានក្នុង បរិយាកាស។ សរុបមកវិញ ការបំពុលខ្យល់ត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់មនុស្ស និងឋានប្រព័ន្ធនានានៅលើផែនដី។[៥២]បន្ថែមពីនេះទៅទៀតនៅក្នុងបរិយាកាសគេរកឃើញមានភ្នាក់ងារបំពុលរាប់រយប្រភេទ។ ប៉ុន្តែមានតែសារធាតុបំពុលចំនួន៥ប៉ុណ្ណោះដែលត្រូវបានប្រទេសមួយចំនួនតាមដានអង្កេតជាប្រចាំ និងត្រូវបានគេប្រើជាសញ្ញាចង្អុលបង្ហាញពីគុណភាពនៃខ្យល់។ ហើយសារធាតុទាំងនោះមានដូចជា អុកស៊ីត ស្ពាន់ធ័រឌីអុកស៊ីតអាសូត អុកស៊ីត អូសូន និងភាគល្អិតអណ្តែតវិលវល់ដែលបញ្ចេញពីយានយន្ត ឬមធ្យោបាយដឹកជញ្ជូន ចំរុះអុស ធ្យូងការបាចដីការជុតកាកសំណល់ធូលីដីជាដើម។[៥៣]នៅពេលដែលកំហាប់របស់ឧស្ម័ន្ធទាំងនេះនៅក្នុងខ្យល់កើនឡើងលើសពីកម្រិតកំណត់ណាមួយនោះខ្យល់ត្រូវរងការបំពុល ហើយដែលផ្តល់គ្រោះថ្នាក់ដល់ការដកដង្ហើម។ ការបំពុលខ្យល់នៅក្នុងតំបន់សហគមន៍ ឬក្នុងភូមិ ស្រុកក៏ដូចជានៅក្នុងខេត្តរតនគិរីទាំងមូលគឺបណ្តាលមកពីមូលហេតុមួយចំនួនដូចជា៖

- **ការបំពុលចេញពីយានយន្តគ្រប់ប្រភេទ** ចំពោះការបំពុលយានយន្តនៅក្នុងខេត្តរតនគិរី ពុំសូវមានការបំពុលខ្លាំងទេ ដោយសារតែចំនួនប្រជាជននៅក្នុងក្រុងបានលុងមាន ចំនួនមិនសូវច្រើនទេដូចនេះតម្រូវការនៃការប្រើប្រាស់ យានយន្តនៅក្នុងការធ្វើដំណើរក៏មានមិនសូវជាច្រើនដែរ តែយ៉ាងណាក៏ដោយយើងសង្កេតឃើញថាមានយានយន្តមកពីខាងក្រៅជាច្រើនដែលជាហេតុនាំឱ្យមានកម្រិតផ្សែងពុលដែលចេញពីយានយន្តទាំងនោះត្រូវបាន បញ្ចេញទៅក្នុងបរិយាកាសដែលនាំឱ្យការបំពុលខ្យល់មានកម្រិតមធ្យម។ លើសពីនេះទៅទៀតក៏សង្កេតឃើញថានៅក្នុងប្រទេសកម្ពុជា ភាគច្រើនប្រើប្រាស់នូវយានយន្ត ចាស់ៗដែលនាំចូលពីបរទេសដែលវាអាចបញ្ចេញផ្សែងពុលទៅក្នុងបរិយាកាសច្រើន ជាងយានយន្តថ្មី។
- **ការបំពុលដោយធូលីដី** គឺជាមូលហេតុដែលគួរឱ្យកត់សម្គាល់មួយដែលបង្កឱ្យមានការបំពុលខ្យល់។ ភាគច្រើនធូលីដីនៅក្នុងក្រុងបានលុងបណ្តាលមកពីការរៀបចំ ឬគ្រប់គ្រងសំរាមមិនបានល្អ និងសំណង់សម្រាប់សាងសង់គេហដ្ឋានផ្សេងៗនៅពេលដឹកជញ្ជូនមិនបានត្រឹមត្រូវដូចជាការដឹកខ្សាច់ ដី ស៊ីម៉ង់ជាដើម ហើយការដែលធ្វើឱ្យធ្លាក់ ឬប៉ើងតាមខ្យល់ ជាហេតុបង្កឱ្យមានការបំពុលខ្យល់។ ម្យ៉ាងវិញទៀតការទុកដាក់គ្រឿងសំណង់ផ្ទាល់នៅលើផ្លូវក៏ជាហេតុបង្កមួយនៃការបំពុលខ្យល់ព្រោះវានឹងធ្វើឱ្យផ្លូវពោរពេញទៅដោយធូលី។
- **ការបំពុលដែលចេញពីចំហេះអុស ធ្យូង** ការប្រើប្រាស់អុសធ្យូងជាប្រភពថាមពលចម្អិនអាហារគឺជាទំនៀមទម្លាប់មួយរបស់ប្រជាជនខ្មែរ និងប្រជាជន ព្រមទាំងជនជាតិដើមភាគតិចដែលពួកគាត់តែងតែប្រើអុសសម្រាប់ចម្អិនអាហារ។ ទោះជាអ្នករស់នៅក្នុងខេត្តក៏ដោយការប្រើប្រាស់អុសធ្យូងនៅតែជាវិធីពេញនិយមក្នុងការ

[៥២] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣ ទំព័រ៣៨
[៥៣] សៀវភៅបរិស្ថានជំនួយស្មារតី ឆ្នាំ២០០៥

ចម្អិនអាហារ។[៥៤] ការប្រើប្រាស់អុសធ្យូងនេះ គឺមានផលប៉ះពាល់ជាខ្លាំងសម្រាប់បរិស្ថានពីព្រោះចំហេះនៅក្នុងអុសធ្យូងបានបង្កើតនូវឧស្ម័នកាបូណាត្សួមទាំងឧស្ម័នពុលដ៏ច្រើនចូលក្នុងបរិយាកាស ហើយឧស្ម័នពុលទាំងនោះ គឺប៉ះពាល់ខ្លាំងណាស់ដល់ភាពខ្យល់។[៥៥]

**គ. ដំណោះស្រាយនៃការបំពុលខ្យល់**

ជាទូទៅបញ្ហាក្នុងការបំពុលខ្យល់ត្រូវបានចាត់ចែង និងគ្រប់គ្រងដោយក្រសួងបរិស្ថានដែល មានតួនាទីក្នុងការត្រួតពិនិត្យ និងអនុញ្ញាតទៅលើការបញ្ចេញខ្យល់ដែលអាចផ្តល់ផលប៉ះពាល់ទៅ ដល់បរិស្ថាន។ បន្ថែមពីនេះទៅទៀត គុណភាពរបស់ខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានត្រួតពិនិត្យ និងតាមដានជាប្រចាំដោយក្រសួងបរិស្ថាន។[៥៦] ហើយកត្តាបំពុលខ្យល់ជាទូទៅ ត្រូវបង្កើតឡើងភាគច្រើនដោយសារមនុស្សជាកត្តាចម្បង ដូច្នេះដំណោះស្រាយអាចមានដូចតទៅៈ

- **កត្តារាជរដ្ឋាភិបាល** រាជរដ្ឋាភិបាល គឺជាកត្តាមួយដែលសំខាន់ចម្បងមួយក្នុងការចូលរួមកាត់បន្ថយការបំពុលខ្យល់ ដោយត្រូវគ្រប់គ្រងឱ្យបាននូវការបញ្ចេញនូវឧស្ម័នពុល ឬការបញ្ចេញនូវផ្សែងនានាដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនទាំងអស់ឱ្យមានកម្រិតស្តង់ដារ ឬជំរុញឱ្យមានម៉ាស៊ីនបន្សុទ្ធខ្យល់មុនពេលបញ្ចេញខ្យល់ដែលមានសារធាតុពុលទាំងនោះនៅក្នុងខ្យល់។ ដែលបានចេញវិធានការឱ្យបញ្ឈប់ការដុតកាក់សំណល់ និងផ្លាស្ទិចគ្រប់ប្រភេទព្រោះការដុតកាកសំណល់ពិតជាធ្វើឱ្យមានការបំពុលខ្យល់ធ្ងន់ធ្ងរដល់ផ្លូវដង្ហើម។ បញ្ឈប់ការបូជសពក្នុងវត្តអារាមដែលនៅក្នុងក្រុងដោយបញ្ហាខ្យល់ពុលដែលបញ្ចេញពីយានដ្ឋានគឺជាខ្យល់ដែលពោរពេញទៅដោយមេរោគ បាក់តេរី និងជាតិពុលដែលចេញពីសរីរាង្គកាយមនុស្ស។ រដ្ឋាភិបាលក៏គួរតែរៀបចំឱ្យមានមធ្យោបាយដឹកជញ្ជូនសាធារណៈឱ្យបានច្រើនជាងប្រើប្រាស់យានយន្តផ្ទាល់ខ្លួនច្រើននាំឱ្យផ្សែងដែលចេញពីយានយន្តមានបរិមាណច្រើនលើសលុប។
- **កត្តាប្រជាជន** ប្រជាជនជាកត្តាមួយដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារបរិស្ថានដោយកាត់បន្ថយនូវការប្រើប្រាស់អុសធ្យូងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃឱ្យបានតិចបំផុត។ បញ្ឈប់ការដុតកាកសំណល់ដើម្បីកាត់បន្ថយការបំពុល ហើយត្រូវងាកមកកែច្នៃ ឬប្រើប្រាស់ឡើងវិញនូវកាកសំណល់ទាំងនោះចៀសវាងការដុតដែលនាំឱ្យមានឧស្ម័នបំពុលខ្លាំងប៉ះពាល់ដល់ស្រទាប់អូហ្សូន។ ប្រជាជនគួរតែងាកមកប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈវិញជាជាងប្រើប្រាស់រថយន្តផ្ទាល់ខ្លួនដើម្បីកាត់បន្ថយយានយន្តនៅតាមដងផ្លូវក៏ដូចជាកាត់បន្ថយនូវផ្សែងបំពុលផងដែរ។

---

[៥៤] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment, ទំព័រ២

[៥៥] មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្តាន់ វិន, ទំព័រ១៣៩

[៥៦] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា២៦

❖ **ការបំពុលសំឡេង**

សំឡេង គឺជាផ្នែកមួយដែលធ្វើឱ្យមានការបំពុលទៅដល់បរិស្ថាន។ ក្នុងនោះផងដែរបានសង្កេតឃើញថាខេត្តរតនគិរីជាខេត្តមួយដែលទទួលរងនូវការបំពុលសំឡេង ដោយការបំពុលសំឡេងនោះបណ្តាលមកពីកត្តាមួយចំនួនដូចជាយានយន្ត ក្លឹបកំសាន្ត តន្ត្រី រោងចក្រ រឺឯការសាងសង់ការដ្ឋាន ឬសំណង់អាគារជាដើម។ សូរសំឡេងទាំងនេះអាចធ្វើឱ្យមានការហត់ហេវអស់កម្លាំងខាងផ្លូវចិត្តការមួរមៅតប់ប្រមល់ និងការខូចខាតសោតវិញ្ញាណ។ យោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់នឹងការរំខានដោយសំឡេងការបំពុលដោយសំឡេងមានប្រភពពីរ គឺប្រភពចល័តដែលជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មានយន្តហោះនាវាដឹកជញ្ជូនគ្រឿងយន្តនិងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ និងប្រភពដោយអចល័ត ជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍រួមមានដូចជារោងចក្រ សហគ្រាស ឃ្លាំង ស្តុកសម្ភារៈ ការដ្ឋានសំណង់ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។

➢ **ការបំពុលសំឡេងដោយប្រភពចល័តក្នុងខេត្តរតនគិរី**

ការបំពុលសំឡេងដោយប្រភពចល័តនេះគឺសំដៅទៅលើការបំពុលដោយសំឡេងចេញពីយានយន្តនៅលើផ្លូវសាធារណៈ។ ដោយសារតែកត្តាយាន្តយន្តមួយចំនួននៅក្នុងខេត្តរតនគិរី ហើយខេត្តរតនគិរីជាខេត្តមួយដែលកំពុងតែមានការអភិវឌ្ឍនឹងទទួលបានការវិនិយោគដូចជាផ្ទះល្វែងជាដើម ដែលជាកត្តាមួយតម្រូវឱ្យមានការដឹកជញ្ជូនធុន់ៗកត្តានេះហើយដែលនាំឱ្យសំឡេងក៏មានការកើនឡើងដែរ ដែលនាំឱ្យការបំពុលដោយសំឡេងក៏កាន់តែខ្លាំងផងដែរ។

➢ **ការបំពុលសំឡេងដោយប្រភពអចល័តក្នុងខេត្តរតនគិរី**

ចំពោះការបំពុលសំឡេងដោយប្រភពអចល័ត គឺសំដៅទៅលើប្រភពបំពុលដែលចេញពីទីតាំងជាក់លាក់ណាមួយដែលមិនមានបំលាស់ទីដូចចល័តនោះទេ។ ម្យ៉ាងវិញទៀតប្រភពបំពុលអចល័តក្នុងខេត្តរតនគិរីអាចបណ្តាលមកពីរោងចក្រ សហគ្រាស កន្លែងកម្សាន្ត កន្លែងសិប្បកម្ម ការដ្ឋាន សំណង់ជាដើម។ ជាក់ស្តែងសំឡេងបុកគ្រឹះនៅការដ្ឋានសំណង់ ឬតន្ត្រីនៅក្លឹបកំសាន្តរាត្រី ក្លឹបរាំកំសាន្តជាដើមកំពុងតែធ្វើឱ្យមានការបំពុលជារៀងរាល់ថ្ងៃ។

កត្តាទាំងឡាយខាងលើនេះ គឺជាបញ្ហាដែលកើតមានសព្វថ្ងៃនេះមិនថាជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ តួយ៉ាងការបំពុលសំឡេងដូចលើកឡើងខាងលើវាជាបញ្ហាសំខាន់ដែលប្រទេសមួយចំនួនយកចិត្តទុកដាក់។ ដោយឡែកបញ្ហាទាំងនេះចំពោះប្រទេសកម្ពុជាវិញ គឺមានតិចតួចបំផុតដែលសំឡេងទាំងអស់នោះមិនត្រូវបានកើតជាបញ្ហាធំដុំនោះទេ ក៏ដោយសារតែបច្ចុប្បន្ននេះប្រជាពលរដ្ឋមានការយល់ដឹង

ច្រើន ហើយសំឡេងដែលសព្វថ្ងៃគេចាត់ទុកជាបញ្ហានោះ ដូចជារថយន្តរកស៊ីដោយការផ្សាដែកឈូសឈើក្លឹបខារ៉ាអូខេទាំងនេះ គឺជាបញ្ហាដែលកម្ពុជាកំពុងជួប។

### ក. ផលប៉ះពាល់នៃការបំពុលដោយសំឡេង

សំឡេងត្រូវបានក្លាយជាផ្នែកធម្មជាតិមួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ ផលប៉ះពាល់ការបំពុលដោយសារសំឡេងវាបានជះឥទ្ធិពលអាក្រក់ដល់យើងទាំងអស់គ្នាដូចជា៖

- មានភាពពិបាកក្នុងការរៀនសូត្រការបំពុលដោយសំឡេងនេះ គឺពិតជាផ្តល់ផលអាក្រក់ទាំងមនុស្សធំទាំងកុមារតូចៗដែលបានប្រឈមនឹងសំឡេងរំខានជាប្រចាំ និងមានបញ្ហាពិបាកក្នុងការសិក្សាដោយសារតែការបង្កឱ្យមានការបំពុលសំឡេងឡានសំឡេងតន្ត្រី ឬយន្តហោះ។ល។[៥៧]
- អាចបណ្តាលឱ្យគេងមិនលក់ដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជននៅក្នុងតំបន់ផ្សេងៗគ្នា ដោយសារតែការគេងមិនលក់មនុស្សមិនអាចអនុវត្តការងារបាន ឬសកម្មភាពក្នុងផ្ទះប្រកបដោយប្រសិទ្ធភាពទេ។ លើសពីនេះទៅទៀតការប៉ះពាល់នឹងសំឡេងខ្លាំងៗ ទាំងនេះក៏អាចបណ្តាលឱ្យខូចខាតដល់សរីរាង្គនៃការស្តាប់ការបំផ្លាញកោសិកាបន្តិចម្តងៗដែលធ្វើឱ្យខូចខាត់ដល់បុគ្គលម្នាក់ៗនៅក្នុងការងារ និងការអនុវត្តការងាររបស់ពួកគេក៏ដូចជានៅក្នុងទំនាក់ទំនងសង្គមពួកគេផងដែរ។[៥៨]

### ខ. វិធានការការពារដោយបំពុលសំឡេង

ដោយយោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យ ការបំពុលខ្យល់ និងការរំខានដោយសំឡេងបានកំណត់អំពីការត្រួតពិនិត្យនូវសំឡេងរំខានពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៥៩]ចំពោះការត្រួតពិនិត្យនូវការរំខានដោយសំឡេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[៦០]

### ❖ កាបំពុលដី

ការបំពុលដី គឺជាការធ្វើឱ្យខូចបាត់បង់ជីវជាតិ និងបណ្តាលឱ្យមនុស្សសត្វ និងរុក្ខជាតិពិបាក និងរស់រានមានជីវិត ឬក៏ឈានទៅដល់ការបាត់បង់ជីវិតក៏មានដែរ។ ចំពោះការបំពុលដីវាអាចរងផលប៉ះពាល់ដីដែលជាសមាសធាតុសំខាន់បំផុតនៃជីវមណ្ឌល និងកំណត់ដំណើរការជាច្រើនដែលកើតឡើងនៅក្នុងវាគឺជាមូលដ្ឋានសម្រាប់ការតាំងទីលំនៅរបស់មនុស្សដូច្នេះហើយផលវិបាកនៃការបំពុលដីត្រូវបានរារាំងតាមដែលអាចធ្វើទៅ

[៥៧] គេហទំព័រ https://thmeythmey.com/?page=detail&id=103631 ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

[៥៨] គេហទំព័រ https://km.warbletoncouncil.org/tipos-contaminacion-acustica-16274 ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

[៥៩] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា១៧

[៦០] អនុក្រឹត្យ លេខ៤២ អនក្រ.បក, មាត្រា១៨

បាន។ ម្យ៉ាងវិញទៀតការបំពុលសំខាន់ៗនៃគម្របដី គឺជីរ៉ែថ្នាំសម្លាប់សត្វល្អិតការបំភាយឧស្ម័នព្រមទាំងផ្សែងទៅក្នុងបរិយាកាសកាកសំណល់ផលិតកម្មប្រេង និងផលិតផលប្រេង។ ថ្នាំសម្លាប់សត្វល្អិត គឺជាសារធាតុគីមីដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងវិស័យកសិកម្មដើម្បីកំចាត់ស្មៅ និងសត្វល្អិតកកកុញនៅក្នុងដីពួកវាអាចឆ្លងតាមខ្សែសង្វាក់អាហារ និងបង្កជាជំងឺធ្ងន់ធ្ងរដល់សត្វ និងមនុស្ស។ ការផលិតថ្នាំសម្លាប់សត្វល្អិតកំពុងកើនឡើងឥតឈប់ឈរនៅក្នុងពិភពលោកដែលជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់សុខភាព។ មិនតែប៉ុណ្ណោះការជីរ៉ែក៏អាចបណ្តាលឱ្យមានការបំពុលដី និងផលវិបាករបស់វាផងដែរ។ វាកើតឡើងដោយសារតែការប្រើប្រាស់របស់ពួកគេក្នុងបរិមាណមិនសមហេតុផលជាមួយនឹងការខាតបង់ក្នុងអំឡុងពេលផលិតកម្ម ឬការដឹកជញ្ជូន។[៦១]

**មូលហេតុនៃការបំពុលដីជាទូទៅឃើញមានកត្តាមួយចំនួនដូចខាងក្រោមៈ**

• **កត្តាកសិកម្ម** មូលហេតុនៃការបំពុលដីចំពោះវិស័យកសិកម្មគឺភាគច្រើនទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលហួសកម្រិតសម្រាប់ការពារដំណាំ ឬការប្រើប្រាស់សារធាតុពុលហួសកម្រិតដែលធ្វើឱ្យសារធាតុពុលទាំងនោះស្ថិតនៅក្នុងដីបង្កឱ្យមានជីវជាតិនៃការបំពុលកាន់តែច្រើន និងធ្វើឱ្យដីនោះពោរពេញទៅដោយសារធាតុពុលតែម្តង។ ដោយឡែកជាក់ស្តែងនៅក្នុងខេត្តរតនគិរីផ្ទាល់តាមភូមិសហគមន៍ទាំងមូលដែលមានដីសម្រាប់ធ្វើកសិកម្មហេតុនេះការបំពុលដីដោយកសិកម្មក៏មានផលប៉ះពាល់យ៉ាងធ្ងន់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋផងដែរ។

• **កត្តាមនុស្ស** សំរាមគឺជាមូលហេតុមួយដែលបណ្តាលឱ្យមានការបំពុលដីនៅពេលដែលមនុស្សមិនបានយកចិត្តទុកដាក់ក្នុងការវេចខ្ចប់សំរាមឱ្យមានរបៀបរៀបរយដោយបែងចែករវាងសំរាមសរីរាង្គ និងសំរាមកែច្នៃ។ នៅពេលដែលសំរាមត្រូវគេគរទុកចោលនៅកន្លែងណាមួយដូចជានៅទីលានចាក់សំរាមជាដើម គឺបណ្តាលឱ្យដីនៅតំបន់នោះបាត់បង់នូវជីវជាតិសម្បូរទៅដោយមេរោគ និងបាក់តេរីគ្រប់ប្រភេទជាហេតុបង្កឱ្យមាននូវជាតិពុលនៅក្នុងដី។[៦២]

## គ. ដំណោះស្រាយពាក់ព័ន្ធ និងការបំពុលដី

វាចាំបាច់ដើម្បីបញ្ជាក់ថាវាមានសារៈសំខាន់បំផុតនៅក្នុងការលើកឡើងនូវអនុសាសន៍មួយចំនួនមុននឹងឈានដល់ការបំពុលដី និងមិនត្រូវប៉ះពាល់ដល់បរិស្ថានទេ និងការផ្លាស់ប្តូរដំណើរនៃធម្មជាតិ ដែលត្រូវបានគូសបញ្ជាក់ខាងក្រោមៈ

[៦១] គេហទំព័រ https://ik-ptz.ru/ ដកស្រង់នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

[៦២] គេហទំព័រ www.youtube.com (land pollution) ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣

- ជៀសវាងការដុតសំរាម ឬសំរាមនៅលើដី ហើយសម្រាប់ហេតុផលដូចគ្នានេះអ្នកមិនគួរប្រើគ្រាប់រ៉ុក្កែតកាំជ្រួចឡើយ។
- រថយន្ត ឬម៉ូតូត្រូវថែទាំ និងរក្សាទុកក្នុងស្ថានភាពល្អដើម្បីព្យាយាមកាត់បន្ថយការបំពុលដី ត្រូវយកចិត្តទុកដាក់ជាមួយការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន។
- ជៀសវាងការចោលសំរាម និងកាកសំណល់ដោយផ្ទាល់លើដី និងជៀសវាងការជក់បារី ឬត្រូវកាត់បន្ថយការប្រើប្រាស់ក្នុងករណីដែលមិនអាចធ្វើវាបាន ដោយសារភាគច្រើននៃអ្នករស់នៅលើភពផែនដីបានប្រតិបត្តិវាដោយភាពធម្មតាដ៏អស្ចារ្យ និងបណ្តេញផ្សែងពុលកន្ទុយបារី គឺសំដៅដល់ភ្នាក់ងារនៃការបំពុលដីដ៏ធំបំផុត។ ដោយសារតែកន្ទុយបារីមានសារធាតុដែលបញ្ចេញចេញពីប្រេងក្នុងចំណោមសារធាតុផ្សេងៗហើយជាកត្តាបង្កឱ្យមានអគ្គិភ័យ។
- កាត់បន្ថយការប្រើប្រាស់ផលិតផលសម្អាតនៅក្នុងផ្ទះដែលមានជាតិគីមីទាំងស្រុង ព្រមទាំងមានផលិតផលធម្មជាតិមួយចំនួនធំដែលមានជាតិគីមីធម្មជាតិ និងគ្មានជាតិពុលដែលមិនប៉ះពាល់ដល់បរិស្ថាន ប៉ុន្តែក៏អាចប្រើបានសម្រាប់អនាម័យ និងលាងសម្អាតផងដែរ។ ទន្ទឹមនឹងនោះការប្រើប្រាស់ទឹកធម្មជាតិអាចផ្តល់អត្ថប្រយោជន៍ដល់ទឹកដែលប្រើប្រាស់ក្នុងការសម្អាតដើម្បីស្រោចស្រព។[៦៣]
- ប្រើប្រាស់ធុងសម្រាប់កែច្នៃឡើងវិញ ប៉ុន្តែក្នុងករណីដែលមិនទទួលស្គាល់ថាធុងកែច្នៃមួយណាសូមបោះចោលត្រង់ចំណុចស្អាត ឬចំណុចពណ៌បៃតង។
- ការសម្អាតដីគឺជានីតិវិធីមួយដែលអាចជួយឱ្យដីក្រោមដីដែលមានមេរោគ នៅពេលមានខ្យល់។

❖ **ការបំពុលដោយសំណល់រឹង និងរាវ**

តាមការពិតយើងបានដឹងពីប្រភពនៃសំណល់រឹងដែលចេញមកពីលំនៅដ្ឋាន ទីផ្សារ អគារពាណិជ្ជកម្មមជ្ឈមណ្ឌលផ្គត់ផ្គង់ស្បៀងអាហារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ និងអ្នកលក់ដូរតាមដងផ្លូវសាធារណៈ តំបន់ទេសចរណ៍ និងកន្លែងផ្សេងៗទៀត ។ សំណល់រឹងទាំងនេះគេសង្កេតឃើញមានជាច្រើនមុខដូចជា ក្រដាស ថងប្លាស្ទិច សំណល់អាហារ កម្ទេចកំណក់ សំពត់ បន្លែ ផ្លែឈើ កម្ទេចដែក សំបកកំប៉ុងសំបកដបជាដើម។ ជារៀងរាល់ថ្ងៃ គឺតែងតែមានសំរាមជាច្រើនដែលត្រូវបោះចោលទោះជាសំរាមប្រភេទណាក៏ដោយការដែលទុកដាក់សំរាមមិនបានល្អអាចធ្វើឱ្យមានមេរោគនៅក្នុងសំរាមជាហេតុធ្វើឱ្យប៉ះពាល់ដល់ជីវិតមនុស្សរស់នៅ។ការបំពុលដោយសំណល់អាចធ្វើការបែងចែកជាពីរទីមួយសំណល់រឹងទីពីរសំណល់រាវ។

---
[៦៣] គេហទំព័រ https://www.postposmo.com ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣

- **សំណល់រឹង** គឺជារបស់របរ ឬក៏វត្ថុទាំងឡាយណាដែលស្ថិតនៅក្នុងភាពរូបរឹងដែលពុំមានតម្លៃសម្រាប់ការប្រើប្រាស់តទៅទៀត ហើយត្រូវបានគេបោះបង់ចោលទៅក្នុងបរិស្ថាន។ សំណល់រឹងរួមមាន ក្រដាស់ ថង់ប្លាស្ទិច ក្រណាត់លោហៈ ផ្សេងៗ សំបកកំប៉ុង បន្លែ ផ្លែឈើ សំណល់ចេញពីវិទ្យុសកម្ម។[៦៤]
- **សំណល់រាវ** សំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុលហូរចូលទៅក្នុងតំបន់សាធារណៈ ឬហូរចូលទៅក្នុងបណ្ដាញលូសាធារណៈទោះបីជាបាន ឬមិនបានធ្វើប្រតិកម្មក្ដី។[៦៥]អាចនិយាយម្យ៉ាងវិញទៀតថាសំណល់រាវ គឺសំដៅដល់វត្ថុរាវដែលជាសារធាតុរាវរួមផ្សំគ្នាជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានបោះបង់ចោលជាប្រចាំថ្ងៃទៅតាមប្រព័ន្ធលូទឹកស្អុយផ្សេងៗ។[៦៦]

ចំពោះក្នុងខេត្តរតនគិរីយើងឃើញថានៅតាមទីផ្សារលក់ដូរ ឬនៅដងផ្លូវក៏ដូចជានៅតាមមុខផ្ទះរបស់ប្រជាពលរដ្ឋឃើញថាកាកសំណល់ជាច្រើនប្រភេទមិនបានរៀបចំឱ្យមានរបៀបរៀបរយទៅតាមលំដាប់លំដោយនៃសំរាមនោះទេ។ ការគ្រប់គ្រងសំណល់រឹង រាវ នៅតំបន់នេះមានកម្រិតនៅឡើយ ហើយការដែលនៅលំដាប់នេះ មិនមានការរៀបចំសំណល់រឹង រាវឱ្យមានសណ្ដាប់ធ្នាប់គឺមកពីមូលហេតុចម្បងមួយចំនួនគឺ៖

- ប្រជាជនរស់នៅក្នុងតំបន់នេះពុំសូវយល់ដឹងពីបញ្ហាសំណល់រឹង និងរាវ
- មានការលាយលំសំណល់រឹង និងរាវជាគ្នាក្នុងថង់តែមួយដែលបណ្ដាលឱ្យសំណល់ទាំង២ប្រភេទនេះក្លាយជាល្បាយ។
- ការចោលសំរាមពុំមានបែងចែកនូវប្រភេទច្បាស់លាស់ ហើយការប្រមូលផ្ដុំចោលសំណល់ជាល្បាយនេះក៏អាចលាយលំជាមួយសំណល់ដែលមានលក្ខណៈជាសរីរាង្គដែលងាយនឹងរលួយធ្វើឱ្យមានក្លិនមិនល្អ ស្អុយ និងបំពុលទៅដល់ដីដែលជាទីតាំងចោលសំរាម និងធ្វើឱ្យប៉ះពាល់សុខភាព និងខូចសុខភាពរបស់ប្រជាពលរដ្ឋទៀតផង។

### ខ. ផលប៉ះពាល់នៃការបំពុលសំណល់រឹង រាវ

- **ផលប៉ះពាល់ដល់មនុស្ស** មិនថាសំណល់រឹង ឬរាវទេ ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានល្អវាធ្វើឱ្យប៉ះពាល់ដល់គុណភាពជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សហើយការចាក់ចោលសំរាមមិនបានត្រឹមត្រូវវាអាចបង្កើតជាប្រភពចម្បងដល់ការរីករាលដាលនៃជំងឺផ្សេងៗជាច្រើនប្រភេទដូចជាជំងឺគ្រុនពោះវៀនជំងឺគ្រុនចាញ់។ មិនតែប៉ុណ្ណោះសារធាតុគីមីផ្សេងៗទៀត ដែលបានមកពីសំណល់ឧស្សាហកម្ម និងសំណល់ដ៏ទៃទៀត គឺវាអាចស្រូបចូលក្នុងខ្លួនរបស់មនុស្សតាមរយៈការដកដង្ហើម ឬការបរិភោគ ឬការប៉ះពាល់វា។ មេរោគដែលបង្កដោយសំរាម

[៦៤] គេហទំព័រ https://www.khsearch.com/qna/5780 ដកស្រង់នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣

[៦៥] គេហទំព័រសុខភាពកម្ពុជា WWW.healthcambodia.com ដកស្រង់នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣

[៦៦] គេហទំព័រ https://seylanote.wordpress.com ដកស្រង់នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣

គឺអាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្សវាមិនត្រឹមតែអាចមានជំងឺរុំរ៉ៃ ឬមហារីកប៉ុណ្ណោះទេ វាអាចបណ្តាលឱ្យមនុស្សបាត់បង់ជីវិតបានថែមទៀតផង។

- **ផលប៉ះពាល់ដល់បរិស្ថាន** ប្រសិនបើការគ្រប់គ្រងសំរាមមិនបានល្អទេនោះ វានឹងនាំឱ្យប៉ះពាល់ដល់បរិស្ថានដល់សុខភាពមនុស្សដោយផ្ទាល់ និងដោយប្រយោល។ ដោយផ្ទាល់មានដូចជាការបរិភោគចំណីអាហារ ឬហូបទឹក ឬសារធាតុផ្ទាល់ដែលបង្កឱ្យមានជំងឺ រីឯដោយប្រយោលវិញ គឺវាធ្វើឱ្យមានការបាត់បង់ធនធានទឹក ដី ខ្យល់ ដែលជាតម្រូវការចំបាច់ដល់ការទ្រទ្រង់ការរស់នៅប្រចាំថ្ងៃរបស់មនុស្សនិងសត្វ។
- **ផលប៉ះពាល់ដល់សេដ្ឋកិច្ច** បើសិនជាមានការបំពុលដោយសំណល់សំរាមរឹងក្តី ឬសំណល់រាវក្តីគឺធ្វើឱ្យមនុស្សមានជម្ងឺ ហើយធ្វើឱ្យប្រាក់ចំណូលថយចុះដោយការកើតឡើងនូវជំងឺផ្សេងៗណាមួយនាំឱ្យប៉ះពាល់ដល់ផលដំណាំកសិកម្ម និងវិស័យទេសចរណ៍ថែមទៀតផង។

### គ. ដំណោះស្រាយនៃការបំពុលសំណល់រឹង រាវ

ក្នុងព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងសំណល់រឹងក៏ត្រូវបានរៀបចំ និងអនុវត្តន៏ដោយបន្ថែមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹងដែលបានចែងទាក់ទងទៅនឹងការគ្រប់គ្រងសំរាមទាំង២ប្រភេទ គឺសំរាមធម្មតា និងសំរាមដែលប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះដែរការរៀបចំ និងចាត់ចែងសំរាមទាំង២ប្រភេទនេះត្រូវស្ថិតនៅក្រោមការសម្រេចរបស់ក្រសួងបរិស្ថានក្នុងការពិនិត្យលើការអនុវត្តន៍ រៀបចំ ប្រមូល បោះចោល ដឹកជញ្ជូន ស្តុកកែច្នៃ កាត់បន្ថយ និងការចាក់ចោលសំរាម។[៦៧] សំណល់រឹងជាបញ្ហាមួយដែលរដ្ឋាភិបាលកំពុងប្រឈមមុខនឹងបញ្ហានេះ។ នាពេលបច្ចុប្បន្ននេះដែរសំណល់រឹងជាច្រើនត្រូវបានគេយកមកកែច្នៃជាថ្មីសម្រាប់ប្រើប្រាស់ឡើងវិញ និងប្រើក្នុងគោលដៅថ្មីផ្សេងទៀត ដើម្បីកាតបន្ថយសំណល់រឹង យើងមិនត្រូវចោល និងដុតសំណល់រឹងតាមដងផ្លូវសាធារណៈ មិនត្រូវប្រើប្រាស់ផលិតផលដែលប្រើថងប្លាស់ស្ទិច កែច្នៃឡើងវិញ ជាពិសេសធ្វើជីកំប៉ុងសម្រាប់យកទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងទីក្រុងព្រមទាំងមានភារកិច្ចដូចជា៖

- រៀបចំគោលនយោបាយផែនការយុទ្ធសាស្រ្ត លិខិតបទដ្ឋានគតិយុត្តជាមួយក្រសួងស្ថាប័ន និងដៃគូរដែលមិនពាក់ពន្ធ័ និងផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថកិច្ច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំណល់រឹង។
- គាំទ្រ និងលើកកម្ពស់ការអប់រំទាំងក្នុងប្រព័ន្ធនឹងក្រៅប្រព័ន្ធព្រមទាំងធ្វើការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំណល់រឹងដែលប្រកបដោយសុវត្ថិភាពបរិស្ថាន។

[៦៧] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦ អនក្រ.បក, ២៧ មេសា ១៩៩៩, មាត្រា៦

- ណែនាំអំពីការកាត់បន្ថយការបង្កើតការប្រើប្រាស់ថង់ប្លាស្ទិច ក៏ដូចជាសំណល់រឹងផ្សេងៗទៀតដែលអាចយកមកប្រើប្រាស់ឡើងវិញ ឬក៏អាចកែច្នៃបាន។
- លើកកម្ពស់សម្ភារៈដែលកើតឡើងពីការប្រើប្រាស់ឡើងវិញ ឬកើតចេញពីការច្នៃប្រឌិតដែលចេញពីសំណល់រឹង និងតាមដានត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងក្នុងទីប្រជុំជន។[៦៨]

ចំពោះបញ្ហាសំណល់ជាសារធាតុរាវ ជាទូទៅវាមានប្រភពចម្បងមកពីរោងចក្រលំនៅដ្ឋាន សហគ្រាសសិប្បកម្ម និងក្រុមហ៊ុនផ្សេងៗ។ ប្រភពនៃសំណល់អាចចេញមកពីលំនៅដ្ឋាន ទីផ្សារ អគារពាណិជ្ជកម្ម មជ្ឈមណ្ឌលផ្គត់ផ្គង់ស្បៀងអាហារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ និងអ្នកលក់ដូរតាមដងផ្លូវសាធារណៈ និងតំបន់ទេចរណ៍។ ចំពោះការគ្រប់គ្រងសំណល់រាវយើងគប្បីដឹងអំពីវិធានការក្នុងការអនុវត្តមួយចំនួនដូចជា៖

- ត្រូវរកវិធីដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាពលើសម្ភារៈដែលបានបោះចោលនោះគឺត្រូវកែច្នៃជាថ្មីដើម្បីញែករូបធាតុលោហៈ កែវ និងក្រដាសដែលចេញពីសំណល់រឹង។
- ហាមឃាត់ដាច់ខាត រាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់ដែលជាសារធាតុរាវដែលចេញពីប្រភពណាមួយដែលមិនបានឆ្លងកាត់ការអនុវត្តតាមកម្រិតស្តង់ដារ នៃការបញ្ចេញសំណល់ជាសារធាតុរាវដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក។
- ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃក្នុងគោលបំណងណាមួយ ត្រូវមកសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។[៦៩]
- ក្រសួងបរិស្ថាន ត្រូវយកគំរូតាមសំណល់រាវនៅគ្រប់ចំណុចបញ្ចេញចោលរបស់ប្រភពបំពុល។ ម្ចាស់សិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីក្រសួងបរិស្ថាន ដែលចុះយកគំរូតាមដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។[៧០]
- ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពីប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុលដែលបានចាំចេញនាំចូលបង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដី ឬលើដី។[៧១]

[៦៨] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក, ២៧ សីហា ២០១៥, មាត្រា៥
[៦៩] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ២៧ មេសា ១៩៩៩, មាត្រា១០
[៧០] អនុក្រឹត្យ លេខ២៧ អនក្រ.បក, មាត្រា១៩
[៧១] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ, ៩ មករា ១៩៩៧, មាត្រា១២

ចំពោះផែនការយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងសំណល់រឹង និងរាវ គឺមានការរៀបចំគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថានរួមជាមួយផែនការមេស្តីពីវិធានការចម្រុះនូវការគ្រប់គ្រងសំណល់រឹង និងរាវប្រកបដោយនិរន្តភាព។ ក្នុងនោះដែរក្រសួងបរិស្ថានក៏ព្យាយាមពង្រឹងទៅលើការអនុវត្តច្បាប់លើកកម្ពស់ការអនុវត្តកម្មវិធីកែច្នៃ និងការប្រើប្រាស់ឡើងវិញនៃសំណល់។ បង្កើតកម្មវិធីកាត់បន្ថយបរិមាណសំណល់ និងបង្កើតទីលានចាក់សំរាមប្រកបដោយបច្ចេកទេស និងមានអនាម័យ។

## ២.២. បញ្ហាប្រឈមនៃការរៀបចំខេត្ត

ជាការពិតណាស់នៅក្នុងខេត្តនីមួយៗការរៀបចំខេត្តឱ្យបានស្អាត និងមានសោភ័ណភាពសណ្តាប់ធ្នាប់សន្តិសុខសុវត្ថិភាព គឺតែងតែមានភាពលំបាកជាច្រើនដែលតែងតែជួបព្រោះត្រូវការធនធានមនុស្សសម្រាប់ការជួយរៀបចំខេត្តដើម្បីឱ្យមានភាពស្រស់ស្អាត និងមានភ្ញៀវទេសចរមកទស្សនា។ ម្យ៉ាងវិញទៀតរាល់ការរៀបចំខេត្តនីមួយៗតែងតែជួបប្រទះនឹងបញ្ហាជាច្រើនដូចជា តម្រូវការខ្ពស់ទាំងសម្ភារៈ និងប្រភពធនធានដទៃទៀត។ **ឧទាហរណ៍** ជាក់ស្តែងដើម្បីសាងសង់ស្ពានមួយបានគេត្រូវការឧបករណ៍ និងសម្ភារៈសំណង់ជាច្រើនព្រោះការធ្វើស្ពានមានទំហំធំជាពិសេសវាទាមទារនូវទំហំពលកម្មច្រើនក៏ដូចជាប្រាក់ឈ្នួលសម្រាប់កម្មករដូចគ្នា។ លើសពីនេះដើម្បីឱ្យសំណង់ស្ពានអាចទ្រទ្រង់បានល្អលុះត្រាតែការគណនាបានច្បាស់លាស់ និងការសាងសង់ត្រូវទៅតាមមាត្រដ្ឋានត្រឹមត្រូវ។ ជាការពិតណាស់សម្រាប់ការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពខេត្តរតនគិរីដូចគ្នាដែរតែងតែប្រឈមមុខនឹងបញ្ហាទាំងនេះ ហើយកត្តាដែលជាបញ្ហានោះរួមមាន៖

### ២.២.១. ធនធានមនុស្ស

ធនធានមនុស្សជាកត្តាចម្បងដែលមិនអាចខ្វះបានទោះបីជាសម័យបច្ចុប្បន្នកាន់តែទំនើបដោយមានការប្រើប្រាស់គ្រឿងយន្តជំនួសកម្លាំងមនុស្សក៏ពិតមែន តែនៅតែត្រូវការគ្រប់គ្រងពីមនុស្សដូចគ្នា។ ម៉្យាងវិញទៀតធនធានមនុស្សនៅក្នុងខេត្តរតនគិរីកាន់តែមានការធ្លាក់ចុះជាលំដាប់ដោយសារតែការធ្វើចំណាកស្រុកទៅកាន់ទីក្រុង និងការចាកចេញទៅធ្វើការនៅស្រុកក្រៅមិនតែប៉ុណ្ណោះមានអ្នកក្រៅចូលមកក្នុងខេត្តកាន់តែមានចំនួនច្រើនទ្វេដង។ ដោយហេតុថាកត្តាជីវភាពមានការរាំងស្ទះដល់ការរស់នៅរបស់ប្រជាជនដែលជាមូលហេតុនាំឱ្យពួកគាត់ព្យាយាមស្វែងរកលំនៅថ្មីដែលអាចទទួលយកបាន។ ចំពោះបញ្ហានេះជាកត្តាប្រឈមនៅទូទាំងប្រទេសមិនត្រឹមតែនៅក្នុងខេត្តរតនគិរីនោះទេ។ ម៉្យាងវិញទៀតអត្រាកំណើនប្រជាជន ក៏មិនសូវមានភាពល្អប្រសើរដែរ បើយើងផ្អែកលើតួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩បានបង្ហាញឱ្យឃើញថាអត្រាកំណើនប្រជាជនកម្ពុជាមានការស្រុតចុះជាលំដាប់បើធៀបនឹងការធ្វើជំរឿននៅឆ្នាំចាស់ដោយអត្រាកំណើនប្រជាជនមានការធ្លាក់ចុះរហូតដល់៣.៣ភាគរយ។[៧២] ខណៈដែលកម្លាំងពលកម្ម

[៧២] ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

មានការថមថយក៏នៅមានបញ្ហាដែលបង្កផលលំបាកដល់គម្រោងការអភិវឌ្ឍមួយកម្រិតទៀតនោះគឺ សមត្ថភាព ចំណេះ ជំនាញ គឺនៅមិនទាន់ពេញលេញតាមតម្រូវការជាក់ស្តែងនោះទេ។ ដូច្នេះហើយបានជា បញ្ហាធនធានមនុស្សជាកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់។

**២.២.២. គម្រោងថវិកា**

ប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ ការរីកចម្រើននៅមានកម្រិត ដោយហេតុថា ប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើន ជាពិសេសសង្គ្រាមផ្ទៃក្នុងដែលអូសបន្លាយអស់រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ក្រោយថ្ងៃរំដោះរាជរដ្ឋាភិបាលបានព្យាយាមអភិវឌ្ឍន៍រហូតបានដល់បច្ចុប្បន្ន។ ងាកមកមើល គម្រោងអភិវឌ្ឍន៍នីមួយៗវិញ គឺត្រូវការចំណាយទុនច្រើន ហើយជាញឹកញាប់ប្រទេសកម្ពុជាតែងតែទទួល ជំនួយមានសំណង និងឥតសំណងជាច្រើនពីបណ្តាប្រទេសផ្សេងៗ។ ខេត្តមួយនេះក៏មានសក្តានុពលខ្លាំង និងបានផ្តល់ឱកាសជាច្រើនទៅលើការវិនិយោគក្នុងវិស័យកសិកម្ម និងទេសចរណ៍ច្រើនជាងក្នុងការវិនិយោគ ក្នុងវិស័យសំណង់ កាលពីពេលកន្លងទៅថ្មីៗនេះខេត្តរតនគិរីកំពុងទទួលបាន គម្រោងវិនិយោគ រោងចក្រ កែច្នៃផលិតផលកសិកម្ម និងរោងចក្រឧស្សាហកម្មជាច្រើនដោយគិតមកទល់ពេលនេះគម្រោងចំនួនរោង ចក្រ និងសិប្បកម្មក្នុងខេត្ត មានចំនួនសរុប ២៣០ ហើយដោយសារ សក្តានុពលដីធ្លី មានអំណោយផលលើ វិស័យកសិកម្មបានធ្វើឱ្យខេត្តនេះអាចនាំចេញកសិផលទៅក្រៅប្រទេសបានជាង៨៧,០០០តោន មានទឹក ប្រាក់ប្រមាណ៣៧លានដុល្លារកាលពីឆ្នាំមុន។[៧៣]

**២.២.៣. កង្វះបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ**

ដោយសារបច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍ដូច្នេះហើយទើបធ្វើឱ្យការរៀបចំខេត្ត មានផលវិបាកដោយមូលហេតុខ្វះបច្ចេកទេសមិនទាន់មានឧបករណ៍ទំនើបក្នុងការសាងសង់ ហេតុនេះហើយ ទើបធ្វើឱ្យការរៀបចំហេដ្ឋារចនាសម្ព័ន្ធកម្ពុជានៅមានកម្រិតនៅឡើយ។ អ្វីដែលគួរអោយកត់សម្គាល់មិនត្រឹមតែ កង្វះនូវឧបករណ៍ប៉ុណ្ណោះទេ តែខណៈដែលប្រទេសកម្ពុជាទើបតែងើបពីសង្គ្រាមប៉ុន្មានសតវត្សចុងក្រោយធ្វើឱ្យ បាត់បង់នូវបុគ្គលឆ្នើមក៏ដូចជាអ្នកមានចំណេះដឹងជាច្រើនជាហេតុបណ្តាលឱ្យបច្ចុប្បន្នទាមទារនូវបុគ្គលដែល មានជំនាញខ្ពស់ជាច្រើនក្នុងការអភិវឌ្ឍហើយដោយសារជំនាញបច្ចេកទេសក្នុងស្រុកនៅមានកម្រិតទើបបណ្តា លឱ្យមាននូវតម្រូវការអ្នកបច្ចេកទេសពីបរទេស។ ជាការពិតណាស់ក្នុងវិស័យសំណង់នាពេលបច្ចុប្បន្នមិនត្រឹម តែរីកចម្រើននោះទេ គឺគម្រោងសាងសង់នីមួយៗកាន់តែប្រណិត និងទំនើប ដូច្នេះវិស្វករដែលទើបតែចាប់ផ្តើម ការងារមិនអាចកាន់កាប់ការងារសំខាន់ៗនោះទេលុះត្រាតែជាវិស្វករអាជីព ដែលមានបទពិសោធន៍ការងារច្រើន ឆ្នាំ ទើបអាចទទួលឱកាសក្នុងការកាន់គ្រោងការនោះ។ នេះគឺជាបញ្ហាចោទដែលទាមទារឱ្យមានវិស្វករពី

---

[៧៣] គេហទំព័រ https://propertyarea.asia/archives/៥៥០៧០ ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣

បរទេសដែលគេមានជំនាញ និងការយល់ដឹងខ្ពស់ជាង វិស្វករ ដែលទើបប្រឡូកក្នុងការងារដែលមិនមែនជាវិស្វករអាជីពនោះទេ។

## ២.៣. ដំណោះស្រាយ

នៅក្នុងការរៀបចំខេត្តមួយ គឺតែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលស្របពេលផែនការអភិវឌ្ឍន៍ទាំងអស់នោះត្រូវការផ្នែកធនធានមនុស្ស ថវិការ និងបញ្ហាបច្ចេកទេសផ្សេងៗ ហើយនឹងត្រូវប្រើប្រាស់រយៈពេលវែងដែលមានន័យថាគម្រោងត្រូវតែចំណាយដើមទុន និងប្រើពេលវេលាយូរ។

❖ **ធនធានមនុស្ស**

ធនធានមនុស្ស គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍប្រទេស ហើយបច្ចុប្បន្ននេះប្រទេសកម្ពុជាបានកំពុងយកចិត្តទុកដាក់ជាខ្លាំង ក្នុងការជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជាមានធនធានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការទៅតាមវិស័យនានា។ ដើម្បីដោះស្រាយរាល់បញ្ហាដែលជួបប្រទះ ក្នុងការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់គណៈគ្រប់គ្រងគួរយកចិត្តទុកដាក់នូវចំណុចមួយចំនួនៈ

- ការគិតគូរអំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីដូចជា ការរៀបចំការបណ្តុះបណ្តាលទៅតាមមុខតំណែង កំណត់តម្រូវការនៃការបណ្តុះបណ្តាល ការរៀបចំកសម្រាប់ការបណ្តុះបណ្តាល។
- ការជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងស្របតាមតម្រូវការរបស់ក្រសួងស្ថាប័ន
- ការពង្រឹងមន្ត្រី តាមជំនាញ តាមទីកន្លែងការងារ និងការវាយតម្លៃគុណផលរបស់មន្ត្រី
- ការលើកទឹកចិត្តដល់មន្ត្រី ដូចជាបរិយាសការងារ ការឡើងថ្នាក់នឹងឋានន្តរសក្តិ ការឈប់សម្រាកប្រចាំសប្តាហ៍ និងប្រាក់បៀវត្សរ៍នៅពេលមានបុណ្យទានជាដើម។[៧៤]

❖ **កង្វះបច្ចេកទេស**

បច្ចុប្បន្នប្រទេសកម្ពុជា មានការខ្វះខាតអ្នកជំនាញបច្ចេកទេស ហើយកង្វះខាតទាំងអស់នេះក៏ ព្រោះតែប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ទាំងវិស័យឧស្សាហកម្ម ទាំងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា និងសេវាកម្មផ្សេងៗទៀត។ ការអភិវឌ្ឍទាំងអស់នេះ គឺចាំបាច់ត្រូវការអ្នកជំនាញបច្ចេកទេសដើម្បីជួយគាំទ្រនៅក្នុងការអភិវឌ្ឍគ្រប់វិស័យទាំងអស់។ យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ដោយប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ ៤គឺៈ

- កៀងគរ និងទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស និងវិនិយោគទុនឯកជននៅក្នុងស្រុកដោយផ្តោតលើឧស្សាហកម្មធំៗ ការអភិវឌ្ឍ និងការពង្រីកទីផ្សារ និងការអភិវឌ្ឍការផ្ទេរបច្ចេកវិទ្យា។
- អភិវឌ្ឍន៍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម។
- ការកែលម្អបរិស្ថាននិយតកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង។

---

[៧៤] របាយការណ៍ស្តីពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា

- អភិវឌ្ឍន៍ ធនធានមនុស្ស បណ្ដុះបណ្ដាលជំនាញ ការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ប្រព័ន្ធដឹកជញ្ជូន ឡូជីស្ទីក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត សេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។

### ២.៣.១. ការសហការពីប្រជាពលរដ្ឋ

ជាការពិតណាស់រាជរដ្ឋាភិបាលបានព្យាយាមសម្រួលភាពលំបាកចំពោះការរស់នៅប្រជាជនតាមរយៈការរៀបចំអភិវឌ្ឍន៍ខេត្ត ក្រុង ស្រុកទាំងអស់ ដោយធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ បើជាចាំបាច់សកម្មភាពប្រជាជន និងការរួបរួម យោគយល់ អាធ្យាស្រ័យពីសំណាក់ប្រជាពលរដ្ឋជាកម្លាំងជំរុញដ៏ខ្លាំងក្លាក្នុងការអភិវឌ្ឍ។ ជាក់ស្តែងប្រជាជនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចផងដែរ ក្នុងប្រការផ្សេងៗទាក់ទងនឹងកិច្ចរៀបចំក្រុង។ **ឧទាហរណ៍** ប្រសិនបើមានការពង្រីកទំហំផ្លូវដើម្បីសម្រួលចរាចរណ៍លើដងផ្លូវ ហើយច្បាស់ណាស់ថាការពង្រីកផ្លូវនេះ តែងតែប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ នៅមុំនោះជាក់ជាមិនខាន ដូច្នេះអាជ្ញាធរត្រូវចុះសុំការសហការពីម្ចាស់លំនៅ ដោយមានការចរចាពីការខូចខាតផ្សេងៗ ដូចជាសំណងការខូចខាតផងដែរ។ ហើយក្នុងនាមជាម្ចាស់លំនៅត្រូវយោគយល់ដល់រដ្ឋាភិបាលដែលព្យាយាមផ្ដល់ប្រយោជន៍រួមក្នុងសហគមន៍នោះ។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋដែលមានផ្ទះអមសងខាងផ្លូវសូមឱ្យជួយថែរក្សា និងមានការយោគយល់ហាមដាច់ខាតយកចិញ្ចើមផ្លូវសាធារណៈរបស់រដ្ឋធ្វើអាជីវកម្មដែលនាំឱ្យប៉ះពាល់សណ្ដាប់ធ្នាប់ បរិស្ថានក្នុងក្រុងបានលុងដើម្បីសោភ័ណភាពទាក់ទាញភ្ញៀវជាតិ អន្តរជាតិ មកកម្សាន្តច្រើន ដូចជាចូលផ្សារទិញទំនិញផ្សេងៗ ដែលជួយជំរុញសេដ្ឋកិច្ចគ្រួសារកើនឡើងមួយកម្រិតទៀត។ បន្ថែមលើនេះទៀតដើម្បីឱ្យក្រុងបានលុងរឹតតែមានសោភ័ណភាពនោះរដ្ឋបាលខេត្តរតនគិរី ក្នុងពេលឆាប់ៗខាងមុខនេះនឹងដាំដើមសាគូរ៉ា ដើមផ្កាត្របែកព្រៃ ដើមចំប៉ី និងដើមក្ងោកជា។[៧៥]

### ២.៣.២. ប្លង់គោល

ជាការពិតណាស់ប្លង់គោលអភិវឌ្ឍន៍នីមួយៗពិតជាមានសារៈសំខាន់ណាស់ ព្រោះប្លង់គោលបានកំណត់ពីទំហំផ្លូវ ដើម្បីកំណត់ពីផែនការប្រើប្រាស់ដីធ្លី នៅក្នុងមូលដ្ឋានណាមួយមានភាពសមស្រប និងដើម្បីជំរុញការប្រើប្រាស់ដី និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ សម្រាប់ផែនការអភិវឌ្ឍន៍ខេត្តនីមួយៗត្រូវឈរលើប្លង់គោល ឬប្លង់គោលប្រើប្រាស់ដី(Master Plan)ដែលជាផែនការកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍ រូបវន្ត និងកំណត់អំពីប្រភេទ ប្រើប្រាស់ដី បង្ហាញអំពីទម្រង់ទីក្រុងនៃបណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង គមនាគមន៍សំខាន់ៗនៃទីក្រុង និងការធ្វើសមាហរណកម្ម។ ជាងនេះទៀតប្លង់គោលត្រូវភ្ជាប់មកជាមួយនូវ

[៧៥] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews ដកស្រង់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

គម្រោងអភិវឌ្ឍន៍ទីក្រុងតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង។[៧៦] ម្យ៉ាងវិញទៀតប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។[៧៧]

តាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញឱ្យឃើញថាប្លង់គោលជាជំហរ ដ៏សំខាន់ក្នុងការកសាង និងរៀបចំខេត្តទៅតាមមាត្រដ្ឋានត្រឹមត្រូវ។ ដូច្នេះរាល់ការរៀបចំខេត្តមួយប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនោះ គឺត្រូវផ្តោតសំខាន់ទៅលើប្លង់គោលនេះផ្ទាល់។

ជាក់ស្តែងនៅក្នុងខេត្តរតនគិរីការសិក្សាស្តីពីប្លង់គោលប្រើប្រាស់ដីស្រុកអូរជុំ និងស្រុកបរកែវខេត្តរតនគិរីក៏ជាផ្នែកមួយនឹងជួយជំរុញឱ្យភូមិភាគឦសាន ដែលជាតំបន់មួយឱ្យក្លាយទៅជាតំបន់សក្តានុពលដីមានជីរជាតិសម្បូរធនធានធម្មជាតិរួមផ្សំជាមួយកត្តាភូមិសាស្ត្រឱ្យទៅជាការអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពមានគោលដៅរួម និងមានអន្តរវិស័យ។ បើយើងក្រឡេកមកមើលលើគណៈកម្មការរៀបចំដែនដីថ្នាក់ខេត្តរតនគិរីបានរៀបចំពិនិត្យសេចក្តីព្រាងឯកសារប្លង់គោលប្រើប្រាស់ដីនៅស្រុកតាវែង ស្រុកអណ្តូងមាស និងស្រុកអូរយ៉ាដាវនាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។ នៅក្នុងកិច្ចប្រជុំនេះលោកអភិបាលខេត្តបានជំរុញឱ្យក្រុមការងារបច្ចេកទេសរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីស្រុកទាំង៣ សហការជាមួយអ្នកពាក់ព័ន្ធពន្លឿនឱ្យបានឆាប់រហ័ស និងគ្រប់ជ្រុងជ្រោយទៅតាមបទដ្ឋានបច្ចេកទេស និងច្បាប់ជាមូលដ្ឋានដើម្បីដាក់ឆ្លងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុក និងខេត្តដើម្បីបញ្ជូនសុំការសម្រេចពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ពិនិត្យ និងសម្រេច។ ម្យ៉ាងវិញទៀតនៅក្នុងស្រុកទាំង៣នេះត្រូវរៀបចំគម្រោងអភិវឌ្ឍន៍ក្នុងស្រុកឱ្យមានភាពច្បាស់លាស់ល្អប្រសើររួមមានការអភិរក្សវិស័យទេសចរណ៍ធម្មជាតិ វប្បធម៌ អត្តសញ្ញាណ វប្បធម៌ជនជាតិដើមភាគតិចហេដ្ឋារចនាសម្ព័ន្ធ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងត្រូវថែរក្សាការពារឱ្យបាននូវសម្បត្តិធម្មជាតិបានគង់វង្ស។ ត្រូវរក្សាឱ្យបាននូវផ្លូវប្រវត្តិសាស្ត្រ និងធនធានដែលនៅសល់ពីសម័យតស៊ូដែលតស្សូរជនខ្មែរពីមុនមកប្រើក្នុងសម័យសង្គ្រាមឱ្យបានល្អ ដើម្បីបង្កើតជាគោលដៅអេកូទេសចរណ៍មួយសម្រាប់ទាក់ទាញទៅថ្ងៃខាងមុខ សម្រាប់ភ្ញៀវទេសចរមកលេងកម្សាន្តខេត្តយើងបានកាន់តែច្រើន។ បន្ថែមពីនោះត្រូវកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលរៀបចំដែនដីតម្រង់ទិសការអភិវឌ្ឍកសិ-ឧស្សាហកម្ម និងការកែច្នៃ គ្រប់គ្រងការពារប្រើប្រាស់អភិវឌ្ឍន៍ដី និងធនធានធម្មជាតិ។

[៧៦] សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា១២

[៧៧] ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ២៤ ឧសភា ១៩៩៤, មាត្រា៧

ជាការពិតណាស់ប្លង់គោលត្រូវបានបង្កើតឡើងយ៉ាងយកចិត្តទុកដាក់ ដោយក្នុងគោលបំណងឱ្យមានការសិក្សាទៅលើទីតាំងភូមិសាស្ត្រជាពិសេសឈរលើគោលការណ៍ច្បាប់ជាធំជាក់ស្តែងដូចជាគោលនយោបាយជាតិដែលស្តីអំពីការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ បានកំណត់ឱ្យរៀបចំច្បាប់ស្តីពី សំណង់។ យោងតាមមាត្រា១ នៃច្បាប់ស្តីពីសំណង់នេះបានបញ្ញត្តិពីគោលបំណងនៃការបង្កើតច្បាប់នេះក្នុងន័យធានាគុណភាពសន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ និងសុខមាលភាពរបស់ម្ចាស់សំណង់អ្នក ប្រើប្រាស់សំណង់ និងសាធារណៈជនព្រមទាំងសោភ័ណភាព និងបរិស្ថានល្អ សម្រាប់ការរស់នៅប្រកបដោយ ចីរភាព សំដៅលើកកម្ពស់សុខមាលភាពសាធារណៈ គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការប្រកបការងារ និងប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយបង្កើនការជឿទុកចិត្តវិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចសង្គម។

ដូច្នេះការដែលបានបង្ហាញឱ្យឃើញថា ប្លង់គោលជាដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពតាមតំបន់នីមួយៗអាចដំណើរការបានល្អប្រសើរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពពិតជាមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យទីក្រុង ឬខេត្តមួយមានរបៀបរៀបរយ និងមានបរិស្ថានស្អាត។ តួយ៉ាងសម្រាប់ខេត្តរតនគិរីផ្ទាល់បានរៀបចំផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ លូ សួនច្បារ បង្គោលភ្លើងបំភ្លឺផ្លូវជាច្រើនគួរឱ្យកត់សម្គាល់។ ម្យ៉ាងទៀតតាមរយៈការខិតខំប្រឹងប្រែងរបស់អភិបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធនានានៅក្នុងការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តរតនគិរីបានធ្វើឱ្យទេសចរណ៍មួយនេះកាន់តែល្អប្រសើរទាំងសន្តិសុខ សុវត្ថិភាព របៀបរៀបរយ និងសោភ័ណភាព។

ទោះបីជាអភិបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធបានខិតខំប្រឹងប្រែងធ្វើការរៀបចំហេដ្ឋារចនាសម្ព័ន្ធរបៀបរៀបរយ សណ្តាប់ធ្នាប់ និងសោភ័ណភាព ក៏ពិតមែនប៉ុន្តែនៅក្នុងនោះបញ្ហា និងចំនុចខ្វះខាតមួយចំនួនក៏នៅតែកើតមានដូចជា ករណីឃាតកម្ម លួច ឆក់ ប្លន់ និងមិនទាន់មានការកែលម្អចំពោះផ្សារនៅក្នុងខេត្តមិនទាន់មានអនាម័យសមរម្យសម្រាប់បម្រើឱ្យសេវាទេសចរណ៍ ហើយម្យ៉ាងទៀតកណ្តាលក្រុងបានលុងខ្វះខាតចំណតយានយន្តដែលបណ្តាលឱ្យមានការកកស្ទះចរាចរណ៍នៅពេលមានកម្មវិធីបុណ្យជាតិ។

សរុបមកការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្ត គឺពិតជាមានសារៈសំខាន់ពិតប្រាកដមែនពីព្រោះថាការរៀបចំខេត្តជាបញ្ហាដែលពាក់ព័ន្ធជាមួយការរៀបចំ រូបរាង និងមុខងាររបស់តំបន់ជាយស្រុក ទីប្រជុំជនដែលមានស្រាប់ ឬមិនទាន់មានសោភ័ណភាព និងសណ្តាប់ធ្នាប់។ ការរៀបចំខេត្តដើម្បីឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់នេះ គឺទាមទារឱ្យមានការចូលរួមពីវិស័យពាក់ព័ន្ធជាច្រើនតួយ៉ាងដូចជា ការធ្វើផែនការការអភិវឌ្ឍស្ថាបត្យកម្ម វិស្វកម្ម និងជាពិសេសហិរញ្ញវត្ថុជាដើម។ ម្យ៉ាងវិញទៀតចំពោះការរៀបចំខេត្តនេះផងដែរមិនមែនត្រឹមតែ អភិបាលខេត្ត អាជ្ញាធរ ឬស្ថាប័នពាក់ព័ន្ធនោះទេដែលត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំនេះ គឺប្រជាពលរដ្ឋក៏ត្រូវតែចូលរួមសហការ ដូចជាការចូលរួមចំណែកក្នុងការ ថែរក្សាការពារហេដ្ឋារចនា សម្ព័ន្ធ និងបរិស្ថានជុំវិញខ្លួនឱ្យកាន់តែល្អប្រសើរគង់វង្សស្ថិតស្ថេរជាចីរកាល។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ថ្វីត្បិតតែអភិបាល និងអាជ្ញាធរខេត្តរតនគិរីបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំ និងអភិវឌ្ឍន៍ខេត្តក៏ពិតមែនប៉ុន្តែឃើញថាការរៀបចំ និងអភិវឌ្ឍន៍នេះបានជួបនូវបញ្ហាប្រឈម និងនៅមានចំណុចខ្វះខាតជាច្រើនហើយមិនទាន់បានបំពេញតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក៏ដូចជាភ្ញៀវទេសចរនៅឡើយ។ បញ្ហានេះផងដែរជាបញ្ហាដែលប្រជាពលរដ្ឋចង់ឱ្យអាជ្ញាធរធ្វើការដោះស្រាយ និងកែលម្អ ជាពិសេសទាក់ទងទៅនឹងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាន។ ដើម្បីធ្វើការដោះស្រាយនឹងបញ្ហាទាំងនេះនាងខ្ញុំទាំងពីរនាក់សូមអនុញ្ញាតបញ្ចេញមតិសំណូមពរមួយចំនួនដូចតទៅៈ

- អាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបង្កើនការបង្ក្រាបក៏ដូចជាទប់ស្កាត់នូវបញ្ហាចោរកម្ម ល្បែងស៊ីសងគ្រប់ប្រភេទ ក្មេងទំនើង និងត្រួតពិនិត្យទៅលើបញ្ហាបរិស្ថានដើម្បីកុំឱ្យមានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងបរិយាកាសក្នុងខេត្ត។
- អាជ្ញាធរខេត្តរតនគិរី គួរតែធ្វើការរៀបចំសោភ័ណភាពបឹងកន្សែងឱ្យបានស្អាតដើម្បីជាការទាក់ទាញភ្ញៀវទេសចរក៏ដូចជាប្រជាពលរដ្ឋអាចមកអង្គុយលេងកម្សាន្តនៅតាមមាត់បឹងស្រូបយកខ្យល់អាកាស និងដើរហាត់ប្រាណប្រកបដោយផាសុកភាព។
- រាជរដ្ឋាភិបាលគួរតែផ្តល់នូវកញ្ចប់ថវិកាបន្ថែមសម្រាប់អ្នកវិទ្យាសាស្ត្រ និងអ្នកសិក្សាស្រាវជ្រាវដើម្បីរិះរកមធ្យោបាយ និងបច្ចេកវិទ្យាជួយដល់ការកាត់បន្ថយការបំពុលបរិស្ថានពីកត្តាផ្សេងៗជាពិសេសពីផ្សែងយានយន្តផ្សេងៗ។
- សូមសំណូមពរដល់រាជរដ្ឋាភិបាល សូមឱ្យផ្តល់កញ្ចប់ថវិកា ទៅដល់សាលាក្រុងឱ្យបានគ្រប់គ្រាន់ដើម្បីយកទៅអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធដូចជាសាងសង់ផ្លូវ ស្ពានបន្ថែម កែលម្អផ្លូវពីផ្លូវក្រាលក្រួសក្រហមឱ្យទៅជាផ្លូវបេតុង ឬថ្នល់ក្រាលកៅស៊ូ ហើយក៏សូមសំណូមពរផងដែរចំពោះប្រព័ន្ធលូសាធារណៈសូមមេត្តារៀបចំប្រព័ន្ធលូឱ្យបានត្រឹមត្រូវតាមស្តង់ដារដោយធ្វើការកែប្រែពីលូតូចទៅជាលូធំវិញ ដើម្បីចៀសវាងពីបញ្ហាកកស្ទះប្រព័ន្ធលូបង្ហូរទឹកដែលបង្កឱ្យមានការជន់លិចផ្លូវ និងពិបាកធ្វើដំណើរ។
- សូមសំណូមពរដល់រាជរដ្ឋាភិបាលឱ្យមានការពង្រឹងច្បាប់បរិស្ថានបន្ថែមទៀតទាក់ទងនឹងការចោលសំរាម ដោយធ្វើការផាកពិន័យឱ្យធ្ងន់ធ្ងរចំពោះបុគ្គលណាដែលបោះចោលសំរាមមិនមានសណ្តាប់ធ្នាប់នៅតាមទីសាធារណៈ និងវេចខ្ចប់សំរាមមិនបានត្រឹមត្រូវ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់វិសោធនកម្ម ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៤ មករា ២០១៩
- ច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ២៤ ឧសភា ១៩៩៤
- អនុក្រឹត្យ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ នាំចូលដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា, លេខ២៧ អនក្រ.បក, ២៨ មករា ២០១៩
- អនុក្រឹត្យ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិទី៣, លេខ២៦ អនក្រ.បក, ២៥ មករា ២០១៩
- អនុក្រឹត្យ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ១៩ អនក្រ.បក ០៨ កុម្ភៈ ២០១៧
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក, ២៧ សីហា ២០១៥
- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្បឹក្សា គណៈអភិបាល ខេត្តក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩
- អនុក្រឹត្យ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ២១៩ អនក្រ/បក, ១៤ ធ្នូ ២០០៩
- អនុក្រឹត្យ ស្តីពីការផ្លាស់ប្តូរស្រុកបានលុងទៅជាក្រុងបានលុង, លេខ២២៧ អនក្រ/បក, ៣០ ធ្នូ២០០៨
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រង សំណល់រឹង, លេខ៣៦ អនក្រ/បក, ២៧ មេសា ១៩៩៩
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យ ការបំពុលទឹក, លេខ២៧ អនក្រ/បក, ២៧ មេសា ១៩៩៩
- ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត, លេខ៣៨៧១ ប្រក, ០៨ សីហា ២០១៧
- សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្ត
- ផែនការណែនាំ ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព, លេខ០២០ ជក, ១៦ សីហា ២០១០
- សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- ឯកសារអប់រំបំណិនជីវិត ស្តីពីបរិស្ថាន ឆ្នាំ២០១៣
- ជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩

## ២. ឯកសារយោងជាសៀវភៅ

- សៀវភៅ នីតីនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣
- សៀវភៅកម្រងឈ្មោះ និងចំនួន រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត
- សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣
- សៀវភៅបរិស្ថានជំនួយស្មារតី ឆ្នាំ២០០៥
- National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment, មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្តាន់ រិន
- របាយការណ៍ស្តិពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា
- ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## ៣.ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://www.ratanakiri.gov.kh/
- គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/93619-2018-07-23-02-26-38.html
- គេហទំព័រ https://www.information.gov.kh/
- គេហទំព័រ http://www.healthcambodia.com/p6241
- គេហទំព័រ https://km.warbletoncouncil.org/tipos-contaminacion-acustica-16274#menu-1
- គេហទំព័រ https://thmeythmey.com/?page=detail&id=103631
- គេហទំព័រ https://www.postposmo.com
- គេហទំព័រ https://www.khsearch.com/qna/5780

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់វិសោធនកម្ម ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៥៥៦ នស/រកម/០៥០៨/០១៧, ២៨ ឧសភា ២០០៨។

**ឧបសម្ព័ន្ធទី២៖** ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ២៤ ឧសភា ១៩៩៤។

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក, ២៧ សីហា ២០១៥។

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩។

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ២១៩ អនក្រ/បក, ១៤ ធ្នូ ២០០៩។

**ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ/បក ១០ កក្កដា ២០០០។

**ឧបសម្ព័ន្ធទី៧៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រង សំណល់រឹង, លេខ៣៦ អនក្រ/បក, ២៧ មេសា ១៩៩៩។

**ឧបសម្ព័ន្ធទី៨៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យ ការបំពុលទឹក, លេខ២៧ អនក្រ/បក, ២៧ មេសា ១៩៩៩។

## ២.ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីរដ្ឋបាលខេត្តរតនគិរី។

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗនៅក្នុងខេត្តរតនគិរី និងសោភ័ណភាព។

**ឧបសម្ព័ន្ធទី៣៖** សកម្មភាពរបស់រដ្ឋបាលខេត្តរតនគិរី។

# ឧបសម្ព័ន្ធគតិយុត្ត